**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**


**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម របស់ធនាគារភោណាឌីយ៉ា ក.អ សាខាកណ្តាល

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦

ឈ្មោះស្ថាប័ន៖ **ធនាគារភោណាឌីយ៉ា ក.អ សាខាកណ្តាល**


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **សាន់ គិញ្ញយ៉ាន់**
**លីលួន វិបុល**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ព្រុំ ទេវី**


ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច
ជំនាញ គ្រប់គ្រងសហគ្រាស

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេររបាយការណ៍ ២០១៦

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម
# របស់ធនាគារកាណាឌីយ៉ា ក.អ សាខាកណ្ដាល

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦

ឈ្មោះស្ថាប័ន៖ **ធនាគារកាណាឌីយ៉ា ក.អ សាខាកណ្ដាល**

តាក់តែងឡើងដោយ
និស្សិតឈ្មោះ: **សាន់ គិញយ៉ាន់**
**លីឈួន វិបុល**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ព្រុំ ទេវី**

ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច
ជំនាញ គ្រប់គ្រងសហគ្រាស

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេររបាយការណ៍ ២០១៦

# អារម្ភកថា

នាពេលបច្ចុប្បន្ននេះ សេដ្ឋកិច្ចប្រទេសកម្ពុជាកំពុងមានការរីកចំរើនជាលំដាប់ទោះបីជាប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមរាំរៃអស់រយៈពេលជាច្រើនឆ្នាំ ដែលធ្វើអោយប្រទេសកម្ពុជាបាត់បង់នូវអត្ថប្រយោជន៍ជាច្រើន។

ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចធ្វើអោយមានដំណើរការពេញផ្ទៃប្រទេសនូវរូបិយវត្ថុ និងរូបិយប័ណ្ណ។ បណ្តាធនាគារនៅប្រទេសកម្ពុជា ធនាគារកាណាឌីយ៉ា ក.អ គឺជាធនាគារដែលនាំមុខគេ ហើយមានបំរើសេវាកម្មជូនប្រជាពលដ្ឋគ្រប់លំដាប់ថ្នាក់ ដែលរួមមានប្រតិបត្តិការ ទទួលប្រាក់បញ្ញើរ-សន្សំ ការផ្តល់ឥណទាននិងមានសេវាកម្មជាច្រើនផ្សេងៗទៀត។ ទន្ទឹមនេះការផ្តល់ឥណទានរបស់ធនាគារ ជូនប្រជាពលរដ្ឋដែលខ្វះខាតនូវដើមទុនក៏ ដូចជាអ្នកកវិនិយោគមួយចំនួនដែលមានបំណងពង្រីកអាជីវកម្ម និងពង្រីកសាថ្មីៗបន្ថែមដើម្បីបង្កើន នូវកំរិតជីវភាពរបស់ពួកគាត់អោយកាន់តែមានភាព ល្អប្រសើរក៏ដូចជារួមចំណែកជួយជំរុញនូវសេដ្ឋកិច្ចអោយកាន់តែមានភាពរីកចំរើន។ ម្យ៉ាងវិញទៀតការផ្តល់ឥណទាន ពិតជាមានសារៈសំខាន់នៅក្នុង វិស័យសេដ្ឋកិច្ចទើបជំរុញ អោយយើងទាំងពីរនាក់សំរេចចិត្តជ្រើសរើសនូវប្រធានបទ ស្តីអំពី "ការគ្រប់គ្រងឥណទានខ្នាតតូចនិងមធ្យមរបស់ធនាគារកាណាឌីយ៉ា ក.អ" ។

ជាចុងបញ្ចប់នេះ យើងខ្ញុំទាំងពីរសង្ឃឹមទុកជាមុនថា របាយការណ៍កម្មសិក្សានេះពិតជាមានអត្ថប្រយោជន៍ ដល់មិត្តនិស្សិត ដែលមានបំណងស្រាវជ្រាវ និងស្វែងយល់បន្ថែមពីប្រតិបត្តិការ "ការគ្រប់គ្រងឥណទានខ្នាតតូចនិងមធ្យមរបស់ធនាគារកាណាឌីយ៉ា ក.អ" ។ យើងខ្ញុំទាំងពីរនាក់ក៏សូមអភ័យទោសនូវរាល់កំហុសឆ្គង ដែលកើតឡើងដោយអចេតនា ព្រោះការចងក្រងរបាយការណ៍កម្មសិក្សានេះពិតជាមាននូវចំនុចខ្វះខាតត្រង់កន្លែងណាមួយជាមិនខាន។ ដើម្បីជាការជួយលំអរនិងស្ថាបនាបន្ថែម យើងខ្ញុំទាំងពីរនាក់រង់ចាំទទួលនូវការផ្តល់មតិយោបល់និងទស្សនៈល្អៗពីសំណាក់មិត្ត អ្នកអាន មិត្តនិស្សិត ព្រមទាំងសាស្ត្រាចារ្យ ដោយក្តីសោមនស្សរីករាយ ដើម្បីអោយរបាយការណ៍នេះ កាន់តែមានលក្ខណៈល្អប្រសើរឡើង។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងសហគ្រាស ជំនាន់ទី១៥ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបាន ស្រាវជ្រាវសរសេររបាយការណ៍បញ្ចប់ថ្នាក់បរិញ្ញាបត្រលើប្រធានបទ "ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម" របស់ធនាគារកាណាឌីយ៉ា ក.អ សាខាកណ្តាល ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រក្នុង ឆ្នាំសិក្សា ២០១២ ~ ២០១៦។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើតនិងចិញ្ចឹមបីបាច់ថែរក្សារូបយើងខ្ញុំតាំងពីតូចរហូតដល់ពេញវ័យ។ យ៉ាងណាមិញលោកទាំងពីរ តែងតែផ្តល់ដំបូន្មានល្អៗ ប្រកបដោយព្រហ្មវិហាធម៌ ព្រមទាំងជួយឧបត្ថម្ភពួកយើងខ្ញុំទាំងផ្នែកស្មារតីផ្នែកសំភារៈ និងបានផ្តល់ជាថវិការដល់ពួកយើងខ្ញុំដើម្បីយកទៅធ្វើការសិក្សាអប់រំអោយដល់ពួកយើងខ្ញុំ ដើម្បីទទួលបាននូវចំណេះដឹងខ្ពង់ខ្ពស់នឹងអាចក្លាយខ្លួនជា កូនល្អ មិត្តល្អ ក៏ដូចជាពលរដ្ឋល្អម្នាក់ក្នុងសង្គម ដោយអ្នកមានគុណទាំងពីរពុំអាចគិតពីការនឿយហត់អ្វីឡើយ។

- ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរងព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យព្រមទាំងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយសម្របសម្រួលក្នុងការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ។
- លោកស្រីសាស្ត្រាចារ្យ ព្រុំ ទេវី ដែលលោកស្រីបានធ្វើការណែនាំដល់ក្រុមយើងខ្ញុំ និងធ្វើការលើកទឹកចិត្តក្នុងកំឡុងពេលនៃ ដំណើរការសរសេររបាយការណ៍បញ្ចប់ការសិក្សាតាំងពីដើមរហូតទទួលជោគជ័យក្នុងកិច្ចការស្រាវជ្រាវនិងចងក្រងជាសៀវភៅនេះឡើង។
- លោកនាយកនិងបណ្តាបុគ្គលិកទាំងអស់ នៃធនាគារកាណាឌីយ៉ាក.អ សាខាកណ្តាលដែលបានអនុញ្ញាតអោយយើងខ្ញុំ បានធ្វើការចុះកម្មសិក្សាស្រាវជ្រាវ នៅស្ថាប័នរបស់លោក ដើម្បីទទួលបាននូវចំណេះដឹង និងយល់ច្បាស់អំពីស្ថានភាពទូទៅរបស់ធនាគារកាណាឌីយ៉ា ក.អ បូកទាំងសេវានានារបស់ស្ថាប័នជាពិសេសគឺការគ្រប់គ្រងឥណទានខ្នាតតូចនិងមធ្យម ដែលជាសេវាកម្មដែលក្រុមរបស់ក្រុមយើងខ្ញុំធ្វើការផ្តោតសំខាន់ជាចំបង។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមជូនពរអោយលោកអ្នកដែលបានរាយនាមខាងលើសូមទទួលបានសុខភាពល្អ ទទួលបានជ័យជំនះគ្រប់កិច្ចការងារ និងសូមប្រសិទ្ធពរជ័យទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ អោយកើតមានដល់លោកអ្នកកុំអោយឃ្លៀងឃ្លាតឡើយ។

# មាតិកា


បញ្ជីតារាង ........ i

បញ្ជីរូបភាព ........ ii

បញ្ជីអក្សរកាត់ ........ iii

បញ្ជីឧបសម្ព័ន្ធ ........ iv


# សេចក្តីផ្តើម


១.លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២

៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៧. គម្រោងនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី១

## រំលឹកទ្រឹស្តី និងការសិក្សាពាក់ព័ន្ធ


១.១ ស្ថានភាពទូទៅនៃធនាគារពាណិជ្ជ ........ ៥

១.១.១. ប្រវត្តិនៃការកកើតធនាគារ ........ ៥

១.១.២. និយមន័យ ........ ៨

១.១.៣. មុខងាររបស់ធនាគារពាណិជ្ជ ........ ៩

១.១.៤. ដើមទុនអប្បបរមា និង ប្រាក់បំរុងកាតព្វកិច្ច ........ ៩

១.២. ការគ្រប់គ្រងឥណទានជាអ្វី? ........ ៩

១.២.១. និយមន័យឥណទាន ........ ៩

១.៣. មុខងារឥណទាន ........ ១០

១.៤ គោលការណ៍នៃការផ្តល់ឥណទាន ........ ១០

១.៤.១. គោលការណ៍ឱ្យខ្ចីដោយសងវិញទាំងដើមទាំងការប្រាក់ ........ ១០

១.៤.២. គោលការឱ្យខ្ចីដោយមានការធានា ........ ១១

១.៥. នីតិវិធីនិងគំរូនៃការផ្តល់ឥណទាន ........ ១២

១.៥.១. នីតិវិធីឥណទាន ........................................................................................................ ១៣
១.៥.២. ការវាយតម្លៃឥណទាន5C’s................................................................................................ ១៤
១.៥.៣. ការវាយតម្លៃឥណទានតាម3R’s ........................................................................................ ១៦
១.៥.៤. ផ្នែកប្រតិបត្តិការ និងការគ្រប់គ្រងឥណទាន...................................................................... ១៦
១.៦. ការគ្រប់គ្រងឥណទាន........................................................................................................ ១៧
១.៧. ប្រភេទការប្រាក់ ................................................................................................................ ១៧

## ជំពូកទី២

## ស្ថានភាពទូទៅរបស់ធនាគារ កាណាឌីយ៉ា ក.អ

២.១. ប្រវត្តិសង្ខេបរបស់ធនាគារកាណាឌីយ៉ា ក.អ ...................................................................... ១៨
២.២. ឈ្មោះផ្លាកសញ្ញានិងទីតាំងភូមិសាស្ត្ររបស់ធនាគារ ........................................................... ១៨
២.៣. បេសកម្ម និង គោលដៅរបស់ធនាគារកាណាឌីយ៉ា ក.អ........................................................ ១៩
២.៤. ទស្សនៈរបស់ធនាគារកាណាឌីយ៉ា ក.អ ............................................................................ ២០
២.៥. ដើមទុន និង ចំណែកហ៊ុន របស់ធនាគារកាណាឌីយ៉ា ក.អ..................................................... ២០
២.៦. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារកាណាឌីយ៉ា ក.អ ........................................................... ២១
២.៧. ទំហំឥណទានខ្នាតតូច (Small Loan)................................................................................ ២១
២.៧.១. ឥណទានខ្នាតតូច........................................................................................................ ២១
២.៧.២. ប្រភេទរូបិយប័ណ្ណ និងទំហំឥណទាន............................................................................... ២១
២.៧.៣. ប្រភេទរូបិយប័ណ្ណ និងតំបន់ប្រតិបត្តិការ ........................................................................ ២២
២.៧.៤. ការកំណត់ទំហំឥណទានសម្រាប់អតិថិជនម្នាក់ៗ................................................................ ២២
២.៧.៥. រយៈពេលខ្ចី និងអត្រាការប្រាក់ .................................................................................... ២២
២.៧.៦. សោហ៊ុយឥណទាន....................................................................................................... ២៣
២.៧.៧. កម្រិតនៃការបញ្ជាក់កិច្ចសន្យា ...................................................................................... ២៣
២.៨. ទំហំឥណទានខ្នាតមធ្យម(Medium Loan)........................................................................ ២៣
២.៨.១. ឥណទានខ្នាតមធ្យម...................................................................................................... ២៣
២.៨.២. ប្រភេទរូបិយប័ណ្ណ និងទំហំឥណទាន ............................................................................. ២៣
២.៨.៣. ប្រភេទរូបិយប័ណ្ណ និងតំបន់ប្រតិបត្តិការ........................................................................ ២៤
២.៨.៤. ការកំណត់ទំហំឥណទានសម្រាប់អតិថិជនម្នាក់ៗ................................................................ ២៤
២.៨.៥. រយៈពេលខ្ចី និងអត្រាការប្រាក់ .................................................................................... ២៤

២.៨.៦. សោហ៊ុយឥណទាន ........ ២៥
២.៨.៧. កម្រិតនៃការបញ្ជាក់កិច្ចសន្យា ........ ២៥
២.៩. សេវាកម្មរបស់ធនាគារកាណាឌីយ៉ា ក.អ ........ ២៥

## ជំពូកទី៣

## គោលការណ៍ប្រតិបត្តិការឥណទានខ្នាតតូច និង មធ្យម

៣.១. ប្រតិបត្តិការឥណទានរបស់ធនាគារកាណាឌីយ៉ា ក.អ ........ ២៩
៣.២. ឥណទានខ្នាតតូច និង មធ្យម ........ ២៩
៣.២.១. អតិថិជនគោលដៅ ........ ២៩
៣.២.២. លក្ខខណ្ឌក្នុងការផ្តល់ឥណទាន ........ ៣០
៣.៣.នីតិវិធីក្នុងការផ្តល់ឥណទានខ្នាតតូច និងមធ្យម ........ ៣០
៣.៣.១. ការដាក់ពាក្យសុំចុះឈ្មោះប្រើប្រាស់សេវាកម្មឥណទាន ........ ៣០
៣.៣.២. ការចុះវាយតម្លៃ និងសិក្សាពីអតិថិជន ........ ៣១
៣.៣.៣. ការចរចារអត្រាការប្រាក់ និងរយៈពេលសងត្រលប់ ........ ៣២
៣.៣.៤. ការប្រជុំសម្រេចឥណទានស្របតាមការវាយតម្លៃ ........ ៣២
៣.៣.៥. ការផ្តល់ព័ត៌មានក្រោយការអនុម័ត ........ ៣២
៣.៣.៦. ការធ្វើកិច្ចសន្យាឥណទាន ធ្វើប្រាតិភោគទ្រព្យបញ្ចាំ និងផ្តល់ប្រាក់កម្ចី ........ ៣៣
៣.៤. ដំណើរការបង់សងត្រឡប់ ........ ៣៣
៣.៤.១. របៀបគិតប្រាក់អនាគតរួមទាំងការប្រាក់ ........ ៣៤
៣.៤.២. របៀបសងការប្រាក់ថេរ ........ ៣៤
៣.៤.៣. ការសងរំលស់ប្រាក់ដើម និងការប្រាក់ ........ ៣៥
៣.៤.៤. ការសងរំលស់ប្រាក់ដើម និងប្រាក់ថេរ (Flat Amortization) ........ ៣៥
៣.៥. ការវាយតម្លៃឥណទាន5C's ........ ៣៦
៣.៥.១. ចរិតលក្ខណៈ (Character) ........ ៣៦
៣.៥.២. ដើមទុន (Capital) ........ ៣៦
៣.៥.៣. សមត្ថភាព (Capacity) ........ ៣៦
៣.៥.៤. ទ្រព្យធានា (Collateral) ........ ៣៧
៣.៥.៥. លក្ខខណ្ឌ (Conditions) ........ ៣៧
៣.៦. លក្ខខណ្ឌកំណត់ទំហំឥណទាន និងកម្រិតសុវត្ថិភាព ........ ៣៨

៣.៦.១. ការកំណត់ទំហំឥណទាន.....................................................................................................៣៨
៣.៦.២. កម្រិតសុវត្ថិភាព..........................................................................................................៣៨
៣.៧. ការត្រួតពិនិត្យឥណទាន និងតាមដានឥណទាន .........................................................................៤០
៣.៧.១. ដំណើរការត្រួតពិនិត្យ....................................................................................................៤០
៣.៧.២. ប្រពន្ធ និងមធ្យោបាយនៃការត្រួតពិនិត្យឥណទាន ...........................................................៤០
៣.៧.៣. ការត្រួតពិនិត្យឥណទាន..................................................................................................៤១
៣.៧.៣.១. ការត្រួតពិនិត្យប្រចាំថ្ងៃ.............................................................................................៤១
៣.៧.៣.២. ការត្រួតពិនិត្យឥណទានតាមពេលកំណត់ (Periodic control)........៤១
៣.៨.ការវិភាគលើការសងត្រឡប់មកវិញនៃឥណទាន..........................................................................៤២
៣.៨.១. ការបង់ផ្តាច់មុនកាលកំណត់ ...........................................................................................៤២
៣.៨.២. ការផ្តល់ឥណទានបន្ថែម ..................................................................................................៤២
៣.៨.៣. ការខកខានសង និងការពិន័យ.........................................................................................៤៣
៣.៨.៤. ការផ្សព្វផ្សាយ ...............................................................................................................៤៤
៣.៨.៥. ទីផ្សារគោលដៅ ..............................................................................................................៤៥
៣.៩. លក្ខណៈមនុស្សដែលអាចទទួលឥណទាន ....................................................................................៤៥
៣.១០. តម្រូវការ និងសុវត្ថិភាពឥណទាន.........................................................................................៤៦
៣.១០.១. តម្រូវការសម្រាប់អ្នកខ្ចី ..................................................................................................៤៦
៣.១០.២. តម្រូវការសម្រាប់ធានាសុវត្ថិភាពឥណទាន.......................................................................៤៧
៣.១០.៣. តម្រូវការឯកសារ ...........................................................................................................៤៧
៣.១០.៤. ភាគីខ្ចីប្រាក់ .................................................................................................................៤៨
៣.១១. ឯកសារឥណទាន ការទទួលខុសត្រូវ និងសិទ្ធិអនុម័តឥណទាន.................................................៤៨
៣.១១.១. ឯកសារឥណទាន...........................................................................................................៤៨
៣.១១.២. ការទទួលខុសត្រូវ និងសិទ្ធិអនុម័តឥណទាន ...................................................................៤៩
៣.១២. ការវិភាគ SWOTទៅលើការគ្រប់គ្រងឥណទានរបស់ធនាគារធនាគារកាណាឌីយ៉ា ក.អ៤៩
៣.១២.១. ចំណុចខ្លាំង(Strength) .................................................................................................. ៤៩
៣.១២.២. ចំណុចខ្សោយ(Weakness)..............................................................................................៥០
៣.១២.៣. ឱកាស(Opportunity) .....................................................................................................៥១
៣.១២.៤. ការគំរាមកំហែង(Threaten) ..........................................................................................៥១

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១ សេចក្តីសន្និដ្ឋាន ..... ៥២
២ ការផ្តល់អនុសាសន៍ ..... ៥២

## គន្ថនិទ្ទេស

## ឧបសម្ព័ន្ធ

# បញ្ជីតារាង

**ទំព័រ**

តារាងទី២.១ រូបិយប័ណ្ណដុល្លារ និងទំហំឥណទាន...........................................................២២

តារាងទី២.២ ប្រភេទរូបិយប័ណ្ណ និងតំបន់ប្រតិបត្តិការ .......................................................២២

តារាងទី២.៣ រយៈពេលខ្ចី និងអត្រាការប្រាក់.....................................................................២២

តារាងទី២.៤ រូបិយប័ណ្ណដុល្លារ និងទំហំឥណទាន...........................................................២៤

តារាងទី២.៥ ប្រភេទរូបិយប័ណ្ណ និងតំបន់ប្រតិបត្តិការ .......................................................២៤

តារាងទី២.៦ រយៈពេលខ្ចី និងអត្រាការប្រាក់ ....................................................................២៤

តារាងទី៣.១ តម្រូវការឯកសារ.........................................................................................៤៧

# បញ្ជីរូបភាព

**ទំព័រ**

រូបភាពទី១.១ ការធានាចេញសងដោយភាគីទីបី ............................................................ ១២

រូបភាពទី២.១ ផ្លាកសញ្ញារបស់ធនាគារកាណាឌីយ៉ា ក.អ .................................................... ១៩

រូបភាពទី២.២ រចនាសម្ព័ន្ធការគ្រប់គ្រងរបស់ធនាគារកាណាឌីយ៉ា ក.អ ................................ ២១

# បញ្ជីអក្សរកាត់

| | |
|---|---|
| 5C's | : Character, Capacity, Collateral, Condition, Capital. |
| 3R's | : Right person, Right Time, Right Amount. |
| MIS | : Management Information System |
| BBG | : Business Banking Group |
| SME | : Small and Medium Enterprises |
| CEO | : Chief Executive Officer |

REALTOR : -Right collateral

-Estimated value of collateral
-Ability to sell collateral Location of collateral
-Type of collateral
-Ownership
-Risk of collateral

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ពាក្យស្នើសុំឥណទាន

ឧបសម្ព័ន្ធទី២៖ របាយការណ៍វាយតម្លៃឥណទាន

ឧបសម្ព័ន្ធទី៣៖ លិខិតបញ្ជាក់ការយល់ព្រម

ឧបសម្ព័ន្ធទី៤៖ កិច្ចសន្យាដាក់បញ្ចាំ

# សេចក្តីផ្តើម

បច្ចុប្បន្ននេះនៅក្នុងប្រទេសកម្ពុជាកំពុងមានការរីកចំរើន ដោយសារតែស្ថេរភាពនយោបាយ និងគោលនយោបាយមានលក្ខណៈល្អប្រសើរ ជាពិសេសរដ្ឋាភិបាលបានបើកចំហរទីផ្សារដែលធ្វើអោយមានអ្នកវិនិយោគច្រើនមកកាន់ប្រទេសកម្ពុជាដើម្បីធ្វើការវិនិយោគ ដែលជាការលើស្ទួយដល់សេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស។ មិនត្រឹមតែការវិនិយោគនោះទេក្នុងនោះវិស័យហិរញ្ញវត្ថុក៏រាជរដ្ឋាភិបាលបានមើលឃើញថា អាចជួយអោយសេដ្ឋកិច្ចប្រទេសមានការរីកចំរើនផងដែររាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ ដោយមានការបង្កើតអោយមាននូវធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងទិសដៅដើម្បីលើកស្ទួយ និងកាត់បន្ថយភាពក្រីក្រប្រជាជនក្នុងប្រទេសដែលបានផ្តល់ការងារជាច្រើន ជូនប្រជាជនកម្ពុជា ដែលជាការកាត់បន្ថយចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសជាច្រើនគួរឲ្យកត់សម្គាល់។ បច្ចុប្បន្នស្ថាប័នហិរញ្ញវត្ថុនានាបានផ្តល់នូវសេវាកម្មជាច្រើនដូចជា សេវាឥណទាន សេវាប្រាក់បញ្ញើ-សន្សំ និងប្រភេទសេវាជាច្រើនទៀត។ ក្នុងនោះដែរឥណទាន គឺជាសេវាមួយដែលមានសារៈសំខាន់ក្នុងការជួយឲ្យសេដ្ឋកិច្ចមានភាពល្អប្រសើរឡើង។ ដោយផ្តល់ឱកាសអោយប្រជាជនដែលមានការខ្វះខាតដើមទុន ហើយចង់ពង្រីកអាជីវកម្មរបស់ខ្លួនគឺទទួលបានឥណទានដើម្បីយកទៅពង្រីកអាជីវកម្មរបស់ពួកគេ។

ដោយសារមានតម្រូវការចាំបាច់នូវឥណទាន ធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ជាច្រើនបានធ្វើប្រតិបត្តិការយ៉ាងសកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្លើយតបនូវតម្រូវការចាំបាច់របស់ប្រជាជន។ ក្នុងនោះរួមមានធនាគារកាណាឌីយ៉ា ក.អ ដែលជាធនាគារធំមួយដែលបានរួមចំណែកជាមួយរដ្ឋាភិបាល ដោយជួយលើកស្ទួយជីវភាពរស់នៅប្រជាពលរដ្ឋ និងជាខឿនសេដ្ឋកិច្ចជាតិមានភាពកាន់តែប្រសើរឡើង។ ធនាគារកាណាឌីយ៉ា ក.អ បានខិតខំពង្រឹងនូវសកម្មភាពរបស់ខ្លួន ជាពិសេសទៅលើការផ្តត់ផ្គង់សេវាឥណទាន ឲ្យកាន់តែមានការរីកចម្រើនទៅមុខ រហូតទើបក្លាយជាធនាគារមួយដែលមានការឈានមុខគេមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជាព្រមទាំង បានផ្តល់សេវាកម្មហិរញ្ញវត្ថុល្អបំផុតដល់អតិថិជនគ្រប់មជ្ឈដ្ឋាន។

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

តាមរយៈការរៀបរាប់ខាងលើបានបង្ហាញឱ្យឃើញថា ឥណទានខ្នាតតូច និងមធ្យម គឺមានសារៈសំខាន់ និងផ្តល់នូវសារៈប្រយោជន៍យ៉ាងសំខាន់ដល់សេដ្ឋកិច្ច ក៏ដូចជាប្រទេសជាតិទាំងមូល។ ដើម្បីធ្វើឱ្យការផ្តល់ឥណទានខ្នាតតូច និងមធ្យមមានប្រសិទ្ធភាពខ្ពស់នោះវាតម្រូវឱ្យមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពមួយ ដែលអាស្រ័យដោយការមើលឃើញពីតម្រូវការបែបនេះហើយ

បានជាក្រុមយើងខ្ញុំបានជ្រើសរើសយកប្រធានបទ "ការគ្រប់គ្រងឥណទានខ្នាតតូចនិងមធ្យម" ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ[1]។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីបង្កើតជាមូលដ្ឋានច្បាស់លាស់ក្នុងការឆ្លុះបញ្ចាំងអំពី ការគ្រប់គ្រងឥណទានខ្នាតតូចនិងមធ្យមក្រុមយើងខ្ញុំបានធ្វើការស្រាវជ្រាវដោយផ្តោតចំណោទបញ្ហាថា តើការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យមរបស់ធនាគារកាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាល មានដំណើរការដ៏ដូចជាការគ្រប់គ្រងយ៉ាងដូចម្តេចក្នុងការកំណត់គោលដៅរួមដែលទទួលបានភាពជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការចុះស្រាវជ្រាវនេះ គឺមានគោលបំណងស្វែងយល់ និងធ្វើការវិភាគលើសកម្មភាពនៃការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យមរបស់ធនាគារកាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាល ដោយរួមមានទាំងសកម្មភាពផ្តល់ និងការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម។ ចំនុចនោះរួមមាន៖

- សិក្សាអំពីស្ថានភាពទូទៅរបស់ធនាគារកាណាឌីយ៉ា ក.អ។
- សិក្សាអំពីគោលការណ៍នៃការផ្តល់ឥណទាន និងការគ្រប់គ្រងឥណទាន។
- សិក្សាអំពីវិធីសាស្ត្រនៃការវិភាគ និងសម្រេចផ្តល់ឥណទាន។
- សិក្សាអំពីវិធីសាស្ត្រនៃការរបញ្ចេញឥណទាន។
- សិក្សាអំពីដំណោះស្រាយឥណទានមានបញ្ហា។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាទៅលើ ការគ្រប់គ្រងឥណទានរបស់ធនាគារកាណាឌីយ៉ា ក.អ មានវិសាលភាពធំទូលាយតែដោយក្រុមយើងខ្ញុំមានការកំណត់ ដូចនេះក្រុមរបស់យើងខ្ញុំ បានធ្វើការស្រាវជ្រាវតែលើប្រធានបទ «ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម» ចន្លោះឆ្នាំ២០១៤ ដល់២០១៦ តែប៉ុណ្ណោះ។ដោយយកការចុះស្រាវជ្រាវនេះធ្វើឡើងដើម្បីឆ្លុះបញ្ចាំង អំពីសេវាកម្ម និងការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យមរបស់ធនាគារកាណាឌីយ៉ា ក.អ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវសរសេររបាយការណ៍កម្មសិក្សារបស់ក្រុមយើងខ្ញុំ បានសិក្សា និងប្រមូលនូវទិន្នន័យពីរប្រភេទជាគោលសំខាន់ៗរួមមាន ទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។

[1] របាយការណ៍កម្មសិក្សា អ៊ិច អ៊ីលីន សួង សារ៉ាត់, ការគ្រប់គ្រងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា

- ទិន្នន័យចម្បង គឺជាទិន្នន័យដែលទទួលតាមរយៈការស្រាវជ្រាវផ្ទាល់ពីធនាគារកាណាឌីយ៉ា ក.អ។
- ទិន្នន័យបន្ទាប់បន្សំ គឺជាទិន្នន័យដែលទទួលបានពីឯកសារមានស្រាប់ និងព័ត៌មានដែលទទួលបានពីមជ្ឈដ្ឋានខាងក្រៅ។

ទិន្នន័យចម្បង

- ធ្វើកម្មសិក្សាដោយផ្ទាល់នៅក្នុងធនាគារកាណាឌីយ៉ា ក.អ។
- ធ្វើការដកស្រង់ទិន្នន័យចេញពីសៀវភៅគោលការណ៍ និងនិតិវិធីនៃការផ្តល់ឥណទានខ្នាតតូច និងមធ្យមរបស់ធនាគារកាណាឌីយ៉ា ក.អ។
- ធ្វើការសាកសួរដោយផ្ទាល់ជាមួយនឹងប្រធាន និងភ្នាក់ងារឥណទាន។
- ចូលរួមសកម្មភាពអនុវត្តន៍ការងារជាក់ស្តែងជាមួយភ្នាក់ងារឥណទាន។

ទិន្នន័យបន្ទាប់បន្សំ

- ទទួលបានតាមរយៈសាស្ត្រាចារ្យណែនាំ។
- ទទួលបានតាមរយៈការស្រាវជ្រាវ នៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ទទួលបានពីការស្រាវជ្រាវតាមគេហទំព័ររបស់ធនាគារកាណាឌីយ៉ា ក.អ និងគេហទំព័រផ្សេងៗ។

## ៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺសិក្សាទៅលើទ្រឹស្តី និងការចុះសិក្សាស្រាវជ្រាវដោយផ្ទាល់ពីធនាគារ កាណាឌីយ៉ា ក.អ សាខាកណ្តាល។

ប្រធានបទ "ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម" បានផ្តល់អត្ថប្រយោជន៍ជាច្រើនដូចខាងក្រោម៖

- ចំពោះធនាគារ
- ជាឯកសារដែលបង្ហាញពីចំនុចខ្វះខាត។
- ធនាគារអាចប្រើឯកសារជាគ្រឹះមូលដ្ឋានក្នុងការអភិវឌ្ឍន៍ និងរៀបចំផែនការសម្រាប់ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យមនាពេលអនាគត។
- ចំពោះនិស្សិត
- បានផ្តល់ឯកសារសម្រាប់និស្សិតជំនាន់ក្រោយៗ ដើម្បីយល់ដឹងពី ដំណើរការនៃការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យមនៅលើវិស័យធនាគារ។

- ជាឯកសារសម្រាប់បំពេញចំនេះដឹងដែលបានផ្សារភ្ជាប់ជាមួយទ្រឹស្តី។
- ជាឯកសារសម្រាប់ជំនួយដល់និស្សិតជំនាន់ក្រោយ ក្នុងការសរសេរសារណាបញ្ចប់ឆ្នាំសិក្សា។

## ៧. គម្រោងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះក្រុមយើងខ្ញុំ បានបែងចែកអត្ថបទរបស់យើងជា ៦ដំណាក់កាលធំៗ ដោយក្នុងនោះរួមមាន៖

- ដំណាក់កាលទី១៖ សេចក្តីផ្តើមក្នុងនោះ យើងនឹងលើកឡើងពីទស្សនៈមួយចំនួនដែលជាដំបូងមានលក្ខណៈជាទូទៅ ក្រោយពីនោះ នឹងក្លាយជាទស្សនៈរួមដែលពាក់ព័ន្ធជាមួយប្រធានបទ។ បន្ទាប់មកយើងធ្វើការសរុបបញ្ហារួម ដើម្បីឈានទៅរកគោលបំណងក្នុងការកំណត់ពីទំហំដែនកំណត់ និងវិធីសាស្ត្រនៃការស្រាវជ្រាវ។
- ដំណាក់កាលទី២៖ នៅក្នុងផ្នែកនេះក្រុមយើងបានធ្វើការរំលឹកទ្រឹស្តីសំខាន់ៗមួយចំនួនដែលមានជាចំណុចទាក់ទងនឹងការសិក្សាស្រាវជ្រាវមកបង្ហាញជាជំនួយក្នុងការសរសេររបាយការណ៍។
- ដំណាក់កាលទី៣៖ នៅក្នុងផ្នែកនេះយើងខ្ញុំបានធ្វើការសិក្សា ទៅលើស្ថានភាពទូទៅរបស់ធនាគារកាណាឌីយ៉ា ក.អ។
- ដំណាក់កាលទី៤៖ វិភាគទៅលើស្ថានភាពទូទៅស្តីអំពីការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យមរបស់ធនាគារកាណាឌីយ៉ា ក.អ សាខាកណ្តាល។
- ដំណាក់កាលទី៥៖ ធ្វើការវិភាគលទ្ធផលនៃការសិក្សាស្រាវជ្រាវដែលក្នុងនោះរួមមានដូចជាចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង។
- ដំណាក់កាលទី៦៖ ធ្វើការសន្និដ្ឋាន និងការផ្តល់អនុសាសន៍ទៅលើចំណុចអសកម្មមួយចំនួនដែលក្រុមយើងខ្ញុំបានសិក្សា។

# ជំពូកទី ១
# រំលឹកទ្រឹស្តី និងការសិក្សាពាក់ព័ន្ធ

## ១.១. ស្ថានភាពទូទៅនៃធនាគារពាណិជ្ជ

### ១.១.១. ប្រវត្តិនៃការកកើតធនាគារ (History of Commercial Bank)

ដំបូងធនាគារកើតឡើងពីពាណិជ្ជករនៅសម័យបូរាណ[2] ដែលបង្កើតអោយមានប្រាក់កម្ចីសំរាប់កសិករ និងពាណិជ្ជករដែលបានដឹកជញ្ជូនទំនិញ ពីទីក្រុងមួយទៅទីក្រុងមួយ។ កំណត់ហេតុរបស់សកម្មភាពបែបនេះមានមកតាំងពី ២០០០ឆ្នាំមុន គ.ស នៅតំបន់Assyria និងBabylonia។ បន្ទាប់មកប្រទេសក្រិចសម័យបុរាណ និងសម័យរ៉ូម៉ាំង ឬចក្រភពរ៉ូម អ្នកផ្តល់កម្ចីដែលមានមូលដ្ឋាននៅព្រះវិហារ បានបង្កើតប្រាក់កម្ចីហើយក៏បានបន្ថែមការបង្កើតថ្មីសំខាន់ៗចំនួនពីរ គឺការទទួលដាក់ប្រាក់ និងការដូរ រូបិយវត្ថុ។ នៅសម័យនោះក៏មានភស្តុតាងស្រដៀងគ្នានៃការអភិវឌ្ឍន៍ឯករាជ្យនៃការខ្ចីប្រាក់នៅសម័យចិនបូរាណ និងសម័យឥណ្ឌាបូរាណ ។

នៅក្នុងគំនិតថ្មី ធនាគារត្រូវបានរកឃើញមជ្ឈឹមសម័យ និងដើមសម័យនៃការចំរើនរបស់អ៊ីតាលីនៅក្នុងទីក្រុង អ្នកមាននៅភាគខាងជើងដូចជា Florence , Venice និងGenoa។ គ្រួសាររបស់ Bardi និង Peruzzi បានគ្រប់គ្រង ធនាគារនៅក្នុងសតវត្សទី១៤ នៃតំបន់ Florence និងបង្កើតសាខានៅក្នុងផ្នែកផ្សេងៗទៀតនៅទ្វីបអ៊ឺរុប។ ប្រហែលជាធនាគារ Bardici ជាធនាគារដែលល្បីជាងគេរបស់អ៊ីតាលី ដែលបានបង្កើតឡើងដោយ Giovanni Madici នៅឆ្នាំ ១៣៩៧។

ការរីកចំរើនរបស់ធនាគារបានរីករាលដាលពេញទ្វីបអឺរ៉ុប ហើយមានការបង្កើតឡើងនូវធនាគារថ្មីសំខាន់ៗមួយចំនួនទៀត ត្រូវបានបង្កើតឡើងនៅទីក្រុង Amsterdam នៅសម័យសាធារណៈរដ្ឋហូឡង់ក្នុងសតវត្សទី១៧។ អំឡុងសតវត្សទី២០ ការអភិវឌ្ឍន៍ក្នុងផ្នែកទូរគមនាគមន៍និងកុំព្យូទ័របានផ្តល់ជាលទ្ធផលយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរនៃការរៀបចំធនាគារ ហើយក៏មានការធ្វើអោយកើនឡើងទាំងទំហំ និងការប្រើប្រាស់តាមតំបន់នៅចុងឆ្នាំ២០០០ វិបត្តិហិរញ្ញវត្ថុ បានធ្វើអោយបរាជ័យរបស់ធនាគារ មួយចំនួនដែលរួមមានទាំងធនាគារធំៗរបស់ពិភពលោក។

**ទំរង់ដំបូងបង្អស់ របស់ធនាគារ**

ប្រវត្តិរបស់ធនាគារ មានទំនាក់យ៉ាងជិតស្និទ្ធទៅនឹងប្រវត្តិរូបិយវត្ថុ ប៉ុន្តែប្រវត្តិរបស់ធនាគារប្រហែលជាមានមុនការបង្កើតរូបិយវត្ថុ។ ការផ្ញើរប្រាក់ដំបូងរួមមានការផ្ញើរគ្រាប់ធញ្ញជាតិ ហើយបន្ទាប់មកមានជាទំនិញដែលរួមមាន សត្វ ពាហនៈ សំភារៈកសិកម្ម ហើយរួមទាំងវត្ថុមានតំលៃ

[2] ងួនហេង (២០១៤) *រូបិយវត្ថុ និងធនាគារ* ទំព័រទី ៧៩ ដល់ ៨២

ដូចជាមាស។ ព្រះវិហារ និងវាំង គឺជាកន្លែងសុវត្ថិភាពបំផុតសំរាប់រក្សាទុកមាសដែលពួកគេសាង សង់ឡើងយ៉ាងរឹងមាំ។ ដោយសារតែព្រះវិហារជាកន្លែងសាសនា បានបង្ហាញភាពភ័យខ្លាចដល់ជន ខិលខូច។

**Mesootamia**

កំណត់ហេតុអំពីប្រាក់កម្ចីមានតាំងពីសតវត្សទី២មុន គ.ស ក្នុងតំបន់ Babylon ដែលបាន បង្កើតឡើងដោយអាចារ្យ ឬព្រះសង្ឃទៅអោយពួកពាណិជ្ជករ។ ត្រឹមពេលនៃ Hammurabi’s Code រហូតដល់ Ca ក្នុងឆ្នាំ១៧៦០មុន គ.ស ធនាគារមានលក្ខណៈគ្រប់គ្រាន់ ដែលអភិវឌ្ឍទៅដល់ការ កំណត់ច្បាប់ គ្រប់គ្រងការរៀបចំធនាគារ។

**អេហ្ស៊ីប**

នៅក្នុងប្រទេសអេហ្ស៊ីប កាលពីមុនគ្រាប់ធញ្ញជាតិត្រូវបានប្រើប្រាស់ក្នុងទំរង់ជារូបិយវត្ថុរួម ទាំងលោហៈធាតុមានតំលៃ ហើយនឹងជម្រុករបស់រដ្ឋដែលមានមុខងារជាធនាគារ។ ពេលដែល ប្រទេស អេហ្ស៊ីបធ្លាក់ចូលការគ្រប់គ្រងរបស់ក្រិច Ptolemies ( ៣៣២~៣០០ឆ្នាំ មុនគ.ស ) រដ្ឋា ភិបាលបានប្រែក្លាយអោយទៅជាប្រព័ន្ធធនាគារធញ្ញជាតិ។ ដែលមានទីតាំងនៅ Alexandria ដែលជា កន្លែងគ្រប់គណនីធនាគារទាំងអស់ត្រូវបានកត់ត្រា។ ប្រព័ន្ធធនាគារមាននេះមានមុខងារជាប្រព័ន្ធ ឥណទានពាណិជ្ជកម្ម ដែលក្នុងនោះរាល់ការចំណាយ ត្រូវបានផ្ទេរពីគណនីមួយទៅគណនីមួយ ផ្សេងទៀត ដោយគ្មានការបញ្ជូនប្រាក់។ នៅចុងសតវត្សទី១៣ មុនគ.ស កោះAegean ដែលជាកោះ គ្មានជីជាតិនៃតំបន់ Delos ត្រូវបានគេស្គាល់ដោយសារកំផែ និងប្រាសាទល្បីល្បាញរបស់ Apollo បានក្លាយទៅជាមជ្ឈមណ្ឌលធនាគារដ៏សំខាន់។ នៅក្នុងប្រទេសអេហ្ស៊ីប ប្រតិបត្តិការសាច់ប្រាក់ ត្រូវបានជំនួសដោយវិក័យប័ត្រឥណទាន ហើយការចំណាយត្រូវបានធ្វើឡើង ដោយផ្អែកទៅតាម ការបញ្ជាជាមួយនឹងគណនីអតិថិជននីមួយៗ។ ដោយសារជ័យជំនះរបស់គូប្រជែង Carthage and Corinth ដោយជនជាតិ Delos មានសារៈសំខាន់ឡើងៗ។ វាជាការពិតណាស់ដែលធនាគារ Delos គួរ ដែរក្លាយទៅជាគំរូ ដែលធនាគាររ៉ូមយកតម្រាប់តាម។

**ឥណ្ឌា**

ក្នុងសម័យបូរាណកំឡុងរាជវង្ស Maurya (៣២១-១៨៥) មុនគ.ស ការបង្គាប់មួយទៀតត្រូវ បានគេ ហៅ Adesha ត្រូវបានប្រើប្រាស់ដែលជាបញ្ជារបស់ធនាគារវិក អោយគាត់បង់ក្រដាសប្រាក់ ទៅអោយតតិយជន ដែលឆ្លើយតបទៅនឹងនិយមន័យនៃវិក័យប័ត្របង់ប្រាក់ ដូចយើងប្រើសព្វថ្ងៃ នេះ។

**ចិន**

ចិនបូរាណចាប់ផ្តើមពីរាជ្យវង្ស Quin (២២១-២០៦) មុនគ.ស រូបិយប័ណ្ណចិនបានរីកចំរើន ដោយសារការបង្ហាញកាក់ស្តង់ដារ ដែលធ្វើអោយមានភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មក្នុង ប្រទេស ហើយនាមអោយមានការអភិវឌ្ឍន៍ទៅជាក្រដាសឥណទាន។ ក្រដាសនេះបានចេញដោយ ពាណិជ្ជករដែលរកស៊ីតាមមធ្យោបាយជាច្រើន ដែលសព្វថ្ងៃនេះយើងយល់ថាដូចជាធនាគារ ។

**ក្រិច**

នៅប្រទេសក្រិចសម័យបូរាណមានសេវាកម្មបញ្ញើរបស់ទ្រព្យដែលមានតំលៃ ទុកក្នុងឃ្លាំង ដែលមានសុវត្ថិភាព ( Safe-deposit valts )។ សម័យនោះក្រិចក៏បានបង្កើតប្រាក់កាស និងប្រព័ន្ធ ឥណទានផងដែរ។ ចំពោះចក្រភពរ៉ូមវិញមានការរីកចំរើន វិស័យធនាគារយ៉ាងខ្លាំងដែរ ហើយ ធនាគារនេះមានសេវាកម្មប្រាក់ បញ្ញើ កំចី និងទិញវត្ថុបញ្ចាំ។ ហើយប្រព័ន្ធធនាគារនៅអ៊ឺរ៉ុបមានការ រីកចំរើនយ៉ាងខ្លាំងដែរនៅពេលនោះ។ ប៉ុន្តែបន្ទាប់ពីមានការដួលរលំនៃចក្រភពរ៉ូម ប្រព័ន្ធធនាគារ នៅអឺរ៉ុបមានការធ្លាក់ចុះវិញ។

នៅសតវត្សទី១៣ មានការរីកចំរើនខាងពាណិជ្ជកម្ម អ៊ីតាលីបានពង្រីកប្រព័ន្ធធនាគារឡើង វិញ។ អ្នកប្តូរប្រាក់បានកែរប្រែប្រព័ន្ធប្តូរប្រាក់ អោយមានទាំងអត្រាប្តូរប្រាក់ជាតិ និងអន្តរជាតិ។ បន្ទាប់មកទៀតពាណិជ្ជករមានតម្រូវការផ្សេងៗទៀត ដូចជាសេវាកម្មកំចីរបស់ពាណិជ្ជកម្មជាដើម ហើយធនាគារបានពង្រីកសេវាកម្មរបស់ខ្លួនជាបន្តបន្ទាប់។ ធនាគារដំបូងបង្អស់ដែលបានផ្តល់ សេវាកម្មដូចសព្វថ្ងៃនេះ គឺធនាគារក្នុងតំបន់ Babylon នៃប្រទេស Mesootamia ធនាគារនេះកើត ឡើងនៅឆ្នាំ១៩០១ ដែលផ្តល់សេវាកម្មបញ្ញើប្តូរប្រាក់ និងផ្តល់កំចី ហើយធនាគារនេះជាធនាគារ ដែលបង្កើតមូលប្បប័ត្រមុនគេ។ បន្ទាប់មកមានធនាគារបីផ្សេងទៀតបានកើតជាបន្តបន្ទាប់គឺ ធនាគារ The Bank of Venice (1587) The bank of Amsterdam (1609) និង The Bank of Hamburg (1619)។

ធនាគារប្រទេសបារាំង បង្កើតឡើងដោយ ណាប៉ូឡេអុងក្នុងឆ្នាំ ១៨០០។ នៅពាក់កណ្តាល សតវត្សទី១៨ ធនាគារនេះបានក្លាយជាស្ថាប័នហិរញ្ញវត្ថុ ដែលមានឥទ្ធិពលបំផុត។ នៅអាល្លឺម៉ង់ ប្រព័ន្ធធនាគារមានការអភិវឌ្ឍន៍ជាលំដាប់ ហើយនៅពាក់កណ្តាលសតវត្សទី១៩មានការបង្កើតភាគ ហ៊ុនមួយ ចំនួនដ៏រឹងមាំទៀតផង។

ប្រព័ន្ធធនាគារនៅក្នុងប្រទេសអង់គ្លេសបានកើតឡើងដោយជាងមាស (London goldsmiths) ក្នុងសតវត្សទី១៦។ អ្នកទាំងនោះបានផ្តល់កម្ចី និងទទួលរក្សាទុកជាវត្ថុមានតំលៃផ្សេងៗដោយគិត ជាថ្លៃសេវា។ នៅសតវត្សទី១៧ ជាងមាសដែលជាម្ចាស់ធនាគារទាំងនោះបានបង្កើតជាការបង្វិល សាច់ប្រាក់ ដោយយកប្រាក់ដែលអតិថិជនផ្ញើរទៅផ្តល់ជាកម្ចី។ អតិថិជនបានយកមាសទៅផ្ញើរនៅ

ជាងមាស ដោយទទួលមកវិញនូវវិក័យប័ត្រដែលបញ្ជាក់ពីកម្មសិទ្ធរបស់ខ្លួន។ វិក័យប័ត្រទាំងនោះអាចប្រើជាលុយបានព្រោះវាបានបញ្ជាក់អំពីចំនួនមាសដែលគេមាន។ បន្ទាប់មកជាងមាសទាំងនោះបានបោះវិក័យប័ត្របន្ថែម ដោយប្រើមាសដែលអតិថិជនដែលបានមកផ្ញើរ។ ប្រតិបត្តិការនេះអាចដំណើរការបានយូរអង្វែង ប្រសិនបើអតិថិជនទាំងនោះមិនមកដកយកមាសភ្លាមៗ។ ការធ្វើបែបនេះធ្វើអោយវិក័យប័ត្រកើនឡើង ច្រើនជាចំនួនមាសដែលមានដោយសារព្រឹត្តិការណ៍បែបនេះហើយបានធ្វើអោយធនាគាររិកចាប់ផ្តើមបង្កើតក្រដាសប្រាក់។

ធនាគារដំបូងនៅសហរដ្ឋអាមេរិចកើតឡើងនៅសតវត្សទី១៨ ដើម្បីផ្តល់រូបិយវត្ថុដល់ពួកអាណានិគមដែលត្រូវការប្តូរប្រាក់។ ដំបូងឡើយធនាគារ ផ្តល់សេវាកម្ចី និងចេញវិក័យប័ត្រសំរាប់ដាក់ប្រាក់នៅធនាគារតែប៉ុណ្ណោះ គណនីមូលប័ត្រកើតឡើងនៅពាក់កណ្តាលសតវត្សទី១៩ បន្ទាប់មកទៀតសេវាកម្ម សេវាថ្មីៗរបស់ធនាគារបានកើតឡើងជាបន្តបន្ទាប់តាមរយៈប្រព័ន្ធធនាគាររបស់រដ្ឋ។

ដោយសារការរីកចំរើនខាងសេដ្ឋកិច្ច និងបច្ចេកទេសធ្វើអោយប្រតិបត្តិការរបស់ធនាគារកាន់តែរីកចំរើនដោយផ្តល់កម្ចីរយៈពេលវែងផ្តល់កំចីរយៈពេលមធ្យមសំរាប់អតិជន និងអ្នកវិនិយោគទុន ពាណិជ្ជករ។ល។ ហើយបង្កើតឡើងនូវសេវាកម្ម ប្រាក់បញ្ញើគ្រប់ប្រភេទទៅតាមតំរូវការរបស់អតិថិជនទាំងឡាយ។

**១.១.២. និយមន័យ**

ធនាគារពាណិជ្ជ គឺជាស្ថាប័នហិរញ្ញវត្ថុដែលបើកសេវាធំទូលាយជាងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត វាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រតិបត្តិការខ្លួនជាអន្តរការី[3] រវាងអ្នកត្រូវការមូលធន ឬអ្នកខ្ចីប្រាក់ និងអ្នកដែលមាន មូលធនលើសផ្ញើរប្រាក់នៅធនាគារ។ ធនាគារបានបំពេញតួនាទីខ្លួនជាស្ថាប័នហិរញ្ញវត្ថុនៅពេលដែលធនាគារផ្ទេរប្រាក់ដែលបានមកពីការផ្ញើររបស់អតិថិជន ឬអង្គភាពពាណិជ្ជកម្មទៅអោយអ្នកដទៃ ដែលមានតំរូវការមូលធន ឬមានតំរូវការវិនិយោគ។

ធនាគារពាណិជ្ជ គឺជាអង្គភាពដែលស្វែងរកប្រាក់ចំណេញ ធនាគារពាណិជ្ជមានទ្រព្យសកម្ម និងបំណុលជាច្រើនប្រភេទ។

ធនាគារពាណិជ្ជជានីតិបុគ្គលដែលមានសម្បទា ពិសេសក្នុងការរើសយកប្រតិបត្តិការធនាគារជាមុខរបរប្រក្រតី។ ធនាគារពាណិជ្ជអនុវត្តន៍នូវសកម្មភាពរបស់វាមានដូចជា៖

[3] ងួនហេង (២០១៥) *រូបិយវត្ថុ និងធនាគារ* ទំព័រទី ៧៩

- ទទួលប្រាក់បញ្ញើពីសាធារណៈជនតាមរយៈការប្រមូលទុន ដែលនៅទំនេរនៅក្នុងសេដ្ឋកិច្ច។
- ផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណៈជនដោយមានកំរៃ និងទៅតាមមុខសញ្ញាដែលបានកំណត់ដោយនយោបាយរូបិយវត្ថុ។
- ប្រព្រឹត្តកម្ម និងការដាក់អោយអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ ជារូបិយវត្ថុ មូលប្បទានប័ត្រ ប័ណ្ណទាន លិខិតឥណទាន អោយមានដំណើរការរលូន និងមានប្រសិទ្ធិភាពសំរាប់បំរើសេចក្តីត្រូវការនៅក្នុងសេដ្ឋកិច្ច។

### **១.១.៣. មុខងាររបស់ធនាគារពាណិជ្ជ**

ធនាគារពាណិជ្ជស្ថិតនៅក្នុងស្ថាប័នហិរញ្ញវត្ថុ ដែលធ្វើប្រតិបត្តិការអ្វីដែលទាក់ទងទៅនឹងសាច់ប្រាក់ ដោយដើរតួជាអ្នកធ្វើនយោបាយប្រមូលប្រាក់បញ្ញើចំពោះអ្នកដែលមានប្រាក់ទំនេរ ដោយមិនដឹងយកទៅធ្វើអ្វី ឬក៏មិនចង់អោយអ្នកដែលមានប្រាក់ទំនេរ នោះយកប្រាក់ទុកក្រោមខ្នើយចោល ដែលជាហេតុធ្វើអោយដំណើរសាច់ប្រាក់នោះ មានការរាំងស្ទះក្នុងការធ្វើប្រតិបត្តិការផ្តល់កម្ចីដល់ប្រជាជន និងពាណិជ្ជករផ្សេងៗ ដែលមានតំរូវការវិនិយោគដើម្បីពង្រីកសហគ្រាស ឬឧស្សាហកម្ម។

### **១.១.៤. ដើមទុនអប្បបរមា និង ប្រាក់បំរុងកាតព្វកិច្ចរបស់ធនាគារពាណិជ្ជ**

ដើមទុនរបស់ធនាគារពាណិជ្ជអាស្រ័យលើច្បាប់ប្រទេសនីមួយៗកំណត់ ចំពោះប្រទេសកម្ពុជាវិញបច្ចុប្បន្ននេះធនាគារពាណិជ្ជមានដើមទុនអប្បបរមាចំនួន ១៥០.០០០.០០០.០០០រៀល។ ក្រោយពេលធនាគារពាណិជ្ជទទួលអាជ្ញាប័ណ្ណរួចមក ធនាគារពាណិជ្ជបានតំកល់ប្រាក់ធនាគារលើដើមទុនចំនួន១០% នៃដើមទុនចុះក្នុងលក្ខន្តិកៈនៅក្នុងគណនី ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។ តំកល់ប្រាក់បំរុងកាតព្វកិច្ចបញ្ញើជាប្រាក់រៀល ៨% ដោយគ្មានការប្រាក់និង ១២% ជារូបិប័ណ្ណបរទេស ក្នុងនោះ៨% ពុំមានការប្រាក់ និង៤% មានការប្រាក់[4] ដោយគិតតាមអត្រាការប្រាក់អន្តរធនាគារសឹង្ហបូរី 3/4(SIBOR) គិតមួយខែ។

## **១.២. ការគ្រប់គ្រងឥណទានជាអ្វី**?

### **១.២.១. និយមន័យឥណទាន**

ពាក្យថាឥណទានជាចង្កោមនៃពាក្យ: ឥណ+ទាន

[4] ប្រកាសលេខ ធ ៧-០៩-០២០ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៩ ប្រកាសស្តីពីការតំកល់ប្រាក់បំរុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ ធនាគារពាណិជ្ជ

ឥណៈ គឺមានន័យថាជំពាក់។

ទានៈ ជាការផ្ដល់ ឬក៏ឱ្យនូវបរិមាណអចលនទ្រព្យ ឬចលនទ្រព្យ។

ដូច្នេះឥណទានមានន័យថា ការផ្ដល់ឱ្យនូវបរិមាណអចលនទ្រព្យឬចលនទ្រព្យទៅឱ្យអ្នកសុំខ្ចីក្នុងរយៈពេលណាមួយជាក់លាក់។ យើងនិយាយម្យ៉ាងទៀតថា ឥណទានក្នុងន័យពាណិជ្ជកម្ម និងហិរញ្ញវត្ថុទាក់ទងប្រតិបត្តិការផ្ដល់ជាលុយ ឬទ្រព្យផ្សេងៗទៀតដោយសន្យានឹងសងត្រលប់មក ឥណទានគេអោយឈ្មោះថា "កូនបំណុល" ។

## ១.៣. មុខងារឥណទាន

ឥណទានមានមុខងារសំខាន់ៗដូចខាងក្រោម៖

- អាចឆ្លើយតបតាមតម្រូវការទុនរបស់ភ្នាក់ងារសេដ្ឋកិច្ច។
- ជួយជំរុញអោយមានស្ថេរភាពសេដ្ឋកិច្ច។
- ធ្វើអោយមានស្ថេរភាពថ្លៃ និងអំណាចទិញរូបិយវត្ថុ។
- ធ្វើអោយប្រតិបត្តិការទូទាត់អន្តរជាតិ និងមាននិន្នាការអតិផរណាល្អ។
- ធ្វើឱ្យអត្រានិកម្មភាពថយចុះ។

## ១.៤. គោលការណ៍នៃការផ្ដល់ឥណទាន

រាល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវអនុវត្តឱ្យបានស្របតាមនយោបាយឥណទានត្រឹមត្រូវប្រុងប្រយ័ត្នការប្រតិបត្តិជាទូទៅ និងនីតិវិធីក្នុងការផ្ដល់ឥណទាន ដែលត្រូវអនុម័តនិងពិនិត្យឡើងវិញ ដោយត្រឹមត្រូវពីគណៈគ្រប់គ្រង ឬក្រុមព្រឹក្សាភិបាល។

### ១.៤.១. គោលការណ៍ឱ្យខ្ចីដោយសងវិញទាំងដើមទាំងការប្រាក់

គោលការណ៍ឱ្យខ្ចីដោយសងវិញ ទាំងដើមទាំងការ គឺជាគោលការណ៍ឥណទានមួយ ដែលធ្វើឱ្យអ្នកខ្ចីត្រូវគិតគូរពីចំនួនដែលខ្លួនត្រូវខ្ចី និងប្រើប្រាស់កម្ចីដោយមានការប្រុងប្រយ័ត្ន។ គោលការណ៍ឥណទាននេះ គឺតម្រូវអោយអ្នកខ្ចីត្រូវសងត្រឡប់នូវចំនួនប្រាក់កម្ចីទាំងអស់ ដែលខ្លួនបានខ្ចីព្រមជាមួយការប្រាក់ដែលបានព្រមព្រៀងគ្នា ហើយនឹងសងទៅតាមពេលវេលា ដែលបានកំណត់ក្នុងកិច្ចសន្យា។

### ១.៤.២. គោលការណ៍ឱ្យខ្ចីដោយមានការធានា

គោលការណ៍នេះទោះបីខ្ទង់ប្រាក់ណាក៏ដោយ ដោយបើកអោយអង្គការអាជីវកម្មជានីតិបុគ្គល ឬជារូបវន្តបុគ្គល ត្រូវមានមូលដ្ឋានច្បាស់លាស់ក្នុងការធានាក្រោមរូបភាពជាច្រើនផ្សេងៗគ្នា ដូចជា ប្រាក់កម្ចីធានាដោយអចលនទ្រព្យ ត្រូវបានធានាចេញសងនៅពេល ដែលខកខានដោយភាគីទីបី។ ការអនុវត្តគោលការណ៍នេះ បង្កអោយមានលក្ខខណ្ឌឱ្យបានសមស្របរវាងប្រាក់ដែល

បើកឱ្យជាមួយតម្លៃទ្រព្យដែលដាក់ធានា។ ទ្រង់ទ្រាយធានាមានច្រើនរូបភាព និងសំបូរបែប អាស្រ័យទៅតាមការរីកចម្រើននៃទំនាក់ទំនងឥណទាននៅក្នុងប្រទេសនីមួយៗ ដែលគេបានជ្រើសរើសការធានាបែបណាមួយអោយសមនឹងប្រទេសរបស់ពួកគេ ឬអោយសមទៅនឹងភាពជាក់ស្តែងណាមួយ។

- **ឥណទានធានាដោយបុគ្គភាព**

ការផ្តល់ឥណទាន គឺយោងតាមជំនឿទុកចិត្តលើបុគ្គលដែលខ្ចីឥណទានតាមរយៈការវាយតម្លៃវិជ្ជមានទៅលើកេរ្តិ៍ឈ្មោះល្អ និងសម្ថភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីឥណទាន។ ចំពោះករណីនេះ ធនាគារតែងតែធ្វើការពិនិត្យយ៉ាងល្អិតល្អន់ណាស់។ ធនាគារអាចសាកសួរព័ត៌មានបន្ថែមផ្សេងៗ ដែលទាក់ទងរបស់សភាពាណិជ្ជកម្ម សេចក្តីប្រកាសរបស់អាជ្ញាធរមានសមត្ថកិច្ចអត្ថបទសារព័ត៌មានទស្សនាវដ្តី និងការស្រាវជ្រាវអង្កេតរបស់ធនាគារផ្ទាល់។

- **ឥណទានធានាដោយបុគ្គលភាព និងការធានាចេញសងដោយភាគីទីបី**

ការធានាចេញសងដោយភាគីទីបី គឺតម្រូវឱ្យភាគីទីបីជួយធានាខុសត្រូវក្នុងការបង់ប្រាក់ និងសងឥណទាន។ ក្នុងករណីនេះគេត្រូវធ្វើកិច្ចសន្យាពីរគឺ:

- ○ កិច្ចសន្យាឥណទានឥណទានដែលធ្វើឡើងរវាងអ្នកផ្តល់ និងអ្នកខ្ចីឥណទាន។
- ○ កិច្ចសន្យាធានាខុសត្រូវរវាងអ្នកផ្តល់ឥណទាន និងអ្នកជួយធានា។

ដោយយោងតាមទៅលើកិច្ចសន្យាខាងលើ ភាគីទីបី "អ្នកធានា" គឺជាអ្នកជំពាក់ប្រយោល (Secondary debtor) រីឯអ្នកខ្ចីឥណទានវិញ គឺជាអ្នកជំពាក់ផ្ទាល់ (Principal debtor)។ តាមធម្មតាអ្នកជំពាក់ប្រយោលត្រូវសងឥណទានឱ្យទៅធនាគារ កាលណាអ្នកជំពាក់ផ្ទាល់ពុំអាចបង់ប្រាក់បំណុលទាំងអស់ ឬចំនួនបាន។ ដើម្បីឱ្យអ្នកធានាបង់ប្រាក់បំណុល ធនាគារត្រូវបង្ហាញប្រាប់អ្នកធានាអំពីភាពបរាជ័យរបស់អ្នកជំពាក់នៅក្នុងការសងបំណុល។

**រូបភាពទី១.១ ការធានាចេញសងដោយភាគីទីបី**




ប្រភព:

- **ឥណទានធានាដោយចលនទ្រព្យ**

អ្នកខ្ចីឥណទានត្រូវផ្ទេរកម្មសិទ្ធិរបស់ខ្លួនដែលមានជាចលនវត្ថុដូចជា រថយន្ត ទំនិញ លោហ: និងត្បូងថ្មមានតម្លៃទៅឱ្យអ្នកផ្តល់ឥណទានទុនជាមធ្យោបាយសំរាប់ការកក់បញ្ចាំ។ អ្នកផ្តល់ឥណទានជាអ្នកទទួលសិទ្ធិ ឬម្ចាស់កម្មសិទ្ធិប្រយោលព្រោះធម្មតាគេគ្រាន់តែយកប័ណ្ណបញ្ជាក់សិទ្ធិទៅកក់បញ្ចាំគឺជាការគ្រប់គ្រាន់។ រីឯអ្នកខ្ចីឥណទានជាអ្នកកាន់កាប់កម្មសិទ្ធិ ព្រមទាំងមានសិទ្ធិប្រើប្រាស់នូវចលនវត្ថុដែលយកទៅបញ្ចាំនោះទៀតផង។ ប្រសិនណាបើអ្នកខ្ចីឥណទានគ្មានប្រាក់សងបំណុលអ្នកផ្តល់ឥណទានអាចយកកម្មសិទ្ធិនោះទៅលក់ ហើយធ្វើការដកហូតទឹកប្រាក់ដែលបានទទួលពីការលក់ចលនវត្ថុនោះក្នុងបរិមាណមួយដែលអ្នកខ្ចីឥណទានត្រូវសងបំណុល។ លទ្ធភាពប្រើប្រាស់ចលនវត្ថុដែលបានយកទៅកក់បញ្ចាំ អាចប្រព្រឹត្តទៅបានដោយមានកិច្ចសន្យាខ្ចីប្រើរវាងភាគីទាំងពីរ។

- **ឥណទានធានាដោយអចលនវត្ថុ**

អ្នកខ្ចីឥណទានត្រូវធ្វើកិច្ចសន្យាដាក់បញ្ចាំនូវអចលនវត្ថុរបស់ខ្លួនដែលមានដូចជា ដី ផ្ទះ អាគារ រោងចក្រជាមួយធនាគារ។ អ្នកខ្ចីឥណទានត្រូវធ្វើសេចក្តីបញ្ជាក់ថា ប្លង់អចលនវត្ថុដែលត្រូវយកមកបញ្ចាំ គឺមិនទាន់បានយកទៅដាក់បញ្ចាំ ឬនឹងមិនយកទៅដាក់បញ្ចាំនៅធនាគារណាមួយដើម្បីយកឥណទានឡើយ។ ចំពោះអាជ្ញាធរនៃស្ថាប័នរដ្ឋ ត្រូវចេញលិខិតធានាជាលាយលក្ខណ៍អក្សរក្នុងការខ្ចីឥណទាននោះក៏អាចជាការមួយគ្រប់គ្រាន់ដែរ ព្រោះអ្នកផ្តល់ឥណទានមានទំនុកចិត្តទៅលើ Borrowing potential និង Credit Worthiness ជាពិសេសទៅលើសមត្ថភាពហិរញ្ញវត្ថុរបស់ស្ថាប័នរដ្ឋ ដែលមានប្រភពមកពីចំណូលពន្ធដារ និងរដ្ឋាករ។

## ១.៥. នីតិវិធីក្នុងការផ្តល់ឥណទាន

គោលបំណងនៃការផ្តល់ឥណទាន គឺធ្វើយ៉ាងណាឱ្យកម្ចីនោះទទួលបានប្រាក់ចំណេញ និងមានហានិភ័យទាបបំផុត។ ដូចនេះគេទាមទារឱ្យមន្ត្រីទទួលបន្ទុកផ្នែកឥណទានទាំងអស់ត្រូវមានទេព្យកោសល្យសមត្ថភាព និងជំនាញច្បាស់លាស់ក្នុងប្រតិបត្តិការងាររបស់ខ្លួន ដើម្បីទទួលបានភាពជោគជ័យរបស់ខ្លួនផងដែរ។

### ១.៥.១. នីតិវិធីឥណទាន

នីតិវិធីក្នុងការបញ្ចេញឥណទានមានដូចខាងក្រោម:

- ដំណាក់កាលទី១: ទទួលពាក្យស្នើសុំខ្ចីឥណទាន។ នៅក្នុងដំណាក់កាលនេះមន្ត្រីឥណទានត្រូវពិនិត្យមើលពីលក្ខខណ្ឌទាមទារមួយចំនួន ដែលបានកំណត់ដោយច្បាប់ និងគោលនយោបាយឥណទានរបស់ធនាគារ។ ប្រសិនបើសំណើរនេះប៉ះពាល់ដល់លក្ខខណ្ឌទាមទារណាមួយមន្ត្រីឥណទាននឹងបដិសេធសំណើរសុំខ្ចីនោះ។
- ដំណាក់កាលទី២: ទទួលឯកសារទាមទារ ឬរបាយការណ៍ហិរញ្ញវត្ថុ
    - ចំពោះឥណទានប្រើប្រាស់ផ្ទាល់ខ្លួន: ឯកសារទាមទាររួមមាន ប័ណ្ណបើកបររថយន្ត របាយការណ៍ចំណូល (ប្រាក់ខែ) ភស្តុតាងដែលបង្ហាញពីប្រភពចំណូលផ្សេងទៀត របាយការណ៍លម្អិតពីការចំណាយនិងរបាយការណ៍លម្អិតពីទ្រព្យសកម្មផ្សេងទៀត។
    - ចំពោះឥណទានអាជីវកម្ម: ត្រូវតែផ្តល់ឯកសារស្តីពីការផ្តល់សិទ្ធិអំណាច (Document of Constitution)។ មានន័យថា អ្នកខ្ចីត្រូវតែជាម្ចាស់ក្រុមហ៊ុន ឬអ្នកតំណាងឱ្យក្រុមហ៊ុនដែលទទួលសិទ្ធអំណាច (ជាលាយលក្ខអក្សរអំពីក្រុមប្រឹក្សាភិបាល) និងឯកសារទាមទារមួយចំនួនទៀតដូចជា តារាងតុល្យការ របាយការណ៍ចំណូលចំណាយ និងរបាយការណ៍លំហូរសាច់ប្រាក់ ដែលឯកសារទាំងនេះមានរយៈពេលបីទៅប្រាំឆ្នាំ។ ឯកសារទាំងនេះនឹងត្រូវយកទៅវិភាគដោយមន្ត្រីឥណទាន។
- ដំណាក់កាលទី៣: ត្រួតពិនិត្យស្នើសុំខ្ចីឥណទាន និងឯកសារ ឬរបាយការណ៍ហិរញ្ញវត្ថុឡើងវិញ។ បើមន្ត្រីឥណទានយល់ថានៅខ្វះព័ត៌មានមួយចំនួនទៀត ត្រូវប្រាប់នៅអ្នកខ្ចីឱ្យយកឯកសារបន្ថែមបាន។
- ដំណាក់កាលទី៤: នៅពេលព័ត៌មានត្រូវបានទទួល និងស្ថិតនៅក្នុងលំដាប់លំដោយនោះការសំរេចចិត្តថាត្រូវផ្តល់ ឬបដិសេធសំណើសុំខ្ចីឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់

ខ្លួនត្រូវបានបង្កើតឡើង។ ក្នុងករណីឥណទានអាជីវកម្មត្រូវបន្តទៅតំណាក់បន្តបន្ទាប់ទៀត ដែលសំខាន់ជាងគេ គឺកាចុះទៅពិនិត្យដល់ទីកន្លែងអាជីវកម្មរបស់អ្នកខ្ចី។

- ដំណាក់កាលទី៥: វាយតម្លៃលម្អិតពីបច្ចេកទេស និងចំណេះដឹងក្នុងការគ្រប់គ្រង ចាត់ចែងអាជីវកម្ម និងធនធានហិរញ្ញវត្ថុរបស់អ្នកខ្ចី។
- ដំណាក់កាលទី៦: វាយតម្លៃពីតម្រូវការហិរញ្ញវត្ថុរបស់អ្នកខ្ចីមានន័យថា មន្ត្រីឥណទានធ្វើការវាយតម្លៃពីទំហំអាជីវកម្មរបស់អ្នកខ្ចី ថាតើទំហំអាជីវកម្មសមស្របទៅនឹងទឹកប្រាក់ ដែលអ្នកខ្ចីបានស្នើសុំខ្ចីដែរឬទេ? និងមើលថា តើអាជីវកម្មនឹងអាចរកចំណូលបានគ្រប់គ្រាន់ដើម្បីសងវិញឬទេ?
- ដំណាក់កាលទី៧: ករណីដំណើរការត្រូវបានយល់ព្រម ត្រូវផ្តល់ព័ត៌មានទៅអ្នកខ្ចីឱ្យមកកាន់ធនាគារដើម្បីចុះហត្ថលេខាលើឯកសារដែលពាក់ព័ន្ធ។ បើសំណើរត្រូវបានបដិសេធក៏ត្រូវ ផ្តល់ព័ត៌មានទៅឱ្យអ្នកសុំខ្ចីវិញដែរ ដោយបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់។
- ដំណាក់កាលទី៨: ត្រូវតែច្បាស់ថា វត្ថុធានា និងឯកសារផ្សេងៗ ត្រូវចុះហត្ថលេខាយ៉ាងត្រឹមត្រូវមុនពេលផ្តល់ប្រាក់កម្ចីដល់អ្នកខ្ចី។ ដំណាក់កាលនេះ មន្ត្រីឥណទានត្រូវត្រួតពិនិត្យមើលឡើងវិញនូវវត្ថុធានា (ដើម្បីច្បាស់ថា វាពិតជាកម្មសិទ្ធរបស់អ្នកខ្ចី) កិច្ចសន្យាដាក់វត្ថុធានា កិច្ចសន្យាខ្ចីប្រាក់ និងឯកសារសំខាន់ៗផ្សេងៗទៀតដែលពាក់ព័ន្ធដើម្បីធានាសុវត្ថិភាព។
- ដំណាក់កាលទី៩: ពិនិត្យមើលគណនីជាប្រចាំ។ នៅក្នុងករណីឥណទានតម្រូវឱ្យអ្នកខ្ចីផ្តល់របាយការណ៍ហិរញ្ញវត្ថុជាប្រចាំមន្ត្រីឥណទាន ត្រូវពិនិត្យមើលអតិថិជនបានផ្តល់ឯកសារទាំងនោះទៀងទាត់ ឬទេ?
- ដំណាក់កាលទី១០: បើការពិនិត្យគណនីរបស់អ្នកខ្ចីមានចំណុចមួយចំនួនដែលធនាគារមិនពេញចិត្តត្រូវតែចាត់វិធានការណ៍ជាបន្ទាន់ដើម្បីកុំឱ្យឥណទានមានបញ្ហា។

ការអនុវត្តន៍នីតិវិធីទាំង១០ដំណាក់កាលទាំងនេះ អាចធានាយ៉ាងច្បាស់ថា គ្មានចំណុចណាមួយភ្លេចភ្លាំងឡើយនៅក្នុងដំណើរការនៃការផ្តល់ឥណទាន។

### **១.៥.២. ការវាយតម្លៃឥណទានតាម5C's**

សារៈសំខាន់នៃការវិភាគឥណទានគឺ ធ្វើការសម្រេចគួរផ្តល់ឥណទានឱ្យអតិថិជនម្នាក់ ឬក៏អត់។ គោលការណ៍មូលនិធិត្រូវបានផ្តល់ឱ្យកន្លែងដែលជំរុញនូវប្រាក់ចំនេញអតិបរមា និងការខាតបង់ជាអប្បបរមា។ មុននឹងសម្រេចផ្តល់ឥណទានឱ្យអតិថិជន ស្ថាប័នចាំបាច់ត្រូវវិភាគជាមុន

ដោយផ្អែកលើ5CS ដែលមានដូចជាចរិតលក្ខណៈ (Character) សមត្ថភាព (Capacity) វត្ថុបញ្ចាំ (Collateral) លក្ខខណ្ឌ (Condition) ដើមទុន (Capital) ។

**ចរិតលក្ខណៈ**

មន្ត្រីឥណទានត្រូវដឹងឱ្យច្បាស់អំពីគោលបំណងរបស់អតិថិជន ( Well Defined Purpose ) ក្នុងការស្នើសុំឥណទាន។ នៅពេលបានដឹងពីគោលបំណង ហើយមន្ត្រីឥណទានត្រូវត្រួតពិនិត្យមើលថា តើវាស៊ីចង្វាក់ នឹងការស្នើសុំឥណទាន របស់អង្គភាពឬទេ។ ក្នុងនេះមានការទទួលខុសត្រូវ (Responsibility) ភាពស្មោះត្រង់ (Faithfulness) គោលបំណងច្បាស់ (Serious Purposes) និងភាពម៉ឺងម៉ាត់ (Serious Intention) ក្នុងការសងបំណុលរបស់អតិថិជនទាំងអស់នេះបញ្ចូលគ្នាគេហៅថាចរិតលក្ខណៈ។ ប្រសិនបើមន្ត្រីឥណទានយល់ឃើញថា អតិថិជនមានចរិតលក្ខណៈមិនស្មោះត្រង់ នោះអង្គភាពមិនគួរគប្បីអនុម័តឱ្យខ្ចីប្រាក់នោះឡើយ។

**សមត្ថភាព**

មន្ត្រីឥណទានត្រូវដឹងច្បាស់ថាអតិថិជនស្នើសុំប្រាក់មានសិទ្ធ (Authority) អាចខ្ចីប្រាក់ និងមានជំហរស្របច្បាប់ (Legal Standing) ក្នុងការចុះហត្ថលេខាលើកិច្ចសន្យាខ្ចីប្រាក់។ លក្ខណៈសម្បត្តិរបស់អតិថិជននេះហៅថាសមត្ថភាពខ្ចីប្រាក់ (Capacity to Borrow Money) ។

ឧទាហរណ៍នៅសហរដ្ឋអាមេរិក មានក្មេងអាយុក្រោម១៨ឆ្នាំ ឬ២១ឆ្នាំ មិនអាចត្រូវបានចោតប្រកាន់ច្បាប់ឱ្យទទួលខុសត្រូវចំពោះកិច្ចសន្យាឥណទានឡើយ។ ហេតុនេះហើយ ប្រសិនបើធនាគារឱ្យខ្ចីប្រាក់ចំពោះក្មេងបែបនេះ ក្នុងករណីគ្មានលទ្ធភាពសងបំណុល នោះគេនឹងមានការលំបាកក្នុងការទារបំណុលតាមផ្លូវច្បាប់។

**វត្ថុបញ្ចាំ**

ក្នុងការវាស់វែងធានាមន្ត្រីឥណទានត្រូវសួរសំនួរដូចជា តើអ្នកខ្ចីមានទ្រព្យសម្បត្តិសុទ្ធ (Net Worth) ឬទ្រព្យសកម្មមានគុណភាព (Quality Assets) គ្រប់គ្រាន់អាចធានាដល់ប្រាក់កម្ចីរបស់គេដែរឬទេ? មន្ត្រីឥណទានចាប់អារម្មណ៍ជាពិសេសទៅលើទិន្នន័យមួយចំនួនដូចជា អាយុ លក្ខណៈ និងកំរិត ឯកទេសកម្ម (Degree of Specialization) នៃទ្រព្យសកម្មរបស់អ្នកខ្ចីមានលក្ខណៈហួសសម័យដោយសារបច្ចេកវិទ្យា ទ្រព្យសម្បត្តិបែបនេះមានតម្លៃតិចតួចប៉ុណ្ណោះសម្រាប់ធ្វើជាវត្ថុធានា ពីព្រោះវាពិបាកនឹងលក់ចេញ។ នៅកម្ពុជាយើងពេញនិយមដាក់បញ្ចាំជា ប្លង់ផ្ទះ ឬប្លង់ដីដើម្បីអាចទទួលប្រាក់កម្ចីពីធនាគារ។

**លក្ខខណ្ឌ**

មន្រ្តីឥណទាន និងអ្នកវិភាគឥណទានត្រូវដឹងអំពីនិន្នាការថ្មីៗក្នុងការងារ ឬឧស្សាហកម្ម (Line of Work or Industry) របស់អ្នកខ្ចីប្រាក់ និងការប្រែប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ច (Economics Condition) អាចមានឥទ្ធិពលយ៉ាងណាទៅលើការខ្ចីប្រាក់។ ដើម្បីវាយតម្លៃស្ថានភាពសេដ្ឋកិច្ច និងឧស្សាហកម្ម ធនាគារបានរក្សាព័ត៌មានដូចជា អត្ថបទក្នុងសារព័ត៌មាន អត្ថបទក្នុងទស្សនាវដ្តី និងរបាយការណ៍ស្រាវជ្រាវផ្សេងៗស្តីអំពីឧស្សាហកម្មដែលជារបស់អ្នកខ្ចីប្រាក់សំខាន់ៗរបស់ខ្លួន។ ស្ថានភាពដែលមានឥទ្ធិពលទៅលើការផ្តល់កម្ចីមានដូចជា ការថយចុះនៃការលក់ ឬប្រាក់ចំណូលរបស់កូនបំណុលនៅពេលសេដ្ឋកិច្ចធ្លាក់ចុះ ឬអត្រាការប្រាក់នៅលើទីផ្សារកើនឡើង ដោយសារអតិផរណាកើនឡើងជាដើម។

**ដើមទុន**

វាយតម្លៃស្ថានភាពហិរញ្ញវត្ថុក្នុងមុខរបរ ដើម្បីកំណត់ពីស្ថានភាពដើមទុន និងប្រភពទុន។ ការវាយតម្លៃដើមទុនត្រូវប្រមូលព័ត៌មានអំពីមុខរបរ ដែលជាទិន្នន័យសម្រាប់រៀបចំគម្រោងជំនួញរបស់អតិថិជនដើម្បីត្រួតពិនិត្យគោលបំណងនៃការប្រើប្រាស់ប្រាក់កម្ចី។

### ១.៥.៣. ការវាយតម្លៃឥណទានតាម3R’s

- មនុស្សត្រឹមត្រូវ (Right person)

  សំដៅដលការផ្តល់ឥណទានទៅដល់អតិថិជន ដោយសង្ឃឹមថាគាត់នឹងសងត្រលប់មកវិញទាំងដើម និងទាំងការប្រាក់ទៅតាមកាលបរិច្ឆេទកំណត់ជាក់លាក់។
- ពេលវេលាត្រឹមត្រូវ (Right Time)

  កំណត់កាលវេលា សម្រាប់ការណាត់ជួប ដើម្បីធ្វើការផ្តល់ឥណទានឲ្យអតិថិជន។ ការកំណត់ពេលវេលានេះអាចជាជំនួយផងដែរក្នុងការសម្រេចផ្តល់ឥណទាន ដោយពិចារណាលើការទទួលខុសត្រូវខ្ពស់របស់អតិថិជនក្នុងការគោរពពេលវេលាណាត់ជួបជាមួយគ្នា។
- ទំហំទុនត្រឹមត្រូវ (Right Amount)

  ការវិភាគ និងវាយតម្លៃទៅលើទំហំរបស់ទុនអតិថិជនអំពីចំណូលចំណាយរបស់គាត់ និងលក្ខខណ្ឌខ្លះទៀត ដើម្បីកំណត់ទំហំទុនថាតើគួរអោយគាត់ខ្ចីប៉ុន្មានដែលសមរម្យ និងត្រឹមត្រូវ។

### ១.៥.៤. ផ្នែកប្រតិបត្តិការ និងការគ្រប់គ្រងឥណទាន

ការផ្តល់ឥណទានជាផ្លូវការអាចសម្រេចទៅបាន ដោយមន្រ្តីឥណទាន ឬដោយគណកម្មការឥណទាន និងយោងតាមនយោបាយ ឬរចនាសម្ព័ន្ធចាត់តាំងរបស់ស្ថាប័ននីមួយៗ។ ជា

ទូទៅភ្នាក់ងារឥណទាននីមួយៗមានសិទ្ធិអំណាចឯករាជ្យ ក្នុងការអនុម័តផ្តល់ឥណទានរហូតដល់ចំនួនកំណត់មួយ។ នៅពេលដែលភ្នាក់ងារឥណទានបានអនុម័តយល់ព្រម ហើយគេត្រូវផ្តល់ដំណឹងដល់អ្នកខ្ចី និងរៀបចំកិច្ចសន្យាឥណទាន។ កិច្ចសន្យានេះបង្កើតឡើងដោយស្ថាប័នហិរញ្ញវត្ថុ ហើយមានការព្រមព្រៀងគ្នារវាងភាគីសងខាង ដោយពុំមានការបង្ខិតបង្ខំឡើយ។ មន្ត្រីឥណទានត្រូវត្រួតពិនិត្យ រាល់ឯកសារ ទាំងអស់ដែលមានតាមលំដាប់ បន្ទាប់មកឱ្យអ្នកខ្ចីចុះហត្ថលេខា ឬផ្តិតមេដៃលើកិច្ចសន្យា ព្រមព្រៀង ជាមូលដ្ឋានរួមជាមួយអ្នកធានា សាក្សីដទៃព្រមទាំងប្រគល់វត្ថុបញ្ចាំ រួចហើយទទួលប្រាក់កម្ចី។

## ១.៦. ការត្រួតពិនិត្យឥណទាន

នៅពេលដែលកម្ចីមួយបានកើតឡើង គោលបំណងសំខាន់នៃការត្រួតពិនិត្យឥណទានគឺដើម្បីកាត់បន្ថយនូវហានិភ័យ ហើយការត្រួតពិនិត្យនេះត្រូវបែងចែកជាពីរ:

- ការត្រួតពិនិត្យនូវសកម្មភាពកម្ចីដែលមានស្រាប់។
- ការដោះស្រាយនូវកម្ចីដែលមានបញ្ហា។

## ១.៧. ប្រភេទការប្រាក់

ការប្រាក់មានពីរប្រភេទគឺ[5]

- ការប្រាក់សាមញ្ញឬការប្រាក់ទោល (Simple Interest): ជាការប្រាក់ដែលគិតលើប្រាក់ដើមក្នុងកំឡុងពេល។ ការប្រាក់ប្រាក់របស់កំឡុងពេលនីមួយៗ មិនបានបូកបញ្ចូលជាប្រាក់ដើម ដើម្បីគិតការប្រាក់ ក្នុងកំឡុងពេលក្រោយឡើយ។
- ការប្រាក់សមាស ឬការប្រាក់ផ្គួប (Compound Interest): ជាការប្រាក់ដែលគេធ្វើឡើងនៅចុងកំឡុងពេលនីមួយ ហើយការប្រាក់ដែលទទួលបាននៅពេលចុងកំឡុងពេលទី១ ត្រូវបូកបន្ថែមនឹងប្រាក់ដើម នៅកំឡុងពេលទី២សម្រាប់គិតការប្រាក់។ គេធ្វើរបៀបនេះរហូតដល់ កំឡុងពេលចុងក្រោយ។ (ការប្រាក់បង្កើតការប្រាក់)

[5] ជា សែម, ឡាយ សុខឃាង, ឆូ សុគន្ធ (២០១២-២០១៣) *គណិតវិទ្យាសេដ្ឋកិច្ចឆ្នាំទី១* ទំព័រ ២២

# ជំពូកទី ២

# ស្ថានភាពទូទៅរបស់ធនាគារ កាណាឌីយ៉ា ក.អ

## ២.១. ប្រវត្តិកកើតរបស់ធនាគារ កាណាឌីយ៉ា ក.អ

ពាក្យថា Canadian ចេញមកពីពាក្យ Cana (Canada) + Dia (Cambodia) = CANADIA។ ធនាគារកាណាឌីយ៉ា អ.ក ត្រូវបានបង្កើតឡើងនូវថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩១ ដែលមានឈ្មោះថា "Canadia Gold & Trust Corporation Ltd." ដោយមានការចូលរួមរវាងភាគីកម្ពុជា និងកាណាដា និងធនាគារជាតិនៃកម្ពុជា។ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារគឺមានការចូលរួមពីបុគ្គលិកជំនាញៗ ពីធនាគារជាតិនៃកម្ពុជា និងម្ចាស់ភាគហ៊ុនទាំងសងខាង: កម្ពុជា កាណាដា ។

គោលដៅសំខាន់ៗរបស់ធនាគារកាណាឌីយ៉ា គឺសំដៅទៅលើប្រតិបត្តិការមាស ដូចជាការផលិត មាស និងផ្តល់កម្ចីដល់ពាណិជ្ជករទាំងឡាយ។ នៅថ្ងៃទី១៩ មេសា ១៩៩៣ ធនាគារត្រូវបានប្តូរទៅជាធនាគារកាណាឌីយ៉ា ដោយទទួលបានសិទ្ធជាធនាគារពាណិជ្ជកម្មពីធនាគារជាតិកម្ពុជា និងត្រូវបានចុះក្នុងបញ្ជីក្រសួងពាណិជ្ជកម្ម។ រហូតមកដល់ថ្ងៃទី១៦ ធ្នូ ២០០៣ ធនាគារត្រូវបានទទួលស្គាល់សារជាថ្មីថា ធនាគារកាណាឌីយ៉ា ក.អ។

ចាប់តាំងពីឆ្នាំ១៩៩៨ ធនាគារបានក្លាយជាធនាគារក្នុងស្រុកដ៏ធំជាងគេ ជាមួយបណ្តាញដ៏ធំជាងគេទូទាំងពិភពលោក ហើយមានការទទួលស្គាល់យ៉ាងមុតមាំពីសំណាក់ប្រជាជនក្នុងស្រុកក៏ដូចជាក្រៅប្រទេស។ ធនាគារផ្តោតទៅលើទីផ្សារភាគហ៊ុន ការផ្តល់ប្រាក់កំចីក៏ដូចជាការទទួលប្រាក់បញ្ញើ។ ធនាគារផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុនៅទីស្នាក់ការកណ្តាល និងគ្រប់ ៥៦ សាខាក្នុងទីក្រុងភ្នំពេញ និងបណ្តាលខេត្តផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ។

## ២.២. ទីតាំង និងផ្លាកសញ្ញា

### ក. ទីតាំងភូមិសាស្ត្រ

ធនាគារកាណាឌីយ៉ា ក.អ បច្ចុប្បន្នមានទីស្នាក់ការកណ្តាលតាំង នៅអគារលេខ#៣១៥ , ផ្លូវអង្គឌួងកែងមហាវិថីមុនីវង្ស រាជធានីភ្នំពេញ ។

### ខ. ផ្លាកសញ្ញារបស់ធនាគារកាណាឌីយ៉ា ក.អ

ខាងក្រោមនេះគឺជាផ្លាកសញ្ញាសំគាល់ពីធនាគារ កាណាឌីយ៉ា ក.អ

រូបភាពទី២.១ ផ្លាកសញ្ញារបស់ធនាគារកាណាឌីយ៉ា ក.អ

ប្រភព: គេហទំព័រ កាណាឌីយ៉ា ក.អ

- **រូបសញ្ញា**

- រូបមានទំរង់ជារង្វង់មូល ពណ៌មាសដូចកាក់ ហើយផ្ទៃខាងក្នុងមានរាងផត ពណ៌មាសទាំងបួនផ្នែក។
- ផ្នែកខាងក្រោមនៃរូបមានឈ្មោះ ធនាគារកាណាឌីយ៉ា ក.អ ជាអក្សរខ្មែរ ចិន និង អង់គ្លេស។

- **អត្ថន័យនៃរូបសញ្ញា**
  - **រូបកាក់ពណ៌មាស:** តំណាងអោយហិរញ្ញវត្ថុរឹងមាំ។
  - **ផ្ទៃខាងក្នុងមានរាងផតពណ៌មាស:** តំណាងអោយភាព រីកចំរើន និងភ័ព្វសំណាងដែលឆ្ពោះទៅអោយជោគជ័យក្នុងអាជីវកម្ម។

## ២.៣. បេសកម្ម និង គោលដៅរបស់ធនាគារកាណាឌីយ៉ា ក.អ

### ក. គោលដៅ

គោលដៅរបស់ធនាគារកាណាឌីយ៉ា ក.អ គឺកេណ្ឌប្រមូលសាច់ប្រាក់ដែលទំនេរ ដើម្បីជួយជំរុញសកម្មភាពសេដ្ឋកិច្ច តាមរយ:ការផ្តល់ឥណទានទៅ តាមផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម និងផ្នែកផលិតកម្មផ្សេងៗក្នុងស្រុក ព្រោះថាឥណទានជាកំលាំងចលករ ដែលអាចជួយជំរុញអោយ ខឿនសេដ្ឋកិច្ចជាតិមានការរីកចំរើន។

### ខ. បេសកម្ម

បេសកម្មរបស់ធនាគារកាណាឌីយ៉ា ក.អ គឺផ្តល់ជូនសហគ្រិនខ្នាតតូចនិងមធ្យម និងសាធារណ:ជននូវមធ្យោបាយក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុអោយមានប្រសិទ្ធភាព

ដើម្បីលើកស្ទួយ ជីវភាពរស់នៅឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយអនុវត្តអោយបាននូវនិរន្តរភាព និងបង្កើតនូវអត្ថប្រយោជន៍ជូនដល់ម្ចាស់ភាគហ៊ុន កម្មករ និយោជិក ព្រមទាំងសហគមន៍ទាំងអស់។

## ២.៤. ទស្សនៈរបស់ធនាគារកាណាឌីយ៉ា ក.អ

**អតិថិជន**: ធនាគារកាណាឌីយ៉ា ក.អ ត្រូវបានសាធារណៈជនជឿជាក់ ទុកចិត្តក្នុងការថែរក្សា ប្រាក់បញ្ញើរបស់ពួកគេ។ និយោជិតទាំងអស់ត្រូវបានណែនាំអោយ បំរើភ្ញៀវដោយស្មោះត្រង់ រហ័ស និងរាក់ទាក់ដើម្បីបំពេញសេចក្តីត្រូវការរបស់អតិថិជនទាំងអស់។ យើងខ្ញុំជឿជាក់ថាការផ្តល់សេវាដ៏ល្អ ជូនដល់អតិថិជនរបស់យើង និងបង្កើនតំលៃសំរាប់ម្ចាស់ភាគហ៊ុន។

**និយោជិក:** និយោជិករបស់យើងខ្ញុំទាំងអស់គ្នា គឺជាគន្លឹះដំបូងបំផុតចំពោះការជោគជ័យរបស់ធនាគារ។ ដើម្បីទាក់ទាញ និងរក្សាទុកមនុស្សមានសមត្ថភាព យើងខ្ញុំខិតខំយកចិត្តទុកដាក់លើការចំណាយប្រាក់ខែតាមរបៀបប្រកួតប្រជែងផ្តល់ជូនប្រាក់ខែបន្ទាប់បន្សំ ដែលគួរអោយចាប់អារម្មណ៍តាមស្តង់ដារក្រុមហ៊ុនឧស្សាហកម្ម ព្រមទាំងផ្តល់ការប្រណាំងប្រជែងបរិស្ថាននៃភាពទៀងត្រង់ខ្លាំងជាមួយនឹងឱកាសរីកចំរើនគ្មានដែនកំណត់ ដែលវង្វាស់អាស្រ័យទៅលើលទ្ធភាពការងារដែលសំរេចបាន។

**បរិស្ថានសង្គម និងសហគមន៍:** យើងខ្ញុំជឿជាក់ថាទុកចិត្ត ចំពោះការធ្វើវិភាគទានទៅដល់សង្គម ទាំងផ្នែកហិរញ្ញវត្ថុនិងការស្ម័គ្រចិត្ត។ ធនាគារកាណាឌីយ៉ា ក.អ មានគោលនយោបាយបែងចែកប្រាក់ចំណេញប្រចាំឆ្នាំចំនួន៥% សំរាប់ការងារ សប្បុរសធម៌។ យើងខ្ញុំមានបំណងចង់ទទួលខុសត្រូវជួយ ដល់ជនទាំងនោះ ។

**ម្ចាស់ភាគហ៊ុន:** បង្កើតទំនាក់ទំនងល្អជាមួយម្ចាស់ភាគហ៊ុនគ្រប់រូប និងវិនិយោគិនផ្សេងៗទៀត ដែលផ្តល់ហិរញ្ញប្បទានដល់ធនាគារ តាមរយៈការផ្តល់ប្រាក់ចំណេញជាបណ្តើរៗ ធ្វើការបង្កើនតំលៃភាគហ៊ុន និងផ្សព្វផ្សាយពត៌មានយ៉ាងត្រឹមត្រូវមិនលំអៀង។

## ២.៥. ដើមទុន និង ចំណែកហ៊ុនរបស់ធនាគារកាណាឌីយ៉ា ក.អ

បន្ទាប់ពីធ្វើវិសោធនកម្មនៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៩៧ មកធនាគារកាណាឌីយ៉ា ក.អ មិនស្ថិតក្រោមរូបភាពជាសហគ្រាសចំរុះ រវាងរដ្ឋនិងឯកជនទៀតទេ។ ដូច្នេះវាជាធនាគារឯកជនសុទ្ធសាធដែលមានដើមទុនបង្កើត ធនាគារចំនួន ៥,០០០,០០០ (ប្រាំលានដុល្លាអាមេរិច) ជាដើមទុនចុះបញ្ជីរបស់ធនាគារហើយត្រូវបែងចែកជា ៥,០០០ភាគហ៊ុនដែល ក្នុងមួយភាគហ៊ុនមានតំលៃ ១,០០០ដុល្លា (មួយ ពាន់ដុល្លាអាមេរិច) ប៉ុន្តែរហូតមកដល់ពេលបច្ចុប្បន្ននេះធនាគារបានបង្កើតដើមទុនរបស់ខ្លួនរហូតដល់ ១៥០ពាន់លានរៀល ដែលស្មើនឹង៣៧.៥លានដុល្លា (សាមសិបប្រាំពីរ

លានប្រាំសែនដុល្លាអាមេរិច) ដើម្បីអោយសមស្របតាមការកំណត់របស់ច្បាប់ស្តីពីគ្រឹស្ថានធនាគារ និងហិរញ្ញវត្ថុ។

## ២.៦. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារកាណាឌីយ៉ា ក.អ

ខាងក្រោមនេះ គឺជារចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារកាណាឌីយ៉ា ក.អ ដែលបានបង្ហាញដូចខាងក្រោម:

រូបភាពទី២.២ រចនាសម្ព័ន្ធរបស់ធនាគារកាណាឌីយ៉ា ក.អ




ប្រភព: ធនាគារកាណាឌីយ៉ា ក.អ

## ២.៧. ទំហំឥណទានខ្នាតតូច (Small Loan)

### ២.៧.១. ឥណទានខ្នាតតូច

ឥណទានខ្នាតតូចត្រូវបានបង្កើតឡើងជាពិសេស សម្រាប់អ្នកខ្ចីជារូបវន្តបុគ្គលនៃទីផ្សាររបស់អ្នកដែលមានអាជីវកម្មខ្លួនឯង និងអ្នកដែលធ្វើការងារមានប្រាក់បៀវត្ស ដែលប្រភពចំណូលនោះមានកម្រិតមធ្យមស្របតាមលក្ខខណ្ឌនៃការខ្ចី-សង និងមានទ្រព្យសម្បត្តិអាចធានាសុវត្ថិភាពឥណទាន។

### ២.៧.២. ប្រភេទរូបិយប័ណ្ណ និងទំហំឥណទាន

ដើម្បីងាយស្រួលកំណត់យុទ្ធសាស្ត្រក្នុងការប្រកួតប្រជែងឥណទានខ្នាតតូចត្រូវបានកំណត់ដូចខាងក្រោម៖

តារាងទី២.១ រូបិយវត្ថុដុល្លារ និងទំហំឥណទាន

| ប្រភេទរូបិយប័ណ្ណ | ទំហំឥណទានអប្បបរមា | ទំហំឥណទានអតិបរមា |
|---|---|---|
| ប្រាក់ដុល្លារ | ២០,០០១ | ៥០,០០០ |

### ២.៧.៣. ប្រភេទរូបិយប័ណ្ណ និងតំបន់ប្រតិបត្តិការ

ដើម្បីងាយស្រួលកំណត់យុទ្ធសាស្ត្រក្នុងការប្រកួតប្រជែងឥណទានខ្នាតតូចត្រូវបានកំណត់ដូចខាងក្រោម៖

តារាងទី២.២ រូបិយវត្ថុ និងតំបន់ប្រតិបត្តិការ

| ប្រភេទរូបិយប័ណ្ណ | តំបន់ប្រតិបត្តិការ |
|---|---|
| ប្រាក់ដុល្លារ | ទូទាំងប្រទេស |

### ២.៧.៤. ការកំណត់ទំហំឥណទានសម្រាប់អតិថិជនម្នាក់ៗ

ទំហំឥណទាននីមួយៗដែលត្រូវផ្តល់ជូនអតិថិជនធ្វើការវាស់វែងដោយផ្អែកលើមូលដ្ឋាន

- លទ្ធភាពសងរបស់អតិថិជន។
- ទ្រព្យដាក់ធានា។
- រយៈពេលខ្ចី។

### ២.៧.៥. រយៈពេលខ្ចី និងអត្រាការប្រាក់

អត្រាការប្រាក់ត្រូវបានកំណត់ ទៅតាមទំហំឥណទានប្រភេទរូបិយប័ណ្ណនីមួយៗ និងរយៈពេលនៃឥណទាននីមួយៗដូចតទៅ៖

តារាងទី២.៣ រយៈពេលខ្ចី និងអត្រាការប្រាក់

| ប្រភេទរូបិយប័ណ្ណ | ទំហំអប្បបរមា | ទំហំអតិបរមា | រយៈពេលអតិបរមា | អត្រាការប្រាក់អប្បរមាប្រចាំខែ |
|---|---|---|---|---|
| ប្រាក់ដុល្លារ | ២០,០០១ | ៣០,០០០ | ៦០ខែ | ១.២% |
| | ៣០,០០១ | ៥០,០០០ | ៧២ខែ | ១.១% |

### ២.៧.៦. សោហ៊ុយឥណទាន

គ្រប់អតិថិជនទាំងអស់ ដែលត្រូវបានផ្តល់ឥណទានតាមទំហំខាងលើនេះ ត្រូវបង់សោហ៊ុយឥណទានចំនួន១%(មួយភាគរយ) នៃទំហំឥណទាន ដែលបានអនុម័តមុនពេលទទួលឥណទាន។

### ២.៧.៧. កម្រិតនៃការបញ្ជាក់កិច្ចសន្យា

ទ្រព្យសម្បត្តិដាក់ធានា តម្រូវអោយចុះកិច្ចសន្យាហ៊ីប៉ូតែក ឬកិច្ចសន្យាដាក់បញ្ចាំ ដោយមាន ការបញ្ជាក់ពីអជ្ញាធរមូលដ្ឋាន ភូមិ ឃុំ ឬស្រុក អាស្រ័យទៅតាមស្ថានភាពជាក់ស្តែងចុះការីបន្ទុក បញ្ចាំពីមន្ទីរ ឬការិយាល័យ រៀបចំដែនដីនគរូបនីយកម្ម សំណង់និងភូមិបាលរាជធានី-ខេត្ត, ក្រុង-ស្រុក-ខណ្ឌ ទៅតាមសភាពជាក់ស្តែង ។

- ចំពោះទំហំឥណទានរហូតដល់៣០,០០០ដុល្លារអាចតម្រូវអោយចុះ ឬ មិនចុះការីបន្ទុកដាក់ធានាពីមន្ទីរ ឬការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលរាជធានី-ខេត្ត, ក្រុង-ស្រុក-ខណ្ឌ ទៅតាមកម្រិតហានិភ័យជាក់ស្តែងដែលសាខាបានព្យាករណ៍។
- ចំពោះទំហំឥណទានធំជាង ៣០,០០០ដុល្លារ តម្រូវអោយចុះការី បន្ទុកដាច់ខាត (ត្រាស្វយោដី) ដាក់ធានាពីមន្ទីរ ឬការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលរាជធានី-ខេត្ត, ក្រុង-ស្រុក-ខណ្ឌ។

**ករណីផ្សេងពីនេះ នាយិកានាយកដ្ឋាន ឥណទានខ្នាតតូច និងមធ្យម ជាអ្នកសម្រេច។**

- ❖ ករណីខ្ចីបន្ថែម ឬខ្ចីបន្តដោយដាក់ទ្រព្យសម្បត្តិដែលមានតម្លៃអាចធានាសុវត្ថិភាពឥណទាន តាមលក្ខខណ្ឌកម្រិតសុវត្ថិភាពនៃឥណទាន មិនតម្រូវឲ្យចុះកិច្ចសន្យាបង្កើត ហ៊ីប៉ូតែក ឬកិច្ចសន្យាដាក់បញ្ចាំលើទ្រព្យសម្បត្តិនោះឡើងវិញទេ លើកលែងតែទ្រព្យសម្បត្តិដាក់ធានាបន្ថែមតែប៉ុណ្ណោះ។

## ២.៨. ទំហំឥណទានខ្នាតមធ្យម (Medium Loan)

### ២.៨.១. ឥណទានខ្នាតមធ្យម

ឥណទានខ្នាតមធ្យមត្រូវបានបង្កើតឡើងជាពិសេស សម្រាប់អ្នកខ្ចីជារូបវន្តបុគ្គលនៃទីផ្សាររបស់អ្នកដែលមានអាជីវកម្មខ្លួនឯង និងអ្នកដែលធ្វើការងារមានប្រាក់បៀវត្ស ដែលប្រភពចំណូលនោះមានកម្រិតបង្គួរស្របតាម លក្ខខណ្ឌនៃការខ្ចី-សង និងមានទ្រព្យសម្បត្តិអាចធានាសុវត្ថិភាពឥណទាន។

### ២.៨.២. ប្រភេទរូបិយប័ណ្ណ និងទំហំឥណទាន

ដើម្បីងាយស្រួលកំណត់យុទ្ធសាស្ត្រ ក្នុងការប្រកួតសប្រជែង ឥណទានខ្នាតមធ្យមត្រូវបាន កំណត់ដូចខាងក្រោម៖

តារាងទី២.៤ ប្រភេទឥណទាន និងទំហំឥណទាន

| ប្រភេទរូបិយប័ណ្ណ | ទំហំឥណទានអប្បបរមា | ទំហំឥណទានអតិបរមា |
|---|---|---|
| ប្រាក់ដុល្លារ | ៥០,០០១ | ២០០,០០០ |

### ២.៨.៣. ប្រភេទរូបិយប័ណ្ណ និងតំបន់ប្រតិបត្តិការ

ដើម្បីងាយស្រួលកំណត់យុទ្ធសាស្ត្រក្នុងការប្រកួតប្រជែងឥណទានខ្នាតមធ្យម ត្រូវបាន កំណត់ដូចខាងក្រោម៖

តារាងទី២.៥ ប្រភេទរូបិយប័ណ្ណ និងតំបន់ប្រតិបត្តិការ

| ប្រភេទរូបិយប័ណ្ណ | តំបន់ប្រតិបត្តិការ |
|---|---|
| ប្រាក់ដុល្លារ | ទូទាំងប្រទេស |

### ២.៨.៤. ការកំណត់ទំហំឥណទានសម្រាប់អតិថិជនម្នាក់ៗ

ទំហំឥណទាននីមួយៗ ដែលត្រូវបានផ្តល់ជូនអតិថិជនត្រូវធ្វើការវាស់វែង ដោយផ្អែកលើ មូលដ្ឋាន៖

- លទ្ធភាពសងរបស់អតិថិជន។
- ទ្រព្យដាក់ធានា។
- រយៈពេលខ្ចី។

### ២.៨.៥. រយៈពេលខ្ចី និងអត្រាការប្រាក់

អត្រាការប្រាក់ត្រូវបានកំណត់ ទៅតាមទំហំឥណទាន ប្រភេទរូបិយប័ណ្ណនីមួយៗ និងរយៈ ពេលនៃឥណទាននីមួយៗដូចតទៅ៖

តារាងទី២.៦ រយៈពេលខ្ចី និងអត្រាការប្រាក់

| ប្រភេទរូបិយប័ណ្ណ | ទំហំអប្បបរមា | ទំហំអតិបរមា | រយៈពេល អតិបរមា | អត្រាការប្រាក់ អប្បរមាប្រចាំខែ |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ប្រាក់ដុល្លារ | ៥០,០០១ | ១០០,០០០ | ៨២ខែ | ១.២% |
| | ១០០,០០១ | ២០០,០០០ | ៧២ខែ | ១% |

### ២.៨.៦. សោហ៊ុយឥណទាន

គ្រប់អតិថិជនទាំងអស់ ដែលត្រូវបានផ្តល់ឥណទានតាមទំហំខាងលើនេះ ត្រូវបង់សោហ៊ុយឥណទានចំនួន១%(មួយភាគរយ) នៃទំហំឥណទាន ដែលបានអនុម័តមុនពេលទទួលឥណទាន។

### ២.៨.៧. កម្រិតនៃការបញ្ជាក់កិច្ចសន្យា

ទ្រព្យសម្បត្តិដាក់ធានាតម្រូវអោយចុះកិច្ចសន្យាហ៊ីប៉ូតែក ឬកិច្ចសន្យាដាក់បញ្ចាំ ដោយមានការបញ្ជាក់ពីអជ្ញាធរមូលដ្ឋាន ភូមិ ឃុំ ឬ ស្រុក អាស្រ័យទៅតាមស្ថានភាពជាក់ស្តែង ចុះការីបន្ទុកបញ្ចាំពីមន្ទីរ ឬ ការិយាល័យ រៀបចំ ដែនដីនគរូបនីយកម្មសំណង់និងភូមិបាលរាជធានី-ខេត្ត,ក្រុង-ស្រុក-ខណ្ឌ ទៅតាមសភាពជាក់ស្តែង ។

**ករណីផ្សេងពីនេះ នាយិកានាយកដ្ឋាន ឥណទានខ្នាតតូចនិងមធ្យម និងនាយកឥណទានដែលបានចាត់តាំង ជាអ្នកសម្រេច។**

- ករណីខ្ចីបន្ថែម ឬខ្ចីបន្តដោយដាក់ទ្រព្យសម្បត្តិដែលមានតម្លៃអាចធានា សុវត្ថិភាពឥណទាន តាមលក្ខខណ្ឌកម្រិតសុវត្ថិភាពនៃឥណទានមិនតម្រូវឲ្យចុះកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ឬកិច្ចសន្យាដាក់បញ្ចាំលើទ្រព្យសម្បត្តិនោះឡើងវិញទេ លើកលែងតែទ្រព្យសម្បត្តិដាក់ធានាបន្ថែមតែប៉ុណ្ណោះ។

## ២.៩. សេវាកម្មរបស់ធនាគារកាណាឌីយ៉ា ក.អ

**ធនាគារអាជីកម្ម**[6]

**គណនីបញ្ញើ**

- គណនីសន្សំ
- គណនីរជេន
- គណនីចរន្ត
- គណនីមានកាលកំណត់

[6] គេហទំព័រ http://www.canadiabank.com.kh ចូលមើលថ្ងៃទី០១.ឧសភា.២០១៦

**សេវាពាណិជ្ជកម្ម**

- សេវាពាណិជ្ជកម្ម

**ឥណទានទុនបង្វិលរហ័ស**

- វិបារូបន៍ពាណិជ្ជកម្ម
- ឥណទានពាណិជ្ជកម្ម
- ឥណទានខ្នាតតូច-មធ្យម

**ការផ្ទេរប្រាក់**

- ការផ្ទេរប្រាក់ក្នុងស្រុក
- SWIFT

**ធនាគារអនឡាញ**

- សេវាកម្មធនាគារតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់នីតិបុគ្គល
- គន្លឹះការពារសុវត្ថិភាព
- ព័ត៌មានថ្មីៗស្តីពីសេវាកម្មធនាគារអនឡាញ
- សំនួរសួរញឹកញាប់
- ផ្សព្វផ្សាយស្តីពីសេវាកម្មធនាគារអនឡាញ

**សេវាទូទាត់តាមប័ណ្ណ**

- សេវាទទួលការទូទាត់តាមរយៈម៉ាស៊ីនឆូតកាត
- សេវាទូទាត់លើបណ្តាញ

**សេវាចាត់ចែងសាច់ប្រាក់**

- សេវាបើកប្រាក់បៀវត្ស
- សេវាប្តូររូបិយប័ណ្ណបរទេស
- សេវាធានា
- សេវាទូទាត់ពន្ធ
- អាជីវកម្មត្រាស់
- មូលប្បទានប័ត្រធនាគារ

**ធនាគារលក្ខណៈបុគ្គល**

**គណនីបញ្ញើ**

- គណនីសន្សំ

- គណនីវរជន
- គណនីចរន្ត
- គណនីកុមារ
- គណនីមានកាលកំណត់
- គណនីសន្សំសម្រាប់អាពាហ៍ពិពាហ៍
- គណនីបញ្ញើតាមផែនការ

**ឥណទានផ្ទះ**

- ឥណទានទិញផ្ទះ

**សេវាផ្ទេរប្រាក់**

- សេវាទទួលការទូទាត់តាមរយៈអនឡាញ
- សេវាផ្ទេរប្រាក់ក្នុងស្រុក
- សេវាដឹកជញ្ជូនប្រាក់
- SWIFT
- ម៉ាន់ នី ក្រាម
- គណនី អ៊ីហ្សីវ័ន្ត

**សេវាជួល**

- ឥណទានយានយន្ត

**កាតឥណទាន**

- ឥណទានទុនបង្វិល
- កាតឥណទានបុគ្គល

**ឥណទានផ្ទាល់ខ្លួន**

- ឥណទានផ្ទាល់ខ្លួន
- កម្ចីរហ័ស

**កាតកាណាឌីយ៉ា**

- កាត អេ ធី អឹម
- ស្មាត កាត

**ធនាគារអនឡាញ**

- សេវាកម្មធនាគារតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់បុគ្គល

- សេវាកម្មធនាគារតាមរយៈទូរស័ព្ទដៃ
- គន្លឹះការពារសុវត្ថិភាព
- ព័ត៌មានថ្មីៗស្តីពីសេវាកម្មធនាគារអនឡាញ
- សំនួរសួរញឹកញាប់
- ផ្សព្វផ្សាយស្តីពីសេវាកម្មធនាគារអនឡាញ

**ប្រាយវេតប៉ៃងយឹង**

- ប្រាយវេតប៉ៃងយឹង

**សេវាចាត់ចែងសាច់ប្រាក់**

- សេវាចាត់ចែងសាច់ប្រាក់

# ជំពូកទី ៣
# ការគ្រប់គ្រងឥណទានខ្នាតតូច និង មធ្យម របស់ធនាគារ កាណាឌីយ៉ា ក.អ

## ៣.១. លក្ខណៈទូទៅនៃឥណទានរបស់ធនាគារ កាណាឌីយ៉ា ក.អ

ឥណទានគឺជាផ្នែកមួយយ៉ាងសំខាន់ បំផុតរបស់វិស័យធនាគារ ដែលមិនអាចខ្វះបានហើយ ឥណទានក៏បានដើរតួនាទីជាប្រភពចំនូលដ៏ធំមួយផងដែរនៅក្នុងធនាគារ។ ដោយឃើញថាបច្ចុប្បន្ន ប្រទេសកម្ពុជាមានការរីកចំរើនខាងផ្នែកសេដ្ឋកិច្ចធនាគារកាណាឌីយ៉ា ក.អ បានផ្តល់ជូនដល់អតិថិជននូវសេវាឥណទានមួយចំនួនជូនដល់ ដែលមានគោលដៅច្បាស់លាស់និងជាពិសេស គឺប្រើប្រាស់ក្នុងលក្ខណៈជាទុនបង្វិល ក្នុងការប្រកបអាជីវកម្ម ឬក៏ធ្វើការពង្រីកមុខរបរបន្ថែម។ អាជីវកម្មដែលធនាគារ ផ្តល់ឥណទាន ត្រូវតែជាអាជីវកម្មស្របច្បាប់ដែលមានដូចជា៖ ពាណិជ្ជកម្ម ឧស្សាហកម្មទេសចរណ៍ និងការងារ ស្របច្បាប់ដែលបានចុះបញ្ជីច្បាស់លាស់។

ធនាគារកាណាឌីយ៉ា ក.អ មានផ្តល់ជូបសេវាឥណទានដូចជា៖ ឥណទានខ្នាតតូច និងមធ្យម ឥណទានពាណិជ្ជកម្ម និងឥណទានគេហដ្ឋាន ។

## ៣.២. ឥណទានខ្នាតតូច និង មធ្យម

ឥណទានខ្នាតតូចនិងមធ្យម គឺជាឥណទានមួយប្រភេទ ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីពង្រឹង និងជំរុញដល់ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជាអោយមានដំណើរការកាន់តែចំរើនជាងនេះថែមទៀត។ ឥណទាននេះអាចផ្តល់កម្ចីជូនដល់អតិថិជនបានក្នុងសងចំនួនទឹកប្រាក់$២០០,០០០ មានន័យថាអតិថិជន អាចស្នើសុំឥណទាន ដែលមានចំនួន $២០០,០០០ ឬក៏តិចជាងនេះទៅតាមតំរូវការរបស់ពួកគេ។ ឥណទានខ្នាតតូច និងមធ្យមធ្វើអោយអតិថិជនអាចមានលទ្ធភាពពង្រីកអាជីវកម្មរបស់ខ្លួនដូចជា បង្កើនទុនកង្វិល ផ្លាស់ផ្តូរគ្រឿងម៉ាស៊ីន ឬបន្ថែមនូវមធ្យោបាយដឹកជញ្ជូនជាដើម។

ការបង្កើតឥណទានខ្នាតតូច និងមធ្យមនេះឡើង ដើម្បីផ្តល់មូលនិធិជូនដល់អាជីវករក្នុងការផ្គត់ផ្គង់ ការប្រើប្រាស់គ្រប់ប្រភេទអាជីវកម្ម រួមមានផលិតផលកសិកម្ម និងតម្រូវការផ្សេងៗទៀតជាច្រើន។

### ៣.២.១. អតិថិជនគោលដៅ

ធនាគារកាណាឌីយ៉ា ក.អ ធ្វើការកំណត់នូវអតិថិជនគោលដៅ របស់ខ្លួនដូចខាង ក្រោម៖

- សុំខ្ចីជាលក្ខណៈគ្រួសារឬឯកត្តជនសំរាប់សកម្មភាពអាជីវកម្មផ្ទាល់ខ្លួន និងមានលក្ខណៈជារូបវន្តបុគ្គល។

- សហគ្រាស ឬក្រុមហ៊ុនឯកកម្មសិទ្ធិ (Sole Proprietorship): ដែលបានបង្កើតឡើង និងចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់បែបបទស្របច្បាប់ និងធ្វើប្រតិបត្តិការ ដោយបុគ្គលម្នាក់ជាម្ចាស់មូលធន និងទទួលខុសត្រូវគ្មានកម្រិត។
- សហគ្រាស ឬក្រុមហ៊ុនសហកម្មសិទ្ធិ(Partnership): ដែលបានបង្កើតឡើង និងចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់បែបបទស្របច្បាប់ ជានីតិបុគ្គលទទួលខុសត្រូវចាប់ពី២នាក់ ឬច្រើននាក់ភាគហ៊ុននិកជាអ្នកកាន់កាប់ចំណែកភាគហ៊ុនរបស់ខ្លួន។
- សហគ្រាស ឬក្រុមហ៊ុនសាជីវកម្ម(Corporation): ដែលបានបង្កើតឡើង និងចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់បែបបទស្របច្បាប់ និងត្រូវបានផ្តល់សិទ្ធិតាមផ្លូវច្បាប់ ជានីតិបុគ្គលដោយឡែកពីសិទ្ធិរបស់ម្ចាស់ភាគហ៊ុន។ សហគ្រាស ឬក្រុមហ៊ុន សាជីវកម្ម មានវិនិយោគច្រើនចូលរួមវិនិយោគ និងជាអ្នកកាន់កាប់ចំណែកភាគហ៊ុនរបស់ខ្លួន ដែលបានវិនិយោគ។

### ៣.២.២. លក្ខខណ្ឌក្នុងការផ្តល់ឥណទាន

លក្ខខណ្ឌនៃការផ្តល់ឥណទានរួមមានៈ សហគ្រាសខ្នាតតូច និងមធ្យម ដែលកំពុងដំណើរការនាពេលបច្ចុប្បន្ន ហើយមានទុនកើនឡើងជារៀងរាល់ឆ្នាំមានទីផ្សារក្នុងកំរិតមួយ ដែលអាចទទួលយកបាន។ ធនាគារកាណាឌីយ៉ា ក.អ មានលក្ខខណ្ឌមួយចំនួន ដើម្បីផ្តល់ឥណទានជូនដល់អតិថិជនទាំងអស់ដូចជា៖

- អតិថិជនត្រូវមានទីលំនៅអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមានការបញ្ជាក់ពីអាជ្ញាធរក្នុងតំបន់ដែលអតិថិជនរស់នៅ និងភ្ជាប់មកជាមួយនៅសៀវភៅស្នាក់នៅសៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណ។
- មានមុខរបរច្បាស់លាស់ និងមានប្រភពប្រាក់ចំណូល ដែលអាចមានលទ្ធភាពសងត្រលប់មកវិញ។
- ចំពោះអចលនទ្រព្យដាក់បញ្ចាំដូចជា ដីធ្លី ផ្ទះ ឬក៏ទ្រព្យផ្សេងទៀតដែលមានតំលៃស្មើ។

## ៣.៣.នីតិវិធីក្នុងការផ្តល់ឥណទានខ្នាតតូច និងមធ្យម

### ៣.៣.១. ការដាក់ពាក្យសុំចុះឈ្មោះប្រើប្រាស់សេវាកម្មឥណទាន

អតិថិជនដែលមានបំណងប្រើប្រាស់នូវសេវាកម្មឥណទាន ត្រូវមកទំនាក់ទំនងនូវសាខាណាមួយនៃធនាគារកាណាឌីយ៉ាក.អដែលមានទីតាំងស្ថិតនៅជិតតំបន់ របស់អតិថិជនបំផុត។ ការស្នើសុំប្រើប្រាស់សេវាត្រូវបង្ហាញដល់មន្ត្រីឥណទាន ដើម្បីរៀបចំនូវឯកសារបឋម ដែលពាក់ព័ន្ធទៅនឹងសេវាឥណទាននិងរាយការណ៍ជាបន្ត ទៅកាន់មន្ត្រីឥណទានដើម្បីធ្វើការ និងរាយការណ៍

បញ្ជាក់ទៅកាន់គណកម្មាធិការឥណទាន។ ក្នុងករណីនេះអតិថិជនត្រូវមានការបង្ហាញអំពីទ្រព្យបញ្ចាំ ទំហំទឹកប្រាក់កម្ចីរយៈពេលខ្ចី គម្រោងអាជីវកម្មដែលកត់ត្រា និងធ្វើរបាយការណ៍ដោយមន្ត្រីឥណទានជាពិសេសត្រូវចុះហត្ថលេខាលើទម្រង់អនុញ្ញាតឲ្យធនាគារអាចពិនិត្យមើលព័ត៌មាន ឬប្រវត្តិរូបអតិថិជនដែលស្នើសុំខ្ចីប្រាក់នៅធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាល។ ការស្នើរសុំខ្ចីត្រូវភ្ជាប់មកជាមួយនូវ ឯកសារមួយចំនួនដូចជាៈ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកស្នើរសុំលិខិតឆ្លងដែន (ត្រូវមានបញ្ជាក់ពីក្រសួងការបរទេសនៃប្រទេសណាមួយ បើសិនមិនមែនជាជនជាតិខ្មែរ) សៀវភៅគ្រួសារ លិខិតបញ្ជាក់កម្មសិទ្ធិដីធ្លី សម្រាប់ជាទ្រព្យបញ្ចាំ (ត្រូវជាប័ណ្ណកម្មសិទ្ធដែលចេញដោយ ក្រសួងដែនដី នគររូបនីកម្ម សំណង់ និងសុរិយោដី ឬហៅថា ប្លង់រឹង)។

សម្គាល់ៈ ក្នុងការស្នើរសុំឥណទានមួយអាចប្រើប្រាស់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនពីរ ឬលើសពីនេះ បើសិនជាទ្រព្យបញ្ចាំមិនមែនជាកម្មសិទ្ធិឯកបុគ្គល ឬចូលរួមខ្ចីជាឥណទានក្រុម។

### ៣.៣.២. ការចុះវាយតម្លៃ និងសិក្សាពីអតិថិជន

ភ្នាក់ងារឥណទានត្រូវចុះវិភាគ និងជួបផ្ទាល់ដល់ផ្ទះអតិថិជន ដើម្បីសាកសួរព័ត៌មានមកបំពេញក្នុងទម្រង់របាយការណ៍វាយតម្លៃឥណទាន (Credit Appraisal Report) ដែលរៀបចំរួចជាស្រេចដោយក្រុមធុរៈកិច្ចរបស់ធនាគារទី១ (BBG1-Business Banking Group) ដែលកាន់កាប់ផ្នែកឥណទានខ្នាតតូច និងមធ្យម (SME Loan)។ ក្រៅពីនេះត្រូវសាកសួរព័ត៌មានពីប្រភពខាងក្រៅ ឬអាជ្ញាធរមូលដ្ឋាន ដើម្បីជៀសវាងហានិភ័យកើតឡើង ក្រោយពេលសិក្សាមិនច្បាស់។

មិនត្រូវតែចុះវិភាគផ្ទាល់ជាមួយអតិថិជនដែលមានតម្រូវការឥណទាន បុគ្គលផ្នែកឥណទានត្រូវយកទម្រង់បែបបទដែលមានចុះហត្ថលេខា ពីអតិថិជនសម្រាប់ការអនុញ្ញាតឲ្យមានការត្រួតពិនិត្យប្រវត្តិ ទៅធនាគារជាតិនៃកម្ពុជាដែលតម្កល់ទុកប្រវត្តិរូបឥណទានដើម្បីត្រួតប្រវត្តិរូបនិងអាចបង្ហាញអតិថិជន ដែលកំពុងសិក្សាធ្លាប់មានជំពាក់បំណុលធនាគារផ្សេងឬទេ? ឬមានប្រវត្តិធ្លាប់បង់មិនទៀងទាត់ដែរឬទេ?

ក្នុងដំណាក់កាលនេះ ប្រសិនបើអតិថិជនមានទ្រព្យបញ្ចាំមិនសមស្របដែលមិនធានាលើឥណទានឬប្រវត្តិរូបរបស់អតិថិជនស្នើសុំឥណទានជាបុគ្គល ជាប់បំណុលនៅធនាគារផ្សេងទៀតមិនទាន់បង់បញ្ចប់ឬធ្លាប់មានប្រវត្តិបង់សងត្រលប់មិនទាន់ពេលវេលា នោះឥណទាននេះត្រូវបានបដិសេធ និងជម្រាបត្រលប់ទៅកាន់អតិថិជនវិញដោយមន្ត្រីឥណទាន។

តែប្រសិនបើក្នុងដំណាក់កាលនេះមានការវិភាគឃើញ ថាអតិថិជនមានស្ថានភាពអាជីវកម្មល្អប្រសើរទ្រព្យបញ្ចាំមានទីតាំងល្អ ជាពិសេសប្រវត្តិរបស់អតិថិជនមានបំណង ស្នើរសុំប្រើប្រាស់សេវាឥណទានមានលក្ខណៈប្រសើរ ដោយមិនដែលមានការបង់ត្រលប់យឺតយ៉ាវ ឬស្ថិតក្នុងបញ្ជី

កំណាត់សម្គាល់បុគ្គលក្នុងបំណងនោះទេ មន្ត្រីឥណទានត្រូវមានការរាយការណ៍បន្ត ទៅកាន់គណៈកម្មាការ ឥណទាននូវព័ត៌មានពិតប្រាកដរបស់អតិថិជន ជាពិសេស តម្លៃទ្រព្យបញ្ចាំ ដែលវាយតម្លៃក្នុងចន្លោះ ៧០%ដល់ ៨០%នៃតម្លៃទីផ្សារសម្រាប់រក្សាគំលាតហានិភ័យ។

**៣.៣.៣. ការចរចារអត្រាការប្រាក់ និងរយៈពេលសងត្រលប់**

ក្នុងដំណាក់កាលនេះក្រោយពីទទួលព័ត៌មានពីមន្ត្រីឥណទាន គណៈកម្មាធិការ ឥណទាន និងធ្វើការកំណត់ ទំហំឥណទាន អត្រាការប្រាក់ និងរយៈពេលសងត្រលប់ ដែលជាព័ត៌មានបឋមជូនដល់អតិថិជនវិញដើម្បីធ្វើការចរចារ។

ប្រសិនមានការយល់ព្រមចំពោះការសម្រេច និងយល់ព្រមពីអតិថិជន សំណើរ និងការយល់ព្រមដាក់ជូនអង្គប្រជុំនៃគណៈកម្មាចិការឥណទានដើម្បីចុះហត្ថលេខា និងផ្តល់ការសម្រេចចុងក្រោយ។

តែប្រសិនបើមិនមានការយល់ព្រមពីអតិថិជន ក្នុងដំណាក់កាលនេះអតិថិជនអាចធ្វើការស្នើរសុំនូវលក្ខខណ្ឌដូចជា ស្នើសុំបន្ថយអត្រាការប្រាក់ ស្នើរសុំបន្ថែមចំនួនឥណទាន ឬធ្វើការបន្ថែមរយៈពេលបង់សងត្រឡប់នៃឥណទានជាដើម។ ហើយសំណើរទាំងនេះមានដាក់ជូនអង្គប្រជុំនៃគណៈកម្មាធិការឥណទានសម្រាប់ប្រជុំសម្រេច។

**៣.៣.៤. ការប្រជុំសម្រេចឥណទានស្របតាមការវាយតម្លៃ**

ក្នុងការប្រជុំនៃគណៈកម្មាធិការឥណទាន ដែលមានសមាជិក ពី១០ទៅ១២រូប និងយោងលើគោលការណ៍មតិភាគច្រើន។ បើសិនលក្ខខណ្ឌឥណទានត្រូវបានយល់ព្រមពីអតិថិជនគណៈកម្មាធិការឥណទាន ត្រូវចុះហត្ថលេខាសម្រេចលើ របាយការណ៍តម្លៃឥណទាន។ តែប្រសិនបើអតិថិជនមានការស្នើរសុំបន្ថែម ដូចមានបង្ហាញក្នុងដំណាក់កាលទីបី គណៈកម្មាធិការឥណទានត្រូវមានការប្រជុំពិភាក្សា និងសម្រេចតាមមតិភាគច្រើន ដើម្បីផ្តល់ព័ត៌មានចុងក្រោយទៅកាន់អតិថិជនវិញ។

**៣.៣.៥. ការផ្តល់ព័ត៌មានក្រោយការអនុម័ត**

ការផ្តល់ព័ត៌មានចុងក្រោយទៅកាន់អតិថិជនត្រូវធ្វើឡើង ដោយមន្ត្រីឥណទានជូនដល់អតិថិជន ក្នុងដំណាក់កាលនេះអាចមានទម្រង់សម្រេចចិត្តពីរករណីកើតឡើងៈ

- ប្រសិនបើអនុម័តចុងក្រោយត្រូវបានយល់ព្រមពីអតិថិជន នោះនីតិវិធីត្រូវបានបញ្ជូនទៅកាន់ដំណាក់កាលចុងក្រោយ (ដំណាក់កាលទី៦) គឺធ្វើកិច្ចសន្យាឥណទាន ធ្វើប្រាតិភោគទ្រព្យបញ្ចាំ និងផ្តល់ប្រាក់កម្ចី។
- ប្រសិនបើអនុម័តចុងក្រោយនៅតែមិនត្រូវបានយល់ព្រមពីអតិថិជន។ អតិថិជនអាចដាក់សំណើរបន្តទៅកាន់ គណៈកម្មាធិការឥណទាន ដើម្បីប្រជុំសម្រេចម្តងទៀតរហូត

ដល់មានការយល់ព្រមពីភាគីធនាគារ និងភាគីអតិថិជន និងធ្វើការអនុម័តចុងក្រោយ ដើម្បីឈានចូលដំណាក់កាលទី៦ ដែលជាដំណាក់កាលចុងក្រោយ។

- ប្រសិនបើការអនុម័ត និងការស្នើរសុំនៅតែមិនអាចរកចំនុចប្រសព្វគ្នាបាន ឬមានការស្នើរ សុំ ឬករណីលើកក្នុងអង្គប្រជុំច្រើនដង ហើយនៅតែពុំមានចំណុចប្រសព្វដោយសារតែការស្នើរសុំឥណទាន មានហានិភ័យខ្ពស់ ឬអតិថិជនយល់ថាទ្រព្យបញ្ចាំអាចមានលទ្ធភាពកម្ចីច្រើនជាងនេះ ឬក៏ក្នុងករណីអត្រាការប្រាក់ ឬរយៈពេលខ្ចីមិនសមស្របឥណទានមួយនេះក៏អាចឈានដល់ដំណាក់កាលបដិសេធផងដែរ។

### ៣.៣.៦. ការធ្វើកិច្ចសន្យាឥណទាន ធ្វើប្រាតិភោគទ្រព្យបញ្ចាំ និងផ្តល់ប្រាក់កម្ចី

ដំណាក់កាលនេះត្រូវបន្តពីដំណាក់កាលទី៥ ក្នុងករណី (១) និង (២) តែប៉ុណ្ណោះ និងមិនអាចបន្តក្នុងករណី(៣) បាននោះទេ។ ដំណាក់កាលចុងក្រោយនេះគូរភាគីធនាគារ និងអតិថិជនត្រូវធ្វើកិច្ចសន្យាក្នុងការខ្ចីដោយមានទំហំឥណទានអត្រាការប្រាក់ និងរយៈពេលខ្ចីសមស្របដូចមានការចរចាររវាងគូរភាគី។ រីឯទ្រព្យបញ្ចាំធនាគារត្រូវតម្កល់ប័ណ្ណសិទ្ធិដែលជាច្បាប់ដើមសម្រាប់បញ្ចាំ និងមានកិច្ចសន្យា(មាននៅក្នុងឧបសម្ព័ន្ធ១)ទុកជាថ្នូរទៅនឹងឥណទាន និងដាក់សំណើរធ្វើប្រាតិភោគ នូវទ្រព្យបញ្ចាំទៅកាន់មន្ទីរដែនដីសំណង់ និងនគររូបនីយកម្មដើម្បីរារាំងការដូរទ្រព្យមួយនេះដែលធ្វើឡើងដោយបុគ្គលម្ចាស់ទ្រព្យ។ ក្នុងធនាគារដើម្បីបើកជូនម្ចាស់គម្រោង ពេលមានការខូចខាតក្នុងកំឡុងពេលធានា។ ធ្វើបែបនេះដើម្បីធានាទំនុកចិត្តម្ចាស់គម្រោងជាមួយនឹងអ្នកទទួលគម្រោង។

ដើម្បីស្នើរសុំលិខិតធានាទប់ស្កាត់ទឹកប្រាក់នេះ ភាគីជាអ្នកទទួលអនុវត្តគម្រោងត្រូវទាមទារឲ្យមានឯកសារដូចតទៅៈ

- កិច្ចសន្យា ឬកិច្ចព្រមព្រៀងគូរភាគី (មាននៅក្នុងឧបសម្ព័ន២)។
- ទម្រង់បែបបទនៃលិខិតធានា លើការទប់ស្កាត់ទឹកប្រាក់។
- ឯកសារផ្សេងៗទៀតដូចជាតម្រូវការប្រាក់កម្ចី និងដំណើរការនៃកម្ចីផងដែរ។
- បន្ទុកធម្មតាគឺ ១% ឬ ១.៥% ក្នុងមួយឆ្នាំ (វាអាចត្រូវបានផ្លាស់ប្តូរ ដោយផ្អែកលើការអនុម័តរបស់គណកម្មាធិការឥណទាន)។

## ៣.៤.ដំណើរការបង់សងត្រឡប់

ដំណើរការបង់សងត្រឡប់ជាដំណាក់កាលបន្តពីការបញ្ចេញប្រាក់ទៅកាន់អតិថិជន និងជាទូទៅត្រូវបានអនុវត្តនៅចុងកាលបរិច្ឆេត ចន្លោះរវាងមួយខែម្តង។ តែនីតិវិធីក្នុងការបង់សងត្រឡប់

ត្រូវបានកំណត់ក្នុងទម្រង់ខុសគ្នារួមមាន និងមានការគណនាដោយប្រើប្រាស់បច្ចេកទេសមាន បង្ហាញក្នុងចំនុចខាងក្រោម។

### ៣.៤.១.របៀបគិតប្រាក់អនាគតរួមទាំងការប្រាក់

ការគណនាចំនួនប្រាក់សង នៅពេលអនាគតរួមទាំងការប្រាក់ សម្រាប់បង្ហាញដល់អតិថិជន នូវចំនួនប្រាក់ដែលអតិថិជនត្រូវសងសរុប ក្រោយពេលទទួលបានឥណទាន។ ការប្រើប្រាស់រូបមន្ត នេះអាចគណនាបានថាតើការប្រាក់ សម្រាប់ចំនួនឥណទានមានចំនួនប៉ុន្មាន? ជាទូទៅធម្មតាតាម រូបមន្តបែបនេះគណនាសម្រាប់ឥណទាន រយៈពេលខ្លីតែប៉ុណ្ណោះ ព្រោះអតិថិជនត្រូវសងនៅចុង គ្រា។

របៀបគិតការប្រាក់អនាគតរួមទាំងការប្រាក់ត្រូវបានអនុវត្តដោយរូបមន្តដូចខាងក្រោម៖

$$FV_n=P_o[1+(i \times n)]$$

- ដោយ $FV_n$ ជាប្រាក់អនាគតរួមទាំងការប្រាក់ (Future Value)
- $P_o$ ជាតម្លៃឥណទានដែលទទួលបច្ចុប្បន្ន (Present Value / Loan Amount)
- i ជាអត្រាការប្រាក់ (Interest Rate)
- n រយៈពេលនៃការខ្ចី (Number of Time period)

### ៣.៤.២.របៀបសងការប្រាក់ថេរ

ការគណនាការប្រាក់របៀបនេះក្នុងករណីដែលអតិថិជន មានបំណងបង់សងអត្រាការប្រាក់ ថេរ ហើយនៅចុងគ្រាទើបធ្វើការបង់នូវប្រាក់ដើមឥណទានត្រឡប់វិញរួមទាំងការប្រាក់ចុងគ្រាផង ដែរ។

ការគណនាការប្រាក់ត្រូវបានអនុវត្តដោយរូបមន្ត៖

$$I = (C \times i \times N) / 360$$

ដោយ

- I ជាការប្រាក់ដែលត្រូវទទួលជារៀងរាល់គ្រាដោយធនាគារ (Interest Payment)
- C ជាចំនួនប្រាក់ដើមជាក់ស្តែង (Actual Capital during the period)
- i អត្រាការប្រាក់ក្នុងប្រចាំឆ្នាំ (Annual Interest Rate)

- N ចំនួនថ្ងៃត្រូវទទួល (Number of Day for Interest calculation)
- 360 ចំនួនថ្ងៃក្នុងមួយឆ្នាំគិតតាម Fiscal year (Number of day per year by fiscals year)

### ៣.៤.៣.ការសងរំលស់ប្រាក់ដើម និងការប្រាក់

ការរំលស់ប្រាក់ដើម រួមទាំងការប្រាក់ជារបៀបគណនាមួយប្រើប្រាស់ជាធម្មតាសម្រាប់ឥណទាន ដែលអតិថិជនមានបំណងចង់ធ្វើការសងត្រឡប់ក្នុងបរិមាណទឹកប្រាក់ស្មើរគ្នារហូតដល់ចុងកាលបរិច្ឆេត និងរក្សាសមតុល្យចុងក្រោយស្មើរសូន្យ។

បរិមាណបង់រំលស់រៀងរាល់កាលបរិច្ឆេត

$A = \frac{PV}{N}$ នាំឲ្យ $I_i = A + (PV_i \times r)$

ដោយ

- A បរិមាណដែលត្រូវរំលស់រៀងរាល់គ្រា (Amortization Amount)
- PV ជាចំនួនកម្ចីបានទទួលនៅគ្រាដំបូង
- n ជាចំនួនគ្រាដែលព្រមព្រៀងសង
- $I_i$ ជាប្រាក់ដែលត្រូវសងក្នុងគ្រានីមួយៗ
- $PV_i$ សមតុល្យក្នុងគ្រានីមួយៗ
- r ជាអត្រាការប្រាក់ដែលកំណត់

### ៣.៤.៤.ការសងរំលស់ប្រាក់ដើម និងប្រាក់ថេរ (Flat Amortization)

ការសងរំលស់ប្រាក់ដើម និងការប្រាក់ថេរ ជារបៀបសងមួយមានលក្ខណៈថេរទាំងការប្រាក់រំលស់ប្រាក់កម្ចីទាំងការប្រាក់។ ដូចនេះវាទាមទារឲ្យអ្នកខ្ចីសងទៅម្ចាស់បំណុលក្នុងចំនួនថេររាល់គ្រាចុងក្រោយ។ ការសងរំលស់ប្រាក់ដើម និងការប្រាក់ថេរត្រូវបានគណនាក្នុងរូបមន្តៈ

$I = P \times r$ នាំឲ្យ $A = \frac{n \times 1 \times PV}{n}$

ដោយ

- I ជាការប្រាក់ដែលសងប្រចាំគ្រា
- PV ជាចំនួនកម្ចីបានទទួលបាន
- r ជាអត្រាការប្រាក់ព្រមព្រៀងក្នុងគ្រានីមួយៗ

- A ជាទឹកប្រាក់សរុបដែលត្រូវសងក្នុងគ្រានីមួយៗ
- n ជាចំនួនគ្រាសរុប

## ៣.៥. ការវាយតម្លៃឥណទាន5C's

មន្ត្រីឥណទានមានភារកិច្ចចុះទៅដល់លំនៅឋាន និងទីកន្លែងប្រកបអាជីវកម្មរបស់អតិថិជន ដោយផ្តោតលើការទុកដាក់លើការសិក្សា-វាយតម្លៃកត្តាសំខាន់ៗជាគន្លឹះមួយចំនួនដូចខាងក្រោម៖

### ៣.៥.១. ចរិតលក្ខណ: (Character)

ត្រូវអង្កេតនិងប្រមូលព័ត៌មានអំពីប្រវត្តិ អត្តចរិត លក្ខណៈសម្បត្តិ សមត្ថភាព គ្រប់គ្រង ជំនាញ បទពិសោធន៍ ទីផ្សារ កេរ្តិ៍ឈ្មោះ ចេតនា សងបំណុល។ល។ ដើម្បីកំណត់ អំពីសុច្ចរិតភាព និងហានិភ័យអត្តចរិត។ ផ្អែកលើការសិក្សានេះ មន្ត្រីឥណទាន ត្រូវរិះរកមធ្យោបាយ បញ្ចៀស ហានិភ័យទៅតាមស្ថានភាពនីមួយៗ។[7]

### ៣.៥.២. ដើមទុន (Capital)

វាយតម្លៃស្ថាភាពហិរញ្ញវត្ថុក្នុងមុខរបរ ដើម្បីកំណត់ពីស្ថានភាពដើមទុន និងប្រភពទុន។ ការវាយតម្លៃដើមទុន ត្រូវប្រមូលព័ត៌មានអំពីមុខរបរដែលជា ទិន្នន័យសម្រាប់រៀបចំគម្រោងជំនួញ របស់អតិថិជន ដើម្បីត្រួតពិនិត្យគោលបំណងនៃការប្រើប្រាស់ប្រាក់កម្ចី។

### ៣.៥.៣. សមត្ថភាព (Capacity)

ត្រូវធ្វើការសិក្សាអំពីលំហូរសាច់ប្រាក់របស់អតិថិជន ដោយផ្អែកលើប្រាក់ចំណូលពីមុខរបរ (ចំណេញ-ខាត) ទីផ្សារ សកម្មភាពជំនួញ និងប្រភពចំណូលផ្សេងៗទៀតដែលអាចធ្វើការវាស់វែង បានតាមប្រចាំថ្ងៃ ប្រចាំខែ ប្រចាំរដូវកាល ឬប្រចាំឆ្នាំឲ្យបានច្បាស់លាស់ត្រឹមត្រូវអាចជឿជាក់បាន ដើម្បីធ្វើការប៉ាន់ប្រមាណពីតម្រូវការ ឥណទាន រយៈពេលឥណទាន និងលទ្ធផលសងប្រាក់។ ការសិក្សាវិភាគអំពីសមត្ថភាពសង ត្រូវឆ្លុះបញ្ចាំងពី ប្រវត្តិលទ្ធភាពនៃប្រតិបត្តិការមុខរបរគ្រាមុនរបស់អតិថិជន។

ការកំណត់លទ្ធភាពសងត្រូវធ្វើឡើងតាមរយៈការកំណត់ ប្រាក់ចំណេញ ឬប្រភពចំណូល ផ្សេងៗទៀតមិនមែនជំនួញ ឬប្រាក់បៀវត្ស និងចំណាយជាមធ្យមប្រចាំខែក្នុងគ្រួសារ។

ការគណនាពីលទ្ធភាពសងរបស់អតិថិជន ផ្អែកតាមប្រភពចំណូលពីមុខរបរត្រូវអនុវត្តតាម រូបមន្ត៖

$$\text{លទ្ធភាព} = \frac{(\text{ប្រាក់ចំណាយ} - \text{ចំណាយប្រចាំខែក្នុងគ្រួសារ})}{n}, \text{ដែល} n \epsilon R*+$$

[7] LOAN PROCES 2014 របស់ធនាគារកាណាឌីយ៉ា ក.អ ទំព័រ ១៣៩-១៤១

បើ

n = ១.៥ សម្រាប់អ្នកដាក់ពាក្យដែលផ្តល់ព័ត៌មានគ្រប់គ្រាន់ អាចទុកចិត្តបានទ្រព្យធានា ឬអ្នកធានាមានសក្តានុពល។

n =២ សម្រាប់អ្នកដាក់ពាក្យដែលផ្តល់ព័ត៌មានគ្រប់គ្រាន់ ហើយអាចទុកចិត្តបាន។

n = ៣ សម្រាប់អ្នកដាក់ពាក្យមុខជំនួញ ទើបតែចាប់ផ្តើមអាចមានបញ្ហាចំពោះការសងមានហានិភ័យខ្ពស់។

ឬម្យ៉ាងទៀតគេអាចកំណត់លទ្ធភាពរបស់អតិថិជនតាមរូបមន្តៈ

| លទ្ធភាពសង = (ប្រាក់ចំណេញ - ចំណាយប្រចាំខែក្នុងគ្រួសារ) x |
|---|

- ករណីប្រភពចំណូលជាប្រាក់បៀវត្ស លទ្ធភាពរបស់អ្នកដាក់ពាក្យ ត្រូវបានកំណត់មិនលើសពី៥0% នៃប្រាក់បៀវត្ស។
- ការកំណត់ទំហំឥណទានតាមលទ្ធភាពសងត្រូវបានធ្វើការប៉ាន់ស្មាន ដោយប្រើរូបមន្តដូចខាងក្រោមៈ

| ទំហំនៃតម្រូវការពិតប្រាកដ = (លទ្ធភាពសង x រយៈពេលខ្ចី) - កាប្រាក់សរុប |
|---|

**៣.៥.៤. ទ្រព្យធានា** (Collateral)

ការវាយតម្លៃទ្រព្យសម្បត្តិដាក់ធានាសុវត្ថិភាពឥណទាន ត្រូវធ្វើការត្រួតពិនិត្យដល់ទីកន្លែងជាក់ស្តែងដោយពិចារណាតាមពាក្យ REALTOR ដូចខាងក្រោមៈ

- Right collateral: ទ្រព្យសម្បត្តិស្របច្បាប់
- Estimated value of collateral: តម្លៃប៉ាន់ស្មាននៃទ្រព្យដាក់ដម្កល់
- Ability to sell collateral: លទ្ធភាពដែលអាចលក់ដូរបាន
- Location of collateral: ទីតាំងរបស់ទ្រព្យដាក់តម្កល់
- Type of collateral: ប្រភេទទ្រព្យដាក់តម្កល់
- Ownership: ភាពជាម្ចាស់កម្មសិទ្ធនៃទ្រព្យដាក់តម្កល់
- Risk of collateral: ហានិភ័យនៃទ្រព្យដាក់តម្កល់

ការវាយតម្លៃទ្រព្យដាក់ធានាត្រូវអនុវត្តតាមនីតិវិធីដាច់ដោយឡែក។

**៣.៥.៥. លក្ខខណ្ឌ** (Conditions)

ត្រូវធ្វើការសិក្សា និងវិភាគអំពីហានិភ័យទាំងឡាយ ដែលអាចបង្កជាហានិភ័យនិងជះឥទ្ធិពលដល់ការសងប្រាក់របស់អតិថិជន ដូចជាហានិភ័យលើការគ្រប់គ្រង ហានិភ័យទីផ្សារ ហានិភ័យហិរញ្ញវត្ថុ ហានិភ័យទ្រព្យធានា និងហានិភ័យលើមុខរបរ។ល។ ឬអាចដាក់លក្ខខណ្ឌបន្ថែមសម្រាប់ធានាសុវត្ថិភាពឥណទានដូចជា តម្រូវឲ្យមានអ្នកធានា តម្រូវឲ្យដាក់ទ្រព្យធានាបន្ថែម តម្រូវឲ្យការកែប្រែនូវ ចំនុចណាមួយដែលធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពសង ឬបរិស្ថាន។ល។

គ្រប់ចំនុចទាំងប្រាំដែលបានរៀបរាប់ខាងលើត្រូវធ្វើការសន្និដ្ឋាន ដោយអនុលោមតាមគោលការណ៍ និងលក្ខខណ្ឌឥណទាន ព្រមទាំងស្វែងរកចំនុចខ្លាំង ចំណុចខ្សោយដើម្បីកំណត់លទ្ធភាព ខ្ចី-សង និងសមត្ថភាពរ៉ាប់រងបំណុលរបស់អ្នកខ្ចីឲ្យបានត្រឹមត្រូវ។

## ៣.៦. លក្ខខណ្ឌកំណត់ទំហំឥណទាន និងកម្រិតសុវត្ថិភាព

### ៣.៦.១. ការកំណត់ទំហំឥណទាន

ការកំណត់ទំហំឥណទាននីមួយៗផ្អែកលើមូលដ្ឋានបីយ៉ាងគឺ៖

- លទ្ធភាពសង: ត្រូវកំណត់ទៅតាមលទ្ធភាពសងមិនលើសពី ៦៧% នៃប្រាក់ចំណេញសុទ្ធបន្ទាប់ពីផាត់ប៉ាន់ស្មានចំណាយគ្រួសាររបស់អ្នកសុំខ្ចី។
- ទ្រព្យដាក់ធានា: ទំហំឥណទានត្រូវ អនុលោមតាមលក្ខខណ្ឌនៃការដាក់ទ្រព្យសម្បត្តិធានាបញ្ចាំង។
- រយៈពេលខ្ចី: រយៈពេលប្រសិទ្ធភាពនៃការប្រើប្រាស់ទុន និងការផលិតចំណូល។

### ៣.៦.២. កម្រិតសុវត្ថិភាព

ទំហំឥណទានដែលកំណត់ផ្អែកតាមទ្រព្យដាក់ធានា ឬបញ្ចាំត្រូវបានកំណត់ទៅតាមប្រភេទនៃទ្រព្យដាក់ធានា ឬបញ្ចាំដូចខាងក្រោម៖

**ករណីដាក់ធានាជាដី និងផ្ទះ ឬអាគារ**

- **ករណីដី និងផ្ទះ ឬអាគារមានលិខិតសម្គាល់កម្មសិទ្ធជាប្រភេទប្លង់រឹង៖**

**ទំហំឥណទានធៀបជាមួយទ្រព្យដាក់ធានា:** មិនត្រូវលើស ៨០% នៃតម្លៃប៉ាន់ប្រមាណទ្រព្យសម្បត្តិដែលបានដាក់ធានា។

**កម្រិតបញ្ជាក់លើកិច្ចសន្យាដាក់ធានាពីអាជ្ញាធរដែនដី:** តម្រូវឲ្យមានការចុះហត្ថលេខា និងបោះត្រាបញ្ជាក់ដឹងលឺដល់អាជ្ញាធរមូលដ្ឋាន ភូមិ ឃុំសង្កាត់ ឬក្រុង-ស្រុក-ខណ្ឌ តាមកម្រិតហានិភ័យដែលប៉ាន់ស្មាន។

**កម្រិតបញ្ជាក់លើកិច្ចសន្យាដាក់ធានាពីអាជ្ញាធរសមត្ថកិច្ច:** អាចតម្រូវ ឬមិនតម្រូវឲ្យចុះការិបន្ទុកដាក់ធានាពីមន្ទីរ ឬការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី រាជធានី ខេត្ត ក្រុង-ស្រុក-ខណ្ឌទៅតាមកម្រិតហានិភ័យដែលប៉ាន់ស្មាន។
ចំពោះទំហំឥណទានចាប់ពី ៣០,០០០ដុល្លារ ឡើងទៅតម្រូវឲ្យចុះការិបន្ទុកដាក់ធានាពីមន្ទីរ ឬការិយាល័យរៀបចំដែនដីនគររូបនីកម្មសំណង់ និងសុរិយោដីរាជធានី-ខេត្ត ក្រុង-ខណ្ឌទៅតាមសភាពជាក់ស្តែង។

- **ករណីដី និងផ្ទះ ឬអាគារមានលិខិតសម្គាល់កម្មសិទ្ធជាប្រភេទប្លង់ទន់៖**

**ទំហំឥណទានធៀបជាមួយទ្រព្យដាក់ធានា:**មិនត្រូវលើស ៧០% នៃតម្លៃប៉ាន់ ប្រមាណសម្បត្តិ ដែលបានដាក់ធានា។

**កម្រិតបញ្ជាក់លើកិច្ចសន្យាដាក់ធានាពីអាជ្ញាធរដែនដី:** តម្រូវឲ្យមានការចុះហត្ថលេខា និងបោះត្រាបញ្ជាក់ដឹងលឺដល់ អាជ្ញាធរមូលដ្ឋានភូមិ ឃុំ-សង្កាត់ ឬក្រុង-ស្រុក-ខណ្ឌ ទៅតាមកម្រិតហានិភ័យដែលប៉ាន់ស្មាន។

ករណីផ្សេងពីនេះ នាយិការនាយកដ្ឋានឥណទានខ្នាតតូច និងមធ្យមជាអ្នកសម្រេច។

**សោហ៊ុយថ្លៃរត់ការឯកសារឥណទាន**

ករណីអតិថិជានស្នើឲ្យធនាគារ ជួយរត់ការសំណុំឯកសារជំនួសមន្ត្រីឥណទានអាចជួយសម្របសម្រួលលើការរត់ឯកសារបញ្ជាក់ ពីអាជ្ញាធរមានសមត្ថកិច្ច តែអតិថិជនត្រូវបង់ថ្លៃចំណាយរត់ការឯកសារទាំងនោះតាមតម្លៃ ដែលបានចំណាយជាក់ស្តែង។ ចំណាយនេះមិនត្រូវឆ្លងកាត់គណនេយ្យរបស់ធនាគារឡើយ។

**ការទទួលយកទ្រព្យដាក់បញ្ចាំផ្សេងទៀត**

ទ្រព្យសម្បត្តិផ្សេងទៀតក្រៅពីការរៀបរាប់ខាងលើ អាចទទួលយកមកដាក់បញ្ចាំបានដោយផ្គួបផ្សំជាមួយទ្រព្យដាក់ធានាជាដី ឬផ្ទះ ឬអាគារ ឬគណនីប្រាក់បញ្ញើ សម្រាប់ឥណទានរូបវន្តបុគ្គល ដែលមានទំហំធំជាង ៦,០០០ដុល្លារអាមេរិក ឬសមមូល ប៉ុន្តែទ្រព្យសម្បត្តិនោះទោះជាមានតម្លៃខ្ពស់យ៉ាងណាក៏ដោយ ត្រូវវាយតម្លៃឲ្យបានច្បាស់លាស់អំពីអាយុកាលប្រើប្រាស់ និងបម្រែបម្រួលនៃហានិភ័យ ដើម្បីប៉ាន់ប្រមាណ លើការធានាសុវត្ថិភាពឥណទានធៀបទៅនឹងរយៈពេលនៃឥណទាននោះ។

**នាយិកានាយកដ្ឋានឥណទានខ្នាតតូច និងមធ្យម** ជាអ្នកសម្រេចក្នុងការទទួលយកទ្រព្យសម្បត្តិផ្សេងៗសម្រាប់ដាក់ធានាដោយមានសំណើរពីប្រធានមន្ត្រីឥណទាន និងនាយក/នាយិកាសាខាក្នុងករណីដែលពុំមានចែងក្នុការទទួលយកទ្រព្យសម្បត្តិដាក់បញ្ចាំខាងលើ។

**អំពីលទ្ធកម្មនៃទ្រព្យដាក់ធានា**

ទ្រព្យសម្បត្តិដាក់ធានារបស់អតិថិជន អាចជាកម្មវត្ថុនៃការធ្វើលទ្ធកម្មសម្រាប់បុគ្គលទូទៅ លើកលែងតែបុគ្គលិកធនាគារមួយចំនួនត្រូវបានហាមឃាត់ដូចជាៈ មន្ត្រីឥណទាន និងមន្ត្រីដោះស្រាយបំណុលដែលទទួលខុសត្រូវផ្ទាល់ចំពោះអតិថិជននោះ។ លទ្ធកម្មនៃទ្រព្យដាក់ធានាត្រូវបានធ្វើឡើងតាមលក្ខខណ្ឌដូចខាងក្រោមៈ

- អតិថិជន ឬម្ចាស់កម្មសិទ្ធនៃទ្រព្យដាក់ធានាព្រមព្រៀងប្រកាសលក់។
- មានការប្រកាសលក់ឡាយឡុងជាសាធារណៈដោយតុលាការ។

ការធ្វើលទ្ធកម្មនៃទ្រព្យដាក់ធានា ដោយកម្មករនិយោជិតធនាគារ ត្រូវតែបង្ហាញអំពីតម្លាភាពយ៉ាងច្បាស់លាស់។

## ៣.៧. ការត្រួតពិនិត្យឥណទាន និងតាមដានឥណទាន

### ៣.៧.១. ដំណើរការត្រួតពិនិត្យ

ដំណើរការត្រួតពិនិត្យត្រូវបានកំណត់ដោយចាប់ផ្តើមពី ពេលអតិថិជនដាក់ពាក្យចុះឈ្មោះសុំខ្ចីប្រាក់រហូតដល់ប្រាក់សំណងចុងក្រោយត្រូវបានប្រមូល។

កិច្ចការត្រួតពិនិត្យរួមមានៈ

- ការចុះបញ្ជីទទួលពាក្យសុំចុះឈ្មោះខ្ចីប្រាក់របស់អតិថិជន (មាននៅក្នុងឧបសម្ព័ន្ធ៣)។
- ការវាយតម្លៃឥណទាន (មាននៅក្នុងឧបសម្ព័ន្ធ៤)។
- ការបំពេញឯកសារឥណទាន។
- ការអនុម័តឥណទាន។
- ការបញ្ចេញឥណទាន។
- ការរៀបចំទុកដាក់ គ្រប់គ្រងឯកសារ។
- ការប្រមូលប្រាក់សំណង និងតាមដានលើប្រាក់សំណង។
- ការវិភាគឡើងវិញអំពីស្ថានភាពអ្នកខ្ចី។

### ៣.៧.២. ប្រព័ន្ធ និងមធ្យោបាយនៃការត្រួតពិនិត្យឥណទាន

**ប្រព័ន្ធត្រួតពិនិត្យឥណទាន**

ប្រព័ន្ធត្រួតពិនិត្យឥណទានមានគ្រប់ផ្នែកបណ្តាពាក់ព័ន្ធ ត្រូវតែបំពេញភារកិច្ចឲ្យបានល្អិតល្អន់ និងម៉ឺងម៉ាត់ដើម្បីមានលទ្ធភាពគ្រប់គ្រង និងកាត់បន្ថយបានជាអតិបរមា នូវហានិភ័យអំពីឥណទានមិនតែប៉ុណ្ណោះវានឹង ផ្តល់អត្ថប្រយោជន៍ដទៃទៀតជាច្រើន ក្នុងកិច្ចការធនាគារ។ ម្យ៉ាង

ទៀតជាការចាំបាច់ដែលត្រូវតែដឹងនូវបម្រែបម្រួលនៃហានិភ័យឥណទាន ដើម្បីឈានឆ្ពោះទៅចាត់វិធានការទាន់ពេលវេលា និងមានប្រសិទ្ធភាពក្នុការងារគ្រប់គ្រងគុណភាពឥណទានរបស់ធនាគារ។

ប្រព័ន្ធត្រួតពិនិត្យឥណទានរួមមាន៖

- ប្រព័ន្ធ MIS (Management Information System)
- គោលនយោបាយ នីតិវិធី និការណែនាំអំពីឥណទាន
- នាយកដ្ឋាន និងផ្នែកពាក់ព័ន្ធ៖

  រួមមាន នាយកដ្ឋានឥណទានខ្នាតតូច និងមធ្យម នាយកដ្ឋានហិរញ្ញវត្ថុនាយកដ្ឋានសវនកម្មផ្ទៃក្នុង ផ្នែកនីតិកម្ម និងផ្នែកគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម។
- ថ្នាក់មានសមត្ថកិច្ចគ្រប់គ្រងផ្ទាល់៖

  ⇨ នាយក-នាយិកា សាខាធនាគារ ប្រធានមន្ត្រីឥណទានសាខា។

ប្រព័ន្ធត្រួតពិនិត្យឥណទាន មានគោលការណ៍ណែនាំដាច់ដោយឡែកសម្រាប់អនុវត្ត។

- មន្ត្រីត្រួតពិនិត្យឥណទាន ឬមន្ត្រីដោះស្រាយបំណុល (ករណីចាំបាច់តម្រូវឲ្យមាន) ការដោះស្រាយបំណុល តម្រូវឲ្យមានគោលការណ៍ ដាច់ដោយឡែក ស្តីពីការដោះស្រាវបំណុល។

**មធ្យោបាយនៃការត្រួតពិនិត្យឥណទាន**

មធ្យោបាយនៃការត្រួតពិនិត្យឥណទានត្រូវធ្វើឡើងផ្អែកលើមូលដ្ឋានបី៖

- តាមរយៈប្រព័ន្ធបច្ចេកវិជ្ជា (MIS)
- ឯកសារ
- ការជួបសម្ភាសជាមួយអតិថិជន និងអ្នកពាក់ព័ន្ធ។

### ៣.៧.៣. ការត្រួតពិនិត្យឥណទាន

#### ៣.៧.៣.១. ការត្រួតពិនិត្យប្រចាំថ្ងៃ

ប្រើប្រាស់ប្រព័ន្ធ MSI តាមដាន ត្រួតពិនិត្យ សមតុល្យឥណទាន ដើម្បីគ្រប់គ្រងបរិមាណនិង គុណភាពឥណទានប្រចាំថ្ងៃ។

មន្ត្រីឥណទានត្រូវត្រួតពិនិត្យរបាយការណ៍សងប្រាក់ប្រចាំថ្ងៃ ចំពោះអតិថិជន ដែលខ្លួនកំពុងទទួលខុសត្រូវ។ មន្ត្រីដោះស្រាយបំណុល ត្រូវត្រួតពិនិត្យតាមដាន បញ្ជីខកខានសងប្រាក់ធ្ងន់ធ្ងរ បំណុលលុបចេញពីបញ្ជី និងការប្រមូលបំណុលប្រចាំថ្ងៃចំពោះអតិថិជនដែលខ្លួនទទួលខុសត្រូវ។

#### ៣.៧.៣.២. ការត្រួតពិនិត្យឥណទានតាមពេលកំណត់ (Periodic control)

ការត្រួតពិនិត្យឥណទានតាមពេលកំណត់ អនុវត្តតែចំពោះឥណទានទោល។ រៀងរាល់ប្រាំមួយខែម្តង មន្ត្រីឥណទានត្រូវចុះទៅដល់កន្លែងមុខរបរ និងគេហដ្ឋានអតិថិជនដើម្បីត្រួតពិនិត្យដោយផ្តោតការយកចិត្តទុកដាក់លើ[8]៖

- ការប្រើប្រាស់ប្រភពទុនសកម្មដំណើរការមុខរបរ និងទំនោរនៃមុខរបរ។។
- ស្ថានភាពហិរញ្ញវត្ថុ។
- ស្ថានភាពទ្រព្យធានា ដូចជាការប្រែប្រួលតម្លៃ ទំហំ ឬភាពមិនប្រក្រតីចំពោះកម្មសិទ្ធប្រភេទទ្រព្យសម្បត្តិ។

ការត្រួតពិនិត្យឥណទានតាមពេលកំណត់នេះ មន្ត្រីឥណទានត្រូវរៀបចំរបាយការណ៍ព្រមទាំងរក្សាទុកក្នុងសំណុំឯកសារឥណទានរបស់អតិថិជន (Client file)។

នាយកប្រតិបត្តិឥណទានខ្នាតតូច និងមធ្យម ជាអ្នកកំណត់ទំហំឥណទានសម្រាប់ធ្វើការត្រួតពិនិត្យឥណទាន តាមពេលកំណត់ (Periodic control) ដោយផ្អែកលើ ការវាយតម្លៃកម្រិតហានិភ័យ។

## ៣.៨.ការវិភាគលើការសងត្រឡប់មកវិញនៃឥណទាន

មន្ត្រីឥណទានត្រូវធ្វើការវិភាគ និងវាយតម្លៃលទ្ធភាពសងរបស់អតិថិជន ដើម្បីឲ្យប្រាកដថាឥណទានត្រូវបានសងត្រឡប់មកវិញទាំងប្រាក់ដើម និងទាំងការប្រាក់ឲ្យបានទាន់ពេលវេលា។

ការវាយតម្លៃប៉ាន់ស្មានលទ្ធភាពសងបំណុល ផ្អែកសំខាន់បំផុតលើចំណូលបច្ចុប្បន្នរបស់អ្នកខ្ចីជាមូលដ្ឋាន គឺមិនផ្អែកទៅលើចំណូលសំខាន់ៗពីមុខរបរ មិនគ្រប់គ្រាន់សម្រាប់សងបំណុលទេនោះចំណូលផ្សេងៗ អាចត្រូវបានយកមកពិចារណាតែត្រូវធ្វើការសិក្សាវិភាគឲ្យបានល្អិតល្អន់ធ្វើយ៉ាងណាបង្ហាញឲ្យឃើញថាអ្នកខ្ចីពិតជាមានលទ្ធភាពសងបំណុលបានទាំងស្រុង។

### ៣.៨.១.ការបង់ផ្តាច់មុនកាលកំណត់

ករណីអតិថិជនសងបំណុលបញ្ចប់មិនតាមកាលបរិច្ឆេទ នៃកិច្ចសន្យាខ្ចីប្រាក់ការប្រាក់ត្រូវបាន កាត់បន្ថយ លើកលែងតែអតិថិជនបង់ផ្តាច់ក្នុងរយៈពេលពីរលើកចុងក្រោយ។ ការប្រាក់ដែលត្រូវកាត់បន្ថយ ត្រូវបានគណនាសមាមាត្រទៅនឹងចំនួនថ្ងៃដែលសងដាច់មិនកាលកំណត់នោះ។

ករណីផ្សេងពីនេះ នាយិកានាយកដ្ឋានឥណទានខ្នាតតូច និងមធ្យម ជាអ្នកសម្រេច។

### ៣.៨.២.ការផ្តល់ឥណទានបន្ថែម

[8] LOAN PROCES 2014 របស់ធនាគារកាណាឌីយ៉ា ក.អ ទំព័រ ១៤៧

ការផ្តល់ឥណទានបន្ថែម លើសមតុល្យឥណទានចាស់ ត្រូវបានអនុញ្ញាតដោយអនុលោមទៅតាមនីតិវិធី និងសិទ្ធក្នុងការអនុម័តឥណទានលុះត្រាតែៈ

- អតិថិជនមានប្រវត្តិសងប្រាក់ល្អ។
- អតិថិជនមានមុខរបររីកចម្រើន ចំណូលកើនឡើង។
- ផ្តល់ឥណទានលើកមុនមិនទាន់អស់លទ្ធភាព។
- អតិថិជនត្រូវការដើមទុនពង្រីកមុខរបរបន្ថែម និងមានទ្រព្យសម្បត្តិធានាគ្រប់គ្រាន់។

**៣.៨.៣.ការខកខានសង និងការពិន័យ**

**ការខកខានសង**

- ឥណទានមួយត្រូវបានចាត់ទុកថាខកខានមិនបានសងតាមកិច្ចសន្យាកាលណា ដល់ពេលវេលាសងហើយអ្នកខ្ចីមិនបានសងទាន់ពេលវេលា (ក្នុងថ្ងៃ) ដូចមានចែងក្នុងកិច្ចសន្យា និងតារាងកាលវិភាគសងប្រាក់[9]។
- រយៈពេលខកខានសងប្រាក់គឺជាចំនួនថ្ងៃដែល ខកខានមិនបានសងតាមកិច្ចសន្យា រាប់ចាប់ពីថ្ងៃយឺតដំបូង ហើយរយៈពេលនឹងត្រូវបានកាត់បន្ថយ ក្នុងករណីទំហំទឹកប្រាក់បានសងសមាមាត្រទៅនឹងទំហំទឹកប្រាក់នៃចន្លោះរយៈពេលយឺតយ៉ាវសងនោះ។
- ទឹកប្រាក់ដែលខកខានសងគឺជាទឹកប្រាក់ដែលមិនបានសង ឬសងមិនគ្រប់ចំនួនចាប់ពីថ្ងៃដំបូង។ ទឹកប្រាក់ដែលសងក្រោយត្រូវយកទៅបំពេញឲ្យទឹកប្រាក់មិនបានសង ឬសងមិនគ្រប់ចំនួនដំបូង រួចហើយកាត់សងបំពេញទៅតាមទឹកប្រាក់មិនបានសង ឬសងមិនគ្រប់ចំនួននៅពេលបន្តបន្ទាប់។

**ការខកខានសងកម្រិតស្រាល** (Minor Default)

ការខកខានសងកម្រិតស្រាល គឺជាការខកខានសងប្រាក់ ដែលទឹកប្រាក់ខកខានមិនបានសង ឬទឹកប្រាក់សងមិនគ្រប់ចំនួនហួសកាលកំណត់នៃកិច្ចសន្យារយៈពេលតិចជាង៣០ថ្ងៃ។

**ការខកខានសងធ្ងន់ធ្ងរ** (Major Default)

ការខកខានសងធ្ងន់ធ្ងរ គឺជាការខកខានសងប្រាក់ ដែលទឹកប្រាក់ខកខានមិនបានសង ឬទឹកប្រាក់សងមិនគ្រប់ចំនួនហួសកាលកំណត់នៃកិច្ចសន្យារយៈពេលចាប់ពី៣០ថ្ងៃឡើងទៅ។

[9] LOAN PROCES 2014 របស់ធនាគារកាណាឌីយ៉ា ក.អ ទំព័រ ១៤២

ប្រធានមន្ត្រីឥណទាន អាចផ្ទេរការទទួលខុសត្រូវដោះស្រាយ ឥណទានដែលមានបញ្ហាយឺតយ៉ាវធ្ងន់ធ្ងរពីមន្ត្រីឥណទានឲ្យទៅមន្ត្រីដោះស្រាយបំណុល (ស្ថានភាពតម្រូវ) អាស្រ័យទៅតាមទំហំហានិភ័យ និងការចាត់ចែងរបស់សាខានីមួយៗ។

**ការពិន័យ**

**លក្ខខណ្ឌពិន័យ**

- ការខកខានសងបំណុលចាប់ពីរយៈពេល៤ថ្ងៃឡើងទៅត្រូវបានគិតពិន័យ។ អត្រាពិន័យត្រូវបានគិតស្មើនឹងទ្វេគុណនៃអត្រាការប្រាក់របស់ឥណទាននីមួយៗ។
- ទឹកប្រាក់ពិន័យត្រូវបាន គណនាតាមអត្រាពិន័យលើចំនួនទឹកប្រាក់ដែលខកខានមិនបានសងសមាមាត្រទៅនឹងចំនួនថ្ងៃដែលខកខានសងនោះ ចាប់គិតពីថ្ងៃទី០៤ ការយឺតយ៉ាវសងឡើងទៅ។

**ការគណនាប្រាក់ពិន័យ**

ប្រាក់ពិន័សយត្រូវបានគណនាតាមរូបមន្ត

$$P= \frac{A \times r \times N}{360}$$

- P ចំនួនទឹកប្រាក់ពិន័យ
- A ជាចំនួនទឹកប្រាក់ដែលខកខានសង
- r ២៤% ជាអត្រាកពិន័យក្នុងមួយឆ្នាំ
- N ជាចំនួនថ្ងៃដែលខកខានសងហួសកិច្ចសន្យា គិតចាប់ពីថ្ងៃទី០៤ នៃការយឺតយ៉ាវសងឡើងទៅ
- 360 ជាចំនួនថ្ងៃគិតក្នុងមួយឆ្នាំ

**ការលុបចោលប្រាក់ពិន័យ**

នាយក/នាយិការបស់សាខា មានសិទ្ធិសម្រេចលុបចោលប្រាក់ពិន័យ ក្នុងករណីមានហេតុផលសមរម្យដែលស្នើរឡើងដោយមន្ត្រីឥណទាន។ ដើម្បីលុបប្រាក់ពិន័យត្រូវតែមានឯកសារយោងសម្រាប់ចុះបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ។ ជារៀងរាល់ចុងខែ រាល់ករណីលុបចោលប្រាក់ពិន័យទាំងអស់ត្រូវរាយការណ៍ជូននាយកដ្ឋានឥណទានខ្នាតតូច និងមធ្យម។

**៣.៨.៤.ការផ្សព្វផ្សាយ**

ដើម្បីធ្វើឲ្យអតិថិជនយល់កាន់តែច្បាស់ពី ផលិតផល-សេវាកម្មរបស់ឥណទានខ្នាតតូច និងមធ្យមធនាគារកាណាឌីយ៉ា ក.អ ត្រូវធ្វើការផ្សព្វផ្សាយផលិតផល-សេវាកម្មរបស់ខ្លួន នៅក្នុងចំណោមកម្មករនិយោជិត និងនៅក្នុងអាជីវកម្ម ជំនួញមានសក្តានុពល និងសហគមន៍កសិករ។

មន្ត្រីឥណទាន (Loan Officer) ឬមន្ត្រីទីផ្សារឲ្យបានទូលំទូលាយនៅគ្រប់ទីកន្លែងនៃតំបន់ប្រតិបត្តិការ។

យុទ្ធសាស្ត្រផ្សព្វផ្សាយដែលអាចត្រូវបានយកមកប្រើមានដូចជា៖

- ការផ្សព្វផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ វិទ្យុ សារព័ត៌មាន។
- តាមរយៈមន្ត្រីឥណទាន មន្ត្រីផ្សព្វផ្សាយ និងគ្រប់បុគ្គលិកផ្សេងទៀតរបស់ធនាគារ។
- តាមរយៈអតិថិជនរបស់ធនាគារ។
- ការចុះធ្វើយុទ្ធនាការផ្សព្វផ្សាយ (ចែកប័ណ្ណផ្សព្វផ្សាយ ពន្យល់ បិទផ្សាយ) ។ល។

**៣.៨.៥.ទីផ្សារគោលដៅ**

ផលិតផលនេះត្រូវបានយកចិត្តទុកដាក់យ៉ាងពិសេស សម្រាប់បម្រើតម្រូវការទីផ្សារទៅតាមកម្រិតដែលអាចទទួលយកបានរបស់អតិថិជនកម្ពុជាគ្រប់រូបនៅតាមទីប្រជុំជន ទីក្រុង ទីជនបទ និងតំបន់នានាក្នុងប្រទេសកម្ពុជា ដែលមានសក្តានុពល។ ទីផ្សារគោលដៅរបស់ធនាគារគឺប្រជាជនកម្ពុជា គ្រប់រូបដែលស្ថិតក្នុងសហគមន៍សេដ្ឋកិច្ច ចាប់ពីកម្រិតទាបឡើងទៅ ជាលក្ខណៈឯកត្តជន (គ្រួសារ) ដែលជាសហគ្រាសសិប្បកម្ម កសិកម្ម ផលិតកម្ម សេវាកម្ម ពាណិជ្ជកម្មខ្នាតតូច និងមធ្យមដែលសកម្មភាពមុខរបរទាំងនោះ អនុលោមទៅតាមលក្ខណៈវិនិច្ឆ័យរបស់នាយកដ្ឋានឥណទានខ្នាតតូច និងមធ្យម។

ឈរលើមូលដ្ឋាននេះធនាគារគាំទ្រ នឹងបន្តគាំទ្រដល់អតិថិជនរបស់ខ្លួន ដែលជាបង្អែកដ៏រឹងមាំដើម្បីធ្វើឲ្យមានកំណើនសេដ្ឋកិច្ច កាន់តែប្រសើរឡើង ក្នុងគោលបំណងរួមចំណែកជាមួយ រដ្ឋាភិបាល កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ប្រទេសជាតិ។

ក្រុមគោលដៅសម្រាប់ទីផ្សារឥណទានខ្នាតតូច និងមធ្យមរបស់ធនាគារគឺ៖

- ក្រុមមនុស្សដែលធ្វើការងារ មានប្រាក់បៀវត្សរ៍ និងមានកេរ្តិ៍ឈ្មោះ និងទំនាក់ទំនងក្នុងសហគមន៍។
- ក្រុមមនុស្សមានអាជីវកម្មខ្លួនឯង ដែលមុខរបរមានសក្តានុពល ក្នុងទីផ្សារទៅតាមប្រភេទជំនួញ និងទីតាំងស្ថិតនៅក្នុងប្រទេសកម្ពុជាដែលមុខរបរមានជាសកម្មភាពស្របច្បាប់ និងមានតម្លាភាពលំហូរសាច់ប្រាក់មានស្ថេរភាពទៅតាមប្រភេទមុខរបរ។

**៣.៩.លក្ខណៈមនុស្សដែលអាចទទួលឥណទាន**

រូបវន្តបុគ្គលជានីតិជន (បុគ្គលដែលមានសិទ្ធិប្រកបការងារតាមផ្លូវច្បាប់) និងជានីតិបុគ្គលដែលរស់នៅ និងមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានប្រវត្តិ និងអត្តចរិតល្អ ដែលអាចជឿទុកចិត្តបាន។

- ធានាផ្តល់ព័ត៌មានជូនធនាគារត្រឹមត្រូវច្បាស់លាស់គ្រប់គ្រាន់ និងទាន់ពេលវេលា។
- មិនជាប់ពិរុទ្ធដែលពាក់ព័ន្ធនឹងបទល្មើសផ្សេងៗ។
- មានទីលំនៅអចិន្ត្រៃយ៍ក្នុងតំបន់ប្រតិបត្តិការ របស់សាខាធនាគារទទួលខុសត្រូវ និងបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរក្នុងតំបន់ដែលខ្លួនរស់នៅ ដូចជាមានសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ...។ល។
- មានមុខរបរ និងប្រាក់ចំណូល ឬប្រភពចំណូលច្បាស់លាស់ ដែលបង្ហាញពីលទ្ធភាពអាចសងបំណុលបានគ្រប់ចំនួនទាំងប្រាក់ដើម និងការប្រាក់។
- មានដី ផ្ទះ ឬទ្រព្យសម្បត្តិផ្សេងទៀតដែលអាចជំនួសបាន។
- មិនមានបំណងផ្លាស់ទីលំនៅទៅកន្លែងផ្សេង ក្រៅពីតំបន់ប្រតិបត្តិការ របស់សាខាធនាគារដែលខ្លួនបានទទួលប្រាក់កម្ចីរហូតដល់ពេលសងបំណុលធនាគារចប់។
- មានអាយុមិនលើសពី៦០ឆ្នាំនៅពេលដាក់ពាក្យស្នើសុំខ្ចីប្រាក់

មិនអនុញ្ញាតឲ្យខ្ចីឥណទានពីធនាគារចំពោះ៖

១. អនីតិជន ជនពិការសតិ (បុគ្គលដែលមិនមានសិទ្ធិប្រកបការងារតាមផ្លូវច្បាប់ក្រោមអាយុ១៨ឆ្នាំ និងជនពិការសតិ ញៀនគ្រឿងស្រវឹង និងញៀនថ្នាំ)។

២. អាជីវកម្មដែលច្បាប់ហាមឃាត់។

## ៣.១០. តម្រូវការ និងសុវត្ថិភាពឥណទាន

### ៣.១០.១. តម្រូវការសម្រាប់អ្នកខ្ចី

មានគម្រោងច្បាស់លាស់ដែលអាចបង្ហាញថាមុខជំនួញមានសក្តានុពលនិងមាននិរន្តរភាព

- យល់ច្បាស់រាល់ប្រការ លក្ខខណ្ឌ និងនីតិវិធីឥណទានរបស់ធនាគារ។
- មានការព្រមព្រៀងជាមុនគ្រប់ចំណុចលើ រាល់លិខិតស្នាមនិងផ្តិតមេដៃស្តាំនៅចំពោះមុខ។
- គោរពកាតព្វកិច្ចរបស់ខ្លួន និងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងកិច្ចសន្យា។
- មានលទ្ធភាពសងបំណុលទាន់ពេលវេលា និងយល់ព្រមបង់ប្រាក់ដល់ការិយាល័យធនាគារ។
- ករណីយល់ថាមិនអាចសងបំណុលទាន់ពេលវេលា អតិថិជនត្រូវតែរកអ្នកធានា ដែលមានសមត្ថភាពអាចសងបំណុលជំនួសខ្លួនបាន។
- មានទុនផ្ទាល់ខ្លួនក្នុងមុខរបរយ៉ាងតិច ២៥% នៃទុនវិនិយោគសរុប។
- មានទ្រព្យសម្បត្តិដែលអាចធានាបំណុលបានទាំងស្រុង។

- យល់ព្រមដាក់ទ្រព្យសម្បត្តិធានា។

### ៣.១០.២. តម្រូវការសម្រាប់ធានាសុវត្ថិភាពឥណទាន

តម្រូវការធានាសុវត្ថិភាពឥណទាន គឺប្រែប្រួលទៅតាមប្រភេទ ទំហំ និងកម្រិតហានិភ័យនៃឥណទានដូចតទៅ៖

- គ្រប់ប្រភេទឥណទាន តម្រូវឲ្យមានទ្រព្យសម្បត្តិ ដែលមានតម្លៃគ្រប់គ្រាន់ ដាក់ធានាសុវត្ថិភាពឥណទាន ឬមានអ្នកធានាអាស្រ័យទៅតាមកម្រិតហានិភ័យដែលប៉ាន់ស្មាន។ ចំពោះឥណទានដែលមានទំហំធំជាង ៥០,០០០ដុល្លារ តម្រូវឲ្យមានឯកសារកម្មសិទ្ធិ (ប្លង់រឹង)។
- ករណីមានអ្នកធានា អ្នកធានាត្រូវមានមុខរបរដាច់ដោយឡែកពីអ្នកខ្ចី ហើយត្រូវធ្វើការសិក្សាឲ្យបានច្បាស់លាស់ ដើម្បីឲ្យប្រាកដថាអ្នកធានា មិនមែនជាអ្នកកំពុងជំពាក់បំណុលរបស់អ្នកខ្ចី។
- តម្រូវការផ្សេងទៀតក៏ត្រូវឲ្យមានផងដែរ ដោយយោងទៅតាមកម្រិតហានិភ័យដែលបានប៉ាន់ស្មាន។

### ៣.១០.៣. តម្រូវការឯកសារ

- អត្តសញ្ញាណកម្មនៃអាសយដ្ឋាន៖
  - វិញ្ញាបនបត្រពីអាជ្ញាធរមូលដ្ឋានដែលអតិថិជនកំពុងស្នាក់នៅតំបន់នោះ។
  - ប្លង់ទីតាំងដែលបានគូសបង្ហាញដោយមន្ត្រីឥណទាន។

    ទាំងពីរនេះត្រូវបានទាមទារឲ្យមាន។
- ឯកសារអត្តសញ្ញាណកម្ម៖ ប្រតិបត្តិករអាចយកឯកសារអត្តសញ្ញាណកម្មមួយ ឬច្រើនក្នុងចំណោមឯកសារខាងក្រោម៖

**តារាងទី៣.១ តម្រូវការឯកសារ**

| ល.រ | ឈ្មោះឯកសារអត្តសញ្ញាណ | ច្បាប់ | កំណត់សម្គាល់ |
|---|---|---|---|
| ១ | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | ច្បាប់ថតចម្លង | ចំណាយរបស់ប្រធានមន្ត្រីឥណទាន |
| ២ | សៀវភៅគ្រួសារ | ច្បាប់ថតចម្លង | ចំណាយរបស់ប្រធានមន្ត្រីឥណទាន |
| ៣ | សៀវភៅស្នាក់នៅ | ច្បាប់ថតចម្លង | ចំណាយរបស់ប្រធានមន្ត្រីឥណទាន |
| ៤ | លិខិតឆ្លងដែន | ច្បាប់ថតចម្លង | ចំណាយរបស់ប្រធានមន្ត្រីឥណទាន |

| | | | |
|---|---|---|---|
| ៥ | សំបុត្រកំណើត | ច្បាប់ថតចម្លង | ចំណាយរបស់ប្រធានមន្ត្រីឥណទាន |
| ៦ | ប័ណ្ណបើកបរ | ច្បាប់ថតចម្លង | ចំណាយរបស់ប្រធានមន្ត្រីឥណទាន |
| ៧ | លិខិតបញ្ជាក់ទីលំនៅ | ច្បាប់ដើម | |

- អត្តសញ្ញាណកម្មនៃប្រភពចំណូលៈ
    - សម្រាប់ប្រាក់បៀវត្សរ៍ ជារបាយការណ៍ស្តីពីប្រាក់បៀវត្សរ៍ ឬកិច្ចសន្យាការងារ។
    - សម្រាប់អាជីករកម្មផ្ទាល់ខ្លួន។

ដោយផ្អែកលើការចុះផ្ទាល់ដល់ទីកន្លែង ការត្រួតពិនិត្យវិក័យបត្រទិញ-លក់យ៉ាងណាស់មានក្នុងរយៈពេលមួយខែ ឬរបាយការណ៍ក្រៅផ្លូវការ។

### ៣.១០.៤.ភាគីខ្ចីប្រាក់

ភាគីខ្ចីប្រាក់អាចជាប្តី ប្រពន្ធ ឬអ្នកស្នងមរតក ឬឪពុកម្តាយ និងត្រូវដឹងលឺ ព្រមទាំងទទួលខុសត្រូវអំពីការសុំខ្ចីឥណទាន ពីធនាគារនិងយល់ព្រមៈ

- សងបំណុលឲ្យបានទាន់ពេលវេលាតាមកិច្ចសន្យា ដោយមិនឲ្យយឺតយ៉ាវឡើយ។
- សុខចិត្តលក់ទ្រព្យសម្បត្តិរបស់គ្រួសារ ដើម្បីដោះស្រាយបញ្ហាខកខាន សងបំណុលរបស់ ធនាគារ។

## ៣.១១. ឯកសារឥណទាន ការទទួលខុសត្រូវ និងសិទ្ធិអនុម័តឥណទាន

### ៣.១១.១. ឯកសារឥណទាន

**ការរៀបចំឯកសារមុនពេលអនុម័តឥណទានរួមមានៈ**

- ទម្រង់ពាក្យស្នើសុំខ្ចីឥណទាន (មាននៅក្នុងឧបសម្ព័ន្ធ៣)។
- ទម្រង់ផែនការអាជីវកម្ម។
- ទម្រង់វាយតម្លៃទ្រព្យដាក់បញ្ចាំ។
- រូបថតអតិថិជន (មិនតម្រូវ ប្រសិនបើឯកសារអត្តសញ្ញាណជាឯកសារដែលមានបិទរូបថត និងឥណទាននោះមានទំហំមិនលើសពី ៣,៥០០ដុល្លារ)។
- ឯកសារកំណត់អត្តសញ្ញាណ។
- ឯកសារកំណត់អាសយដ្ឋាន។
- ឯកសារកំណត់កំណត់ប្រាក់ចំណូល (អាចរៀបចំដោយមន្ត្រីឥណទាន)។
- ទម្រង់ការយល់ព្រមជាមួយការិយាល័យឥណទាន (មាននៅក្នុងពាក្យសុំខ្ចី)។

**ការរៀបចំឯកសារក្រោយពេលអនុម័តឥណទាន និងមុនពេលបញ្ចេញឥណទានៈ**

- កិច្ចសន្យាឥណទាន

- ចុះហត្ថលេខាលើតារាងកាលវិភាគសងប្រាក់
- វិក័យបត្រសាច់ប្រាក់ សម្រាប់សោហ៊ុយឥណទាន និងសោហ៊ុយផ្សេងៗ
- ទម្រង់បង្កាន់ដៃតម្កល់ទ្រព្យដាក់បញ្ចាំ
- រូបថតពីសកម្មភាពអាជីវកម្ម (មិនទាមទារ សម្រាប់ឥណទានដែលមាន ទំហំរហូតដល់ ៣,៥០០ ដុល្លារ)។

### ៣.១១.២. ការទទួលខុសត្រូវ និងសិទ្ធិអនុម័តឥណទាន

- សិទ្ធិអនុម័តឥណទានរបស់នាយក/នាយិកាសាខា៖

សិទ្ធិអនុម័តឥណទានរបស់ នាយក/នាយិកាសាខាត្រូវអនុលោមទៅតាមការសម្រេចរបស់នាយកប្រតិបត្តិ។ ក្នុងករណីនាយក/នាយិកាសាខាអវត្តមាន សិទ្ធិអនុម័តឥណទាន នឹងត្រូវផ្ទេរមកនាយកដ្ឋានឥណទានខ្នាតតូច និងមធ្យមដោយស្វ័យប្រវត្តិ។

ឯកសារឥណទានដែលបញ្ជូនមកដើម្បីអនុម័ត ត្រូវមានសំណើរនិងសេចក្តីបញ្ជាក់របស់មន្ត្រីឥណទានទទួលបន្ទុក និងប្រធានឥណទាន។

ករណីយល់ឃើញថា មានភាពមិនប្រក្រតីក្នុងការអនុម័តឥណទាន នាយកប្រតិបត្តិអាចព្យួរសិទ្ធិអនុម័តឥណទាន របស់នាយក/នាយិកាសាខា តាមការស្នើសុំរបស់ នាយិកានាយកដ្ឋានឥណទានខ្នាតតូច និងមធ្យម។

- សិទ្ធិអនុម័តរបស់នាយិការនាយកដ្ឋានឥណទានខ្នាតតូច និងមធ្យម៖

សិទ្ធិអនុម័តឥណទានរបស់នាយិកានាយកដ្ឋានឥណទានខ្នាតតូច និងមធ្យម ត្រូវអនុលោមទៅតាមការសម្រេចរបស់នាយកប្រតិបត្តិ។ ក្នុងករណីនាយិកានាយកដ្ឋានឥណទានខ្នាតតូច និងមធ្យមអវត្តមាន សិទ្ធិអនុម័តឥណទាន នឹងត្រូវផ្ទេរមក នាយកឥណទានដែលត្រូវបានចាត់តាំង (Appointed Credit Manager) ដោយស្វ័យប្រវត្តិ។

ឯកសារឥណទានដែលបញ្ជូនមកដើម្បីអនុម័ត ត្រូវមានសំណើ និងសេចក្តីបញ្ជាក់របស់មន្ត្រីឥណទានទទួលបន្ទុក ប្រធានឥណទាន និងនាយក/នាយិកាសាខា។

- សិទ្ធិអនុម័តឥណទានរបស់គណៈកម្មាធិការឥណទាន៖

អនុម័តរាល់ការកែប្រែគោលការណ៍ឥណទាន ការអភិវឌ្ឍន៍គោលការណ៍ឥណទានថ្មី និងផែនការយុទ្ធសាស្ត្រឥណទានរបស់ធនាគារ។

## ៣.១២. ការវិភាគ SWOT នៅលើការគ្រប់គ្រងឥណទានរបស់ធនាគារភាណាឌីយ៉ា ក.អ

### ៣.១២.១ ចំណុចខ្លាំង (Strength)

ស្របតាមសក្តានុពល ដូចដែលបានរៀបរាប់ដូចខាងលើ របស់ស្ថាប័នធនាគារកាណាឌីយ៉ាក.អ ផលិតផលឥណទានខ្នាតូចនិងមធ្យមរបស់ធនាគារនេះ បានពន្លឿននៃការរីកចំរើនទៅលើប្រតិបត្តិការះ

- កាណាឌីយ៉ាក.អមានរចនាសម្ព័ន្ធការងារច្បាស់លាស់ ដែលបានបែងចែកភារកិច្ច និងទំនួលខុសត្រូវច្បាស់លាស់។
- ធនាគារមានយុត្តិសាស្ត្រលើកទឹកចិត្តបុគ្គលិកឲ្យមានសាមគ្គីភាព និងមានសហប្រតិបត្តិការល្អក្នុងការបំពេញការងារ។
- ផ្តល់ឥណទានរបស់ធនាគារកាណាឌីយ៉ាក.អ សុទ្ធតែមានសមត្ថភាព និងចំណេះដឹងជ្រៅជ្រះព្រមទាំងមានជំនាញច្បាស់លាស់។
- មន្ត្រីឥណទានបានថែរក្សាទំនាក់ទំនង និងបង្កើតភាពស្និតស្នាលជាមួយនឹងអតិថិជន ដែលបង្ហាញពីការរាប់អានស្និតស្នាល រួសរាយរាក់ទាក់ ដែលឆ្លុះបញ្ចាំងឲ្យឃើញថាធនាគារយកចិត្តទុក ដាក់ចំពោះអតិថិជន។
- ធនាគារកាណាឌីយ៉ាក.អមានគោលការណ៍ច្បាស់លាស់ ក្នុងការដោះស្រាយបំណុលដែលខកខានមិនបានសងមកវិញតាមការកំណត់។ ធនាគារកាណាឌីយ៉ាក.អ កម្រប្តឹង ឬរឹបអូសយកទ្រព្យសម្បត្តិពីអតិថិជនណាស់លុះត្រាតែបញ្ហានោះ មានសភាពធ្ងន់ធ្ងរមិនអាចដោះស្រាយបាន ដោយគោរពទៅតាមកិច្ចសន្យា ដែលជាកិច្ចព្រមព្រៀងនៃភាគីទាំងសងខាង។
- ការផ្តល់អត្រាការប្រាក់គឺមានកំរិតទាប។
- ធនាគារនឹងមិនធ្វើការផាកពិន័យ ចំពោះការទូទាត់មុនកាលកំណត់ ដែលប្រតិបត្តិការនេះមានលក្ខណៈផ្ទុយពីធនាគារដទៃទៀត ដែលធ្វើការពិន័យទៅលើការទូទាត់មុនកាលអវសាន។

### ៣.១២.២. ចំណុចខ្សោយ (Weakness)

ទោះបីធនាគារកាណាឌីយ៉ាក.អ មានគុណសម្បត្តិច្រើនយ៉ាងណាក៏ដោយ ក៏ធនាគារនៅតែមានចំណុចខ្វះខាតមួយចំនួនមិនទាន់គ្រប់គ្រាន់ដូចជាះ

- ពុំទាន់រៀបចំប៉ុស្ដិ៍សេវាកម្ម សំរាប់បំពេញតំរូវការអតិថិជន នៅតាមស្រុកតំបន់ដាច់ស្រយាល។ តែទោះបីចំណាយតិចក្នុងការចំណាយ ក្នុងការធ្វើដំណើររបស់អតិថិជនក្តី វាអាចជា ចំណុចខ្សោយនាំអោយបាត់បង់អតិថិជននៅតំបន់ដាច់ស្រយាល។

- ចំពោះឥណទានលើពី ប្រាំម៉ឺនដុល្លារដាច់ខាតត្រូវតែមានប្លង់រឹង ដើម្បីទប់ស្កាត់ហានិភ័យ។

### ៣.១៤.៣. ឱកាស (Opportunity)

- ធនាគារកាណាឌីយ៉ា ក.អ នឹងអាចឈានមុខគេពេលអនាគត ដោយសារសន្ទុះនៃការរីកចំរើននៃសេដ្ឋកិច្ច ពិសេសកំណើនប្រជាជនដែលនឹងជម្រុញឲ្យមានការកើនឡើងនៃតំរូវការឥណទានខ្នាតតូច និងមធ្យមក្នុងការពង្រីកអាជីវកម្មរបស់ពួកគេ។
- ដោយសារធនាគារកាណាឌីយ៉ាក.អ ជាស្ថាប័នមួយដែលមានវ័យចំណាស់ ជាងគេនៅក្នុងវិស័យធនាគារ ដូចនេះគេអាចមានលទ្ធភាពទាក់ទាញអតិថិជន វិនិយោគធំៗបានច្រើនតាមរយៈកេរ្តិ៍ឈ្មោះនេះ និងការរក្សាទំនាក់ទំនងល្អជាមួយអតិថិជន។

### ៣.១៤.៤. ការគំរាមកំហែង (Threats)

- បច្ចុប្បន្នមានគូប្រកួតប្រជែងច្រើន ដូចជាអ្នកវិនិយោគផ្នែកអចលនទ្រព្យ ស្ថាប័នធនាគារមួយចំនួន ដែលជាដៃគូប្រកួតប្រជែង បានជំរុញប្រតិបត្តិការរបស់ខ្លួនដូចនឹងផលិតផលឥណទានខ្នាតតូច និងមធ្យម របស់ធនាគារកាណាឌីយ៉ាក.អ ដែរ ដោយសារពិនិត្យឃើញនូវសក្តានុពលនៃវិស័យអចលទ្រព្យផ្នែកឥណទាននេះ។
- កំនើនរបស់ធនាគារពាណិជ្ជមានសន្ទុះខ្លាំងក្លាពេក ដែលជាភាព គំរាមកំហែងសម្រាប់ការប្រកួតប្រជែងចំពោះផលិតផល និងសេវាកម្មដូចគ្នា។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ឆ្លងកាត់ការសិក្សានូវទ្រឹស្តីក្នុងរយៈពេល ៤ឆ្នាំ ក្នុងជំនាញគ្រប់គ្រងសហគ្រាស មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាសេដ្ឋកិច្ច ជាពិសេសយោងតាមការចុះកម្មសិក្សានៅធនាគារកាណាឌីយ៉ា ក.អ ទីស្នាក់ការកណ្តាល លើប្រធានបទ "ការគ្រប់ គ្រងឥណទានខ្នាតតូច និងមធ្យម" របស់ធនាគារកាណាឌីយ៉ា ក.អ កន្លងមកយើងខ្ញុំជាបេក្ខភាព កម្មសិក្សាសម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្របានស្វែងយល់ និងទទួលបានលទ្ធផលវិភាគដូចមានបង្ហាញខាងក្រោមនេះ ៖

- សេវាកម្មឥណទានរបស់ធនាគារកាណាឌីយ៉ាក.អ អាចបំពេញតម្រូវការរបស់ អតិថិជនបានគ្រប់គ្រាន់ ដោយមានការប្រាក់សមរម្យ ងាយស្រួលរត់ឯកសារ បុគ្គលិកមានក្រមសីលធម៌ខ្ពស់។
- ជាមួយគ្នានេះដែរ ចំពោះការ refinance ពីធនាគារផ្សេង យើងមានបំរើជូនដោយឥតគិតថ្លៃហើយថែមទាំងបញ្ចុះការប្រាក់ប្រចាំឆ្នាំជូនមួយភាគរយថែមទៀតផង ដើម្បីទាក់ទាញដល់អតិថិជន។
- ទន្ទឹមជាមួយគ្នានេះដែរ ធនាគារកាណាឌីយ៉ា ក.អ កំពុងពង្រីកសាខារបស់ខ្លួននៅតាមបណ្តាខេត្តដាច់ស្រយាលមួយចំនួនមានការកើនឡើងជាលំដាប់។
- ទទួលបានការគាំទ្រពីអតិថិជន ពីមួយឆ្នាំទៅមួយឆ្នាំ មានការកើនឡើងយ៉ាងគាប់ប្រសើរ។

## ២. ការផ្តល់អនុសាសន៍

ដោយផ្អែកលើកាស្រាវជ្រាវនិងឆ្លងតាមការធ្វើសេចក្តីសន្និដ្ឋានអំពីស្ថាប័នធនាគារកាណាឌីយ៉ាក.អ រួចមក ក្រុមយើងខ្ញុំសង្កេតឃើញថាដំណើរការអាជីវកម្មក្នុងការផ្តល់កម្ចីរបស់ធនាគារកាណាឌីយ៉ាក.អ មានលទ្ធផលវិជ្ជមានគួរឲ្យកត់សម្គាល់។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏ក្រុមយើងខ្ញុំសង្កេតឃើញថានៅមានចំនុចខ្វះខាតមួយក្នុងប្រតិបត្តិការផ្តល់ឥណទាន ដូចនេះក្រុមយើងខ្ញុំសូមចូលរួមបញ្ចេញមតិយោបល់ខ្លះៗសម្រាប់ប្រយោជន៍ដល់ស្ថាប័ន៖

- គ្រឹះស្ថានគួរតែពង្រីកសាខាឲ្យបានច្រើនជាងមុនជាពិសេសតាមភូមិឃុំ ដែលនៅតាមបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជា ដែលវាជួយសម្រួលដល់ការចំណាយ លើមធ្យោ

បាយធ្វើដំណើរជួយកាត់បន្ថយហានិភ័យរបស់អតិថិជនក៏ដូចជា មន្ត្រីឥណទានសម្រាប់ការធ្វើដំណើរផ្លូវឆ្ងាយ។

- គ្រឹះស្ថានគួរតែព្យាយាមកាត់បន្ថយ នូវអត្រាការប្រាក់តាមដែលអាចធ្វើទៅបានដើម្បីធ្វើការប្រកួតប្រជែងជាមួយគ្រឹះស្ថានដទៃទៀត។
- ស្ថាប័នគួរបង្កើនសកម្មភាពផ្សព្វផ្សាយពាណិជ្ជកម្ម ក៏ដូចជាគោលការណ៍ ផ្តល់ប្រាក់កម្ចីរបស់ខ្លួនឲ្យបានច្រើនទោះក្នុងរូបភាពណាក៏ដោយ គឺដើម្បីបង្កើកទំនុកចិត្តពីអតិថិជន ក៏ដូចជាអ្នកវិនិយោគផងដែរ។

សរុបមកទោះបីជា ធនាគារកាណាឌីយ៉ាក.អ នៅមានភាពខ្វះខាតក៏ពិតមែន តែយើងអាចសន្និដ្ឋានបានថា ធនាគារកាណាឌីយ៉ា ក.អ ក៏នៅតែជាធនាគារដែលនាំមុខគេ និងមានអតិថិជនទទួលស្គាល់ច្រើន ជាពិសេសក្នុងចំនោមអាជីវករនិងពាណិជ្ជករ។ ការរីកចម្រើនរបស់ធនាគារកាណាឌីយ៉ាក.អ បានស្តែងចេញឲ្យឃើញតាមរយៈការពង្រីកសកម្មភាព និងការបង្កើតសាខាតាមខេត្តក្រុង មួយចំនួនក្នុងព្រះរាជាណាចក្រកម្ពុជាយើង ហើយធនាគារកាណាឌីយ៉ា ក.អ បច្ចុប្បន្នក៏បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ តាមរយៈការផ្តល់ឥណទាននេះ ក៏ដូចជាការជំរុញក្នុងការវិនិយោគក្នុងស្រុក និងផ្តល់ឱកាសការងារសម្រាប់ប្រជាពលរដ្ឋយើងបានមួយចំនែកផងដែរ។ ដូច្នេះប្រតិបត្តិការឥណទានខ្នាតតូច និងមធ្យមក៏មានតួនាទីសំខាន់ណាស់ក្នុងការរួមចំណែកជំរុញសេដ្ឋកិច្ច ឲ្យមានការរីកចំរើន ជាពិសេសក្នុងការបម្រើដល់វិស័យធំៗជាច្រើន ដូចជាឧស្សាហកម្ម សេវាកម្ម ពាណិជ្ជកម្ម ព្រមជាមួយគ្នានេះដែរ វាក៏បានជួយលើកកម្ពស់កំរិតជីវភាពរបស់ប្រជាជនបានមួយកំរិតទៀតផង។

យើងខ្ញុំជាក្រុមសិក្សាស្រាវជ្រាវ និងចុះកម្មសិក្សា សង្ឃឹមយ៉ាងមុតមាំថា គណៈគ្រប់គ្រងបុគ្គលិកពាក់ព័ន្ធ នឹងធ្វើការពិចារណា និងទទួលយកដោយក្តីអនុគ្រោះ និង អធ្យាស្រ័យខ្ពស់បើសិនការសិក្សា និងការវិភាគនៅមានភាពខ្វះខាត ដោយសារបទពិសោធន៍មានកម្រិត។

# គន្ថនិទ្ទេស

១. លោក ងួនហេង "រូបិយវត្ថុ និង ធនាគារ" ឆ្នាំ ២០១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។

២. លោក ជា សែម អ្នកស្រី ឡាយ សុខឃាង លោក ឆួយ សុគន្ធ "គណិតវិទ្យា សេដ្ឋកិច្ច" ឆ្នាំ២០១២-២០១៣នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។

៣. សៀវភៅដំណើរការឥណទានរបស់ធនាគារកាណាឌីយ៉ា ក.អ ។

៤. គេហទំព័រ ធនាគារកាណាឌីយ៉ា ក.អ : www.canadiabank.com.kh

# ឧបសម្ព័ន្ធ១

# ពាក្យស្នើសុំឥណទាន

# ឧបសម្ព័ន្ធ២

# របាយការណ៍វាយតម្លៃឥណទាន

# ឧបសម្ព័ន្ធ៣

# លិខិតបញ្ជាក់ការយល់ព្រម

# ឧបសម្ព័ន្ធ៤

# កិច្ចសន្យាដាក់បញ្ញាំ